ISSN 1560-7615 / ISBN 978-99950-52-06-5


# ទស្សនាវដ្តី អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី១៤ លេខ ១ | មករា - មីនា ឆ្នាំ២០១០ | តម្លៃ ១.៥០០៛


20 ខួបលើកទី
CDRI 1990-2010

# ការរឹតត្បិតឥណទាន និងសាច់ប្រាក់: ផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកលលើប្រព័ន្ធធនាគារនៅកម្ពុជា[១]


ធនាគារជាតិនៃកម្ពុជា ជានិយតករដ៏សំខាន់សម្រាប់វិស័យធនាគារនៅកម្ពុជា

## សេចក្តីផ្តើម

ផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកលមកលើប្រទេសកម្ពុជា អាចមើលឃើញច្បាស់ណាស់ ។ គេគន់គូរថា កម្ពុជាស្ថិតក្នុងចំណោមបណ្តាប្រទេសកំពុងអភិវឌ្ឍន៍នៅអាស៊ីខាងកើត ដែលត្រូវរួមចុះកំណើនសេដ្ឋកិច្ចធ្ងន់ធ្ងរជាងគេ នៅឆ្នាំ២០០៩ (CDRI 2009c; World Bank 2009a, 2009b; ADB 2009; IMF 2009b, 2009c) ។ ឥទ្ធិពលវិបត្តិនេះ អាចពិនិត្យឃើញជាសំខាន់តាមការប៉ះទង្គិចទៅលើពាណិជ្ជកម្ម លំហូរមូលធន និងជាពិសេស ក្បាលម៉ាស៊ីនកំណើនរបស់កម្ពុជាតែម្តង ។ ទោះបីប្រព័ន្ធធនាគារក្នុងស្រុករបស់កម្ពុជាបានរួចផុតពីឥទ្ធិពលប៉ះទង្គិចនៅជុំទី១ ដោយសារមិនសូវមានជាប់ពាក់ព័ន្ធនឹងផលិតផលកម្ចីលេខពីរដែលគ្រោះថ្នាក់ខ្លាំងក្តី ប៉ុន្តែត្រូវប្រឈមមុខនឹងឧបសគ្គយ៉ាងច្រើន ដោយសារស្ថានភាពសេដ្ឋកិច្ចមិនល្អ និងការរឹងស្ងួតឥណទាន និងសាច់ប្រាក់ជាសាកល ។ ដូចស្ថានភាពសេដ្ឋកិច្ចសាកលលោកដែរ សេដ្ឋកិច្ចកម្ពុជា បានឆ្លងផុតចំណុចចុះទាបបំផុតរួចហើយ ប៉ុន្តែនៅមានហានិភ័យធំៗជាច្រើនទៀត (សូមមើល Jalilian *et al.* 2009; CDRI 2009a, 2009b, 2009c) ។ អត្ថបទនេះពិនិត្យពីផលប៉ះពាល់នៃវិបត្តិមកលើវិស័យធនាគារនៅកម្ពុជា ។

## ផលប៉ះពាល់លើប្រព័ន្ធធនាគារក្នុងស្រុក

ការរឹតត្បិតឥណទាន និងសាច់ប្រាក់ងាយស្រួលក្នុងស្រុក បង្ហាញច្បាស់ពីភាពតានតឹងនៃស្ថានភាពរូបិយវត្ថុទូទៅ ចាប់ពីពាក់កណ្តាលឆ្នាំ២០០៨ មក ទោះបីក្នុងប៉ុន្មានខែកន្លងទៅនេះ សកម្មភាពសេដ្ឋកិច្ច ឃើញថា បានប្រសើរឡើងវិញខ្លះៗក្តី ។ កំណើនរូបិយវត្ថុទូទៅពីមួយឆ្នាំទៅមួយឆ្នាំ បានធ្លាក់ចុះ

---

១ អត្ថបទនេះ រៀបចំដោយ Hossein Jalilian (នាយកផ្នែកស្រាវជ្រាវនៃ CDRI) និង Glenda Reyes (អ្នកស្រាវជ្រាវនៃ CDRI) ដោយសង្ខេបចេញពីរបាយការណ៍ព្រាងដែលរៀបចំសម្រាប់ជាឯកសារពិភាក្សាវិស័យហិរញ្ញវត្ថុសាកលនៃ Overseas Development Institute ។ របាយការណ៍នេះ នឹងត្រូវបញ្ចប់នាពេលឆាប់ៗខាងមុខ ។ការពិគ្រោះយោបល់ជាមួយអ្នកតំណាងផ្សេងៗក្នុងវិស័យធនាគារ ត្រូវបានធ្វើឡើង ដើម្បីជួយទ្រទ្រង់ និងបញ្ជាក់បន្ថែមលើការវាយតម្លៃពីផលប៉ះពាល់នៃវិបត្តិទៅលើប្រព័ន្ធធនាគារ ។
អ្នកនិពន្ធ សូមអរគុណផងដែរដល់លោក សាំង ច័ន្ទហង្ស (អ្នកស្រាវជ្រាវនៃ CDRI) ដែលបានចូលរួមធ្វើការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធផ្សេងៗ ។

## មាតិកា


ការរឹតត្បិតឥណទាន និងសាច់ប្រាក់:ផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកលលើប្រព័ន្ធធនាគារនៅកម្ពុជា ............១
ផលប៉ះពាល់នៃការធ្លាក់ចុះសេដ្ឋកិច្ចសាកល លើភាពក្រីក្រ និងការអភិវឌ្ឍសង្គមនៅកម្ពុជា ................................ ៧
ការវិភាគពីរដ្ឋកម្ពុជាក្នុងលក្ខណៈ ជារដ្ឋជំរុញអភិវឌ្ឍន៍ ........១១
តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស.......................១៥
— ស្ថានភាពក្នុងប្រទេស....................... ១៧
ព័ត៌មានថ្មីៗពី វិទ្យាស្ថាន CDRI ................................ ២៤

ក្រាហ្វិក ១: កំណើនរូបិយវត្ថុទូទៅ (បំលាស់ប្ដូរពីមួយឆ្នាំទៅមួយឆ្នាំ)




*ប្រភព: ធនាគារជាតិនៃកម្ពុជា (NBC)*

ចាប់ពីប្រហែល ៦០% នៅខែកុម្ភៈ ២០០៨ មកត្រឹម -១% ក្នុងឆ្នាំបន្ទាប់ រួចទើបកើនឡើងបន្តិចវិញ ដល់ប្រហែល ១៣% នៅខែសីហា ២០០៩ (ក្រាហ្វិក ១) ។

កាលពីមុន សូចនាករភាពរឹងមាំខាងហិរញ្ញវត្ថុ បង្ហាញថា ធនាគារក្នុងស្រុកគិតជារួម រក្សាបានស្ថានភាពរឹងប៉ឹង នៅពេលរីកធំធាត់ ដោយមានមូលធនបង្ការ និងសាច់ប្រាក់ងាយស្រួលគ្រប់គ្រាន់ និងមានបញ្ហាតិចតួចខាងប្រាក់កម្ចី (Jalilian *et al*. 2009; IMF 2009a) ។ ចំនួនធនាគារ កើនឡើងយ៉ាងលឿន រហូតដល់ ធនាគារពាណិជ្ជ មាន ២៧ ធនាគាររដ្ឋ មាន ១ និងធនាគារឯកទេស មាន ៥ នាពេលបច្ចុប្បន្ន ។ មានស្ថាប័នធនាគារមួយចំនួនតូចប៉ុណ្ណោះ ដែលដើរតួសំខាន់ក្នុង ផសស ។ ទោះយ៉ាងនេះក្ដី ទ្រព្យសកម្មរបស់ធនាគារសរុប គិតជាចំណែកនៃ ផសស បានកើនឡើងពី ២៦% នៅខែធ្នូ ២០០៦ មកដល់ ៤៧% នៅខែធ្នូ ២០០៨ ហើយប្រាក់កម្ចីគិតជាភាគរយនៃ ផសស កើនឡើងប្រហែល ១១% (ធនាគារជាតិនៃកម្ពុជា) ។

បន្ទាប់ពីនោះមក គេឃើញមានការតានតឹងកាន់តែខ្លាំងឡើង ដោយធនាគារត្រូវប្រឈមមុខនឹងហានិភ័យកាន់តែធំខាងឥណទាន និងសាច់ប្រាក់ងាយស្រួល ។ ប្រហែល ៩៧% នៃប្រាក់បញ្ញើនៅធនាគារសរុប ជាប្រាក់បញ្ញើជារូបិយប័ណ្ណ ហើយកាលពីខែកុម្ភៈ ២០០៨ កំណើនពីមួយឆ្នាំទៅមួយឆ្នាំនៃប្រាក់បញ្ញើប្រភេទនេះ មានប្រហែល ៧០% ប៉ុន្តែមួយឆ្នាំក្រោយមក វាបានធ្លាក់ចុះមកត្រឹម -៤% (ក្រាហ្វិក ១) ។ គេរាយការណ៍ថា មានការដកប្រាក់ច្រើនៗមួយចំនួនជារូបិយប័ណ្ណ ហើយក៏មានការដាក់បញ្ចូលមូលនិធិបន្ទាន់ពីក្រុមហ៊ុនមេនៅឯបរទេស ដែលធ្វើឱ្យប្រព័ន្ធធនាគារត្រូវពឹងផ្អែកខ្លាំងទៅលើមូលធនពីបរទេស[២] ។

នៅដើមឆមាសទី២ ឆ្នាំ២០០៩ សាច់ប្រាក់ងាយស្រួល បានកើនឡើងបន្តិចវិញ នាំឱ្យមានការវាយតម្លៃថា គ្រោះថ្នាក់លើសាច់ប្រាក់ងាយស្រួលបានកន្លងផុតហើយ ។ នៅខែសីហា កំណើនប្រាក់បញ្ញើជារូបិយប័ណ្ណពីមួយឆ្នាំទៅមួយឆ្នាំ មាន ១១% ។ អនុបាតសាច់ប្រាក់ងាយស្រួល បានកើនឡើង (ខ្ពស់ល្អជាងកម្រិតប្រុងប្រយ័ត្ន) ពី ៨១% នៅចុងឆ្នាំ២០០៨ ដល់ ៩៣% នៅខែសីហា ២០០៩ (ក្រាហ្វិក ២) ។ មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានយល់ស្របថា បច្ចុប្បន្ននេះ សាច់ប្រាក់ងាយស្រួល មានគ្រប់គ្រាន់នៅក្នុងប្រព័ន្ធធនាគារ (IMF 2009b) ហើយអ្នកតំណាងរបស់វិស័យធនាគារក្នុងស្រុកក៏ឯកភាពដូច្នេះដែរ ប៉ុន្តែគេបានលើកពីការបារម្ភខ្លះលើបញ្ហាសាច់ប្រាក់ងាយស្រួលដែលប្រមូលផ្ដុំនៅក្នុងធនាគារធំៗ និងហានិភ័យនៃការធ្លាក់ចុះវិញ ដែលអាចធ្វើឱ្យស្ថានភាពប្រែប្រួលក្រឡាប់ចាក់ (ការពិភាក្សាជាមួយអ្នកពាក់ព័ន្ធ) ។

ផ្ទុយទៅវិញ ការព្រួយបារម្ភលើហានិភ័យនៃឥណទាន ដែលពិនិត្យឃើញតាមរយៈការប្រុងប្រយ័ត្នជាបន្តទៀតក្នុងការផ្ដល់កម្ចីទៅដល់វិស័យឯកជននោះ គឺមិនទាន់រលាយបាត់អស់នៅឡើយទេ បើទោះជាអារម្មណ៍ភ័យព្រួយនេះប្រែប្រួលទៅតាមកម្រិតធ្ងន់ធ្ងរនៃហានិភ័យក៏ដោយ ។ កំណើនឥណទានវិស័យឯកជនពីមួយឆ្នាំទៅមួយឆ្នាំ ធំលើស ១០០% នៅតាមខែនីមួយៗក្នុងត្រីមាសទី២ ឆ្នាំ២០០៨ ហើយនៅតែរក្សាកំណើនខ្លាំងដដែល គឺ ៥០% នៅចុងឆ្នាំ២០០៨ ។

ការរីកដុះដាលលឿននេះ ហាក់ដូចកើតឡើងជាមួយនឹងបញ្ហាខ្លះៗ ដែលធនាគារជាតិនៃកម្ពុជាបានព្យាយាមដោះស្រាយក្នុងកិច្ចប្រឹងប្រែងជួយការពារប្រព័ន្ធធនាគារក្នុងស្រុក កុំឱ្យជួបភាពតានតឹងកាន់តែខ្លាំងថែមទៀត ។ ចំណែកនៃឥណទានមិនដំណើរការ (NPL) នៅក្នុងឥណទានសរុប បានកើនឡើងពីប្រហែល ៣,៧% នៅចុងខែធ្នូ ២០០៨ ដល់ ៥,៩% នៅខែសីហា ២០០៩ (ក្រាហ្វិក ២) ។ ប៉ុន្តែ វានៅតែជាចំណែកមួយតូចដដែល ជាពិសេសបើធៀប

---

២ នៅចុងខែធ្នូ ២០០៨ មូលធនពីបរទេស រួមចំណែកប្រហែល ៦៧% នៃមូលធនបានបង់ជំរះសរុបរបស់ប្រព័ន្ធធនាគារពាណិជ្ជ (NBC) ។

ក្រាហ្វិក ២: អនុបាតប្រុងប្រយ័ត្ននៃធនាគារ*** (គិតជា %)




*ប្រភព: ធនាគារជាតិនៃកម្ពុជា (NBC)*

*** អនុបាតប្រុងប្រយ័ត្ននៃធនាគារ ជាសូចនាករស្តីពីសុខភាពហិរញ្ញវត្ថុរបស់ធនាគារ ។ អនុបាតសាធនភាព និងអនុបាតសាច់ប្រាក់ងាយស្រួល បង្ហាញពីលទ្ធភាពរបស់ធនាគារក្នុងការសងបំណុលរយៈពេលខ្លី និងរយៈពេលវែងរបស់ខ្លួន រីឯអនុបាតមូលធនគ្រប់គ្រាន់ (ទ្រព្យម្ចាស់ធៀបនឹងទ្រព្យសកម្មសរុប) បង្ហាញពីលទ្ធភាពរបស់ធនាគារក្នុងការទប់ទល់នឹងការខាតបង់ជាសក្តានុពលផ្សេងៗ ។ អនុបាតបំណុលធៀបនឹងទ្រព្យសកម្មសរុប បង្ហាញពីភាគរយនៃទ្រព្យសកម្មរបស់ធនាគារដែលទទួលហិរញ្ញប្បទានពីការខ្ចីបុលជាជាងបានពីទ្រព្យម្ចាស់ ហើយអនុបាតឥណទានមិនដំណើរការ (NPL) បង្ហាញពីភាគរយនៃកម្ចីធនាគារ ដែលមិនត្រូវបានទូទាត់សង ឬប្រហែលជាមិនអាចទូទាត់សងវិញ ។

នឹងកំណើនយ៉ាងលឿននៃឥណទានកាលពីមុន ។ ម្យ៉ាងវិញទៀត កំណើនឥណទាននេះ អាចបណ្តាលមួយផ្នែកមកពីការធ្វើចំណាត់ថ្នាក់ឡើងវិញនៃឥណទានដែលធនាគារជាតិនៃកម្ពុជាបានអនុវត្ត ដោយយោងតាមបទបញ្ញត្តិកាន់តែតឹងរ៉ឹងជាងមុន ស្តីពីការធ្វើចំណាត់ថ្នាក់ទ្រព្យសកម្ម និងការធ្វើសវិធានធន (ការពិភាក្សាជាមួយអ្នកពាក់ព័ន្ធ)[៣] ។

ចំណែកនៃឥណទានរបស់ធនាគារផ្តល់ទៅឱ្យវិស័យអចលនទ្រព្យ (ក្រាហ្វិក ៣) ដែលមានហានិភ័យកើនខ្ពស់ ដោយសារអចលនទ្រព្យក្នុងស្រុកបានដួលរលំ និងឥទ្ធិពលពីវិបត្តិ តាមពិតមានមិនច្រើនប៉ុន្មានឡើយ ប៉ុន្តែរឿងនេះ អាចមិនត្រឹមត្រូវទាំងស្រុងទេ ព្រោះមានកម្ចីរបស់បុគ្គលឯកជនមួយចំនួន ក៏ប្រហែលបានយកមកប្រើប្រាស់ក្នុងសកម្មភាពខាងអចលនទ្រព្យដែរ ។ ដោយសារទំនាក់ទំនងជិតស្និទ្ធរវាងការសាងសង់ និងការអភិវឌ្ឍអចលនទ្រព្យក្នុងប្រទេស ឥណទានធនាគារដែលផ្តល់ទៅឱ្យវិស័យសំណង់ក៏មានចំណែកទទួលរ៉ាប់រងហានិភ័យដែលពាក់ព័ន្ធនឹងវិស័យអចលនទ្រព្យដែរ ។ ការធ្វើកាលវិភាគថ្មីលើកម្ចី អាចជួយលាក់បាំងបញ្ហាឥណទានមិនដំណើរការតទៅទៀត[៤] ។ អនុបាតឥណទានមិនដំណើរការ រំពឹងថា អាចកើនខ្ពស់បំផុតដល់ ១០% នៅចុងឆ្នាំនេះ (សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ចេញថ្ងៃទី ២៧ សីហា ២០០៩) ។

នៅខែសីហា ២០០៩ កំណើនប្រចាំឆ្នាំនៃឥណទានចំពោះវិស័យឯកជនបានធ្លាក់ចុះមកត្រឹម ៤% ប៉ុណ្ណោះ ដោយសារការប្រុងប្រយ័ត្នជាបន្តក្នុងការផ្តល់ឥណទាន ។ ក្នុងពេលជាមួយគ្នា ឥណទានធនាគារផ្តល់ទៅឱ្យវិស័យអចលនទ្រព្យ បានថយចុះមកត្រឹម ៦,៤% ធៀបនឹង ៧,៦% កាលពីឆ្នាំមុន (ក្រាហ្វិក ៣) ។ ផ្អែកតាមសូចនាករប្រុងប្រយ័ត្នផ្សេងៗ (ដូចជា អនុបាតសាច់ប្រាក់ងាយស្រួលបានលើកឡើងនៅខាងលើ និងអនុបាតមូលធនគ្រប់គ្រាន់) លទ្ធផលសំរេចបានអាចធ្វើឱ្យប្រព័ន្ធធនាគារមានសាច់ប្រាក់បង្ការគ្រប់គ្រាន់សម្រាប់ដោះស្រាយបញ្ហាខាងឥណទាន ក៏ដូចជា ហានិភ័យផ្សេងៗ ។

មិនមែនមានតែធនាគារពាណិជ្ជ និងធនាគារឯកទេស ប៉ុណ្ណោះទេ ដែលទទួលរងនូវឥទ្ធិពលជុំទី២ នៃវិបត្តិ បណ្តាស្ថាប័នមីក្រូហិរញ្ញវត្ថុ (MFIs)

៣ សូមពិនិត្យផងដែរនូវប្រកាសស្តីពីការធ្វើចំណាត់ថ្នាក់ឡើងវិញ និងការធ្វើសវិធានធនក្នុងស្ថាប័នហិរញ្ញវត្ថុ និងធនាគារ ចុះនៅដើមឆ្នាំ២០០៩ និងចុះក្នុងគេហទំព័រ http://www.nbc.org.kh/read-prakas.asp?id=63 ។ ដោយសារការរីកដុះដាលនៃវិស័យធនាគារក្នុងឆ្នាំ២០០៨ និងការដាក់អនុវត្តប្រកាសខាងលើដែលបានបង្កើនសវិធានធនតាមការតំរូវ ផលចំណេញលើចំណូលដុល (return on earnings) បានធ្លាក់ចុះពី ១៣,១១% នៅចុងឆ្នាំ២០០៨ មកត្រឹម ៣,៦៩% រីឯចំណូលពីទ្រព្យសកម្ម (return on asset) ធ្លាក់ចុះពី ២,៨៨% មកត្រឹម ០,៨២% (ទិន្នន័យរបស់ NBC) ។

៤ ក្នុងពេលពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ មានការលើកឡើងថា យុទ្ធសាស្ត្រអាចមានការ "កែច្នៃ" តារាងតុល្យការមួយចំនួនឱ្យល្អមើល ។ ឥណទានមានចោទបញ្ហាខ្លាំងមួយចំនួន ប្រហែលបានរៀបចំតារាងពេលឡើងវិញ ឱ្យទៅជាបំណុលរយៈពេលយ៉ាងវែង ដែលមានការបង់រំលោះតិចជាងមុន ។ ការអនុវត្តបែបនេះប្រហែលគ្រាន់តែអាចពន្យាពេលបញ្ហារបស់សាមីធនាគារប៉ុណ្ណោះ ។

ក្រាហ្វិក ៣: ចំណែកផ្សេងៗនៃឥណទានធនាគារ (គិតជា % នៃឥណទានសរុប)




*ប្រភព: ធនាគារជាតិនៃកម្ពុជា (NBC)*

ក៏រងឥទ្ធិពលនេះដែរ ថ្វីបើពីមុននោះ ហាក់ដូចពុំឃើញមានការប៉ះពាល់អ្វីសោះ ។ ដោយសារ MFIs នៅជិតជាប់ជាមួយអតិថិជននៅតាមទីជនបទ និងបានពង្រីកកម្ចីទៅដល់សហគ្រាសធនតូច និងមធ្យម និងទៅដល់វិស័យកសិកម្ម MFIs កាន់តែមានប្រជាប្រិយភាពខ្លាំងក្នុងប៉ុន្មានឆ្នាំកន្លងទៅនេះ ទោះបីជាវិស័យនេះនៅតូច បើធៀបនឹងប្រព័ន្ធធនាគារពាណិជ្ជកម្ម (Jalilian *et al.* 2009) ។ ត្រឹមខែសីហា ២០០៩ មាន ២០ MFIs ដែលមានអាជ្ញាប័ណ្ណ និងមានអង្គការមិនមែនរដ្ឋាភិបាលអ្នកផ្ដល់មីក្រូឥណទាន ចំនួន ២៥ អង្គការដែលបានចុះបញ្ជីរួច និងជាង ៦០អង្គការទៀត ដែលមិនទាន់ចុះបញ្ជី (NBC) ។

ថ្វីបើមានជាប់ពាក់ព័ន្ធតិចជាមួយឥណទានមានហានិភ័យខ្ពស់ (ដូចជាឥណទានដល់វិស័យអចលនទ្រព្យ និងសំណង់ ជាដើម) ក៏ដោយ ក៏ស្ថាប័នមីក្រូហិរញ្ញវត្ថុ ជួបការតឹងតែងកាន់តែខ្លាំងដែរ នៅពេលវិបត្តិកាន់តែធ្ងន់ធ្ងរឡើង ។ វិស័យនេះ ពឹងផ្អែកខ្លាំងលើមូលធនពីបរទេស[៥] ដូច្នេះហើយក៏ទទួលរងឥទ្ធិពលពីការស្ទះសាច់ប្រាក់ងាយស្រួលជាសាកល និងកំណើនការខ្លាចរអាហានិភ័យ ។ គេរាយការណ៍ថា អ្នកផ្ដល់ឥណទានពីបរទេសមកឱ្យ MFIs ក្នុងស្រុក បានធ្វើការរឹតត្បិតឥណទាន ដែលបណ្ដាលឱ្យមានការលុបកិច្ចសន្យាក្នុងករណីមួយចំនួន និងការតំឡើងថ្លៃហិរញ្ញប្បទាន ហើយជាលទ្ធផល MFIs ត្រូវផ្ទេរបន្ទុកចំណាយមួយភាគ ឬទាំងអស់លើការតំឡើងអត្រាការប្រាក់ទៅលើអតិថិជន (Chhun 2009) ។

សូចនាករប្រុងប្រយ័ត្ន ហាក់បង្ហាញថា MFIs អាចជៀសផុតពីផលប៉ះពាល់ភាគច្រើននៃវិបត្តិបានប្រសើរជាងពួកធនាគារពាណិជ្ជ ។ អនុបាតឥណទានមិនដំណើរការរបស់ MFIs បានឡើងដល់ ២,៧% នៅខែសីហា ២០០៩ ធៀបនឹង ០,៤% នៅចុងឆ្នាំ២០០៨ ប៉ុន្តែវាជាអត្រាមួយទាបទេ បើយើងពិចារណាដល់ការរីកដុះដាលយ៉ាងរហ័សនៃមីក្រូឥណទាន ។ កំណើនអត្រានេះ អាចបណ្ដាលមួយចំណែកដោយសារការធ្វើចំណាត់ថ្នាក់ឥណទានឡើងវិញដែលតំរូវឡើងដោយធនាគារជាតិនៃកម្ពុជា ។ អនុបាតមូលធនគ្រប់គ្រាន់ ក៏កើនឡើងដែរ ពី ២០,៤% នៅឆ្នាំ២០០៨ ដល់ ២៣,៥% នៅខែសីហា ២០០៩ (NBC និងការពិភាក្សាជាមួយអ្នកពាក់ព័ន្ធ) ។

សរុបមក វិស័យធនាគារនៅកម្ពុជា រួមទាំង MFIs និងអ្នកផ្ដល់សេវាហិរញ្ញវត្ថុផ្សេងៗផង ហាក់ដូចមិនសូវប៉ះពាល់ធ្ងន់ធ្ងរដោយសារវិបត្តិទេ ។ ប៉ុន្តែអាចមានការប៉ាន់ស្មានទាបពេកពីផលប៉ះពាល់នៃវិបត្តិទៅលើវិស័យធនាគារ ហើយបញ្ហាពាក់ព័ន្ធផ្សេងៗ ប្រហែលអាចកើតមានឡើងចំពោះធនាគារមួយចំនួននៅពេលក្រោយទៀត ។

## គោលនយោបាយឆ្លើយតប

ភាពអន់ថយនៃវិស័យហិរញ្ញវត្ថុកម្ពុជា អាចជាកត្តានាំឱ្យកម្ពុជាគេចផុតពីឥទ្ធិពលជុំទី១ នៃវិបត្តិ ។ ប៉ុន្តែភាពអន់ថយនេះ ក៏ជាឧបសគ្គរារាំងដល់សមត្ថភាពរបស់រដ្ឋាភិបាល និងស្ថាប័នហិរញ្ញវត្ថុ ដើម្បីឆ្លើយតបឱ្យបានស័ក្ដិសិទ្ធិជាងនេះ ចំពោះឥទ្ធិពលជុំទី២ នៃវិបត្តិ ។ ធនាគារជាតិនៃកម្ពុជា បានឆ្លើយតបបានទាន់ពេលគួរឱ្យកោតសរសើរចំពោះសំពាធក្នុងវិស័យហិរញ្ញវត្ថុក៏ពិតមែន ប៉ុន្តែសមត្ថភាពរបស់ធនាគារកណ្ដាលដើម្បីធ្វើការងារឱ្យបានច្រើនថែមទៀត ត្រូវជួបឧបសគ្គនៃដុល្លារូបនីយកម្មក្រៅផ្លូវការដ៏ខ្លាំងក្លានៃសេដ្ឋកិច្ច ។ សមត្ថភាពពិនិត្យតាមដាន មានដែនកំណត់របស់ NBC និងឧបសគ្គខាងផ្លូវច្បាប់ គឺជាកត្តាសំខាន់ផ្សេងៗទៀតក្នុងរឿងនេះ ។

ការស្រាវជ្រាវពីបញ្ហាសេដ្ឋកិច្ចប្រើរូបិយវត្ថុពីររបស់កម្ពុជា វាស្ថិតនៅក្រៅដែនកំណត់នៃការសិក្សានេះ ដូច្នេះ យើងសូមលើកយកចំណុចសំខាន់ៗបី

៥ មូលធនពីបរទេស រួមចំណែកប្រហែល ៧៣% ក្នុងមូលធនបានបង់ជំរះសរុបរបស់វិស័យ MFI (NBC) ។

មកបង្ហាញតែប៉ុណ្ណោះ ។ ទីមួយ ដុល្លាររូបនីយកម្មនាបច្ចុប្បន្នរបស់កម្ពុជា មិនមែនមានលក្ខណៈត្រង់ៗ ងាយស្វែងយល់ឡើយ ។ តាមការជជែកវែកញែក ដុល្លាររូបនីយកម្ម ចែកចេញជា"ដំណឹងល្អ" និង"ដំណឹងអាក្រក់" គឺបានន័យថា វាឆ្លុះបញ្ចាំងទាំងជោគជ័យនៃសេដ្ឋកិច្ចកម្ពុជាក្នុងទសវត្សរ៍កន្លងទៅ និងទាំងភាពអន់ថយនៃវិស័យហិរញ្ញវត្ថុក្នុងស្រុក ស្ថាប័ន និងក្របខ័ណ្ឌច្បាប់ ក៏ដូចជា បញ្ហាខាងប្រវត្តិសាស្ត្រ (CDRI 2009c; Menon 2008) ។

ទីពីរ ហេតុផលត្រូវគាំទ្រ ឬត្រូវប្រឆាំងនឹងដុល្លាររូបនីយកម្ម ក៏មិនច្បាស់លាស់ដាច់ណាត់ដែរ ។ ចំណាយសំខាន់ៗនៃដុល្លាររូបនីយកម្មដែលគេបានអះអាងឡើង រួមមានការខាតបង់ចំណូលដែលទទួលបានពីការចេញផ្សាយក្រដាសប្រាក់ ការបាត់បង់លទ្ធភាពរបស់ធនាគារកណ្ដាលក្នុងការដើរតួជាអ្នកផ្ដល់កម្ចីចុងក្រោយគេ និងការបាត់បង់គោលនយោបាយរូបិយវត្ថុដែលមានលក្ខណៈឯករាជ្យ ហើយទាំងអស់នេះ វាកាត់បន្ថយលទ្ធភាពក្នុងការឆ្លើយតបនឹងការប៉ះទង្គិចពីខាងក្រៅ ។ដោយមិនបាច់និយាយដល់អត្ថប្រយោជន៍នៃដុល្លាររូបនីយកម្មផង គេក៏មិនគួរវាយតម្លៃពីការខាតបង់ ដោយមិនពិចារណាពីកត្តាឯទៀតៗ ជាពិសេស កត្តាផ្សេងៗ ដែលអាចជួយសំរាលការខាតបង់ ដូចជា ផលប្រយោជន៍ខាងហិរញ្ញវត្ថុនៃស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលកើតឡើងពីឥទ្ធិពលល្អនៃដុល្លាររូបនីយកម្ម (ជួយកាត់បន្ថយអតិផរណា អត្រាការប្រាក់ និងហានិភ័យខាងរូបិយវត្ថុ) ជាដើម ដែលអាចប៉ះប៉ូវនូវការខាតបង់ចំណូលទទួលបានពីការចេញផ្សាយក្រដាសប្រាក់ ។

**សកម្មភាពទាំងឡាយដែល NBC បានធ្វើកន្លងមក ពិតជាទាន់ពេល និងអាចបង្ការគ្រោះថ្នាក់បានល្អ គួរឱ្យកោតសរសើរ ។**

ទីបី ក្រៅពីធនាគារកណ្ដាល នៅមានប្រភពផ្ដល់សាច់ប្រាក់ងាយស្រួលដទៃទៀត ដែលជួយបង្ការគ្រោះថ្នាក់នៃសាធនភាព និងកង្វះសាច់ប្រាក់ងាយស្រួល ដែលជាប់ទាក់ទងនឹងដុល្លាររូបនីយកម្ម ក្នុងពេលមានវិបត្តិ ។ នៅពេលស្ថាប័នរូបិយវត្ថុនានា កំពុងប្រឈមមុខនឹងបញ្ហាបាត់បង់ទំនុកចិត្តដែរនោះ សេណារីយ៉ូនៃការលុបចោលដុល្លាររូបនីយកម្ម អាចចោទបញ្ហាកាន់តែស្មុគស្មាញ និងធ្វើឱ្យបាត់បង់ឱកាសទាញយកចំណេញពីតួនាទីជាឧបករណ៍បញ្ជាក់កិច្ចសន្យានៃដុល្លាររូបនីយកម្ម (សូមមើល Chang & Velasco 2002; Schmitt-Grohé & Uribe 2000; Alvarez-Plata & Garcia-Herrero 2008; Antinolfi & Keister 2001; Edwards & Magendzo 2003; Baliño *et al*. 1999) ។

ឆ្លងតាមការពិចារណាដូចខាងលើ យើងឃើញថា លទ្ធភាពរបស់ NBC ក្នុងការឆ្លើយតបនឹងវិបត្តិពិតជាមានកម្រិតព្រំដែនជៀសមិនផុត ។ទោះយ៉ាងណាក្ដី សកម្មភាពទាំងឡាយដែល NBC បានធ្វើកន្លងមក ពិតជាទាន់ពេល និងអាចបង្ការគ្រោះថ្នាក់ បានល្អគួរឱ្យកោតសរសើរ ។ ពិសេសទៅទៀត ដោយសារវិបត្តិសាកលបានកើតឡើងភ្លាមៗ បន្ទាប់ពីមានកំណើនថ្លៃទំនិញខ្ពស់ជាខ្លាំងនោះ ធនាគារកណ្ដាល ត្រូវបន្ស៊ីពេលគ្នាយ៉ាងប្រុងប្រយ័ត្នរវាងការបន្ធូរបន្ថយការរឹតបន្តឹងខាងរូបិយវត្ថុ និងការកាត់បន្ថយអតិផរណា ។នៅពេលថ្លៃទំនិញ ធ្លាក់ចុះជាបណ្ដើរៗមកវិញនោះ NBC បានកាត់បន្ថយការតំរូវធនបំរុងពី ១៦% មកត្រឹម ១២% ដើម្បីដាក់បញ្ចូលសាច់ប្រាក់ងាយស្រួលបន្ថែមមកក្នុងប្រព័ន្ធធនាគារ ។NBC បានលុបចោលនូវការដាក់កម្រិតលើការផ្ដល់ឥណទានទៅឱ្យវិស័យអចលនទ្រព្យ ដើម្បីបញ្ឈប់ការរំលំរលាយដំណើរការរីកដុះដាលលឿន ។ ធនាគារជាតិ ក៏បានបង្កើតសេវាឥណទានលើសសមតុល្យ (ទោះបីពីដំបូងមានប្រាក់សម្រាប់គាំទ្រត្រឹម ១00លានដុល្លារ [CEW 2009]) សម្រាប់ជួយដល់ធនាគារដែលនៅមានលទ្ធភាពសងបំណុលគេ និងដែលកំពុងជួបកង្វះខាតសាច់ប្រាក់ងាយស្រួលជាបណ្ដោះអាសន្ន ។ NBC បានចេញបទបញ្ជាតឹងរ៉ឹងជាងមុនស្ដីពីការធ្វើចំណាត់ថ្នាក់ទ្រព្យសកម្មឡើងវិញ និងការធ្វើសវិធានធន ដើម្បីកំណត់បានកាន់តែត្រឹមត្រូវលើស្ថានភាពឥណទានមិនដំណើរការ និងធានាឱ្យធនាគារនានា មានស្ថានភាពប្រសើរជាងមុនក្នុងការទប់ទល់នឹងការខាតបង់ផ្សេងៗ ។ NBC ក៏បានរឹតបន្តឹងបទបញ្ជាស្ដីពីការរាយការណ៍ពីហានិភ័យធំៗ ដើម្បីអាចវាយតម្លៃបានប្រសើរជាងមុនពីការប្រមូលផ្ដុំហានិភ័យខាងឥណទាន ។ NBC បានពង្រឹងការត្រួតពិនិត្យដល់ទីកន្លែង និងការត្រួតពិនិត្យលើឯកសារ ទាំងជាលក្ខណៈទៀងទាត់ និងមិនទៀងទាត់ ។ NBC ក៏បានចាប់ផ្ដើមផ្ដល់អាជ្ញាប័ណ្ណអនុញ្ញាតឱ្យ MFIs អាចប្រមូលទទួលយកប្រាក់បញ្ញើពីសាធារណជនដោយផ្ទាល់ដែរ (Keat 2009; CEW 2009; Jalilian *et al*. 2009; Chhun 2009; see also NBC—www.nbc.org.kh/index.asp) ។

គេគួរអនុវត្តជំហានមួយចំនួនថែមទៀត ដើម្បីបង្កើនប្រសិទ្ធភាព និងជៀសវាងបញ្ហាផ្សេងៗទៅថ្ងៃមុខ ។ ចន្លោះប្រហោងដែលអាចកើតមានក្នុងការត្រួតពិនិត្យលើឥណទានមិនដំណើរការ ត្រូវបិទឱ្យជិត ព្រោះការវិនិច្ឆ័យក្នុងផ្លូវខុសបង្កឡើងនូវអារម្មណ៍សុខសាន្តខុសទំនង ដែលនាំឱ្យមានការធ្វេសប្រហែស ឬការឆ្លើយតបខុសផ្លូវ ។ សំខាន់ជាងការឆ្លើយតបឆាប់រហ័សទៅនឹងតំរូវការរយៈពេលខ្លីនៃវិបត្តិទៅទៀត គេត្រូវអនុវត្តជំហានធំៗ កែលំអប្រព័ន្ធហិរញ្ញវត្ថុឱ្យបានស៊ីជំរៅ ដើម្បីពង្រឹងសមត្ថភាពសម្រាប់ទប់ទល់នឹងការប៉ះទង្គិចពីខាងក្រៅ និងជៀសវាងករណីដែលប្រព័ន្ធហិរញ្ញវត្ថុខ្លួនឯងក្លាយជាប្រភពនៃវិបត្តិ ។ នាបច្ចុប្បន្ន រចនាសម្ព័ន្ធហិរញ្ញវត្ថុនៅក្មេងខ្ចីនៅឡើយ ឧបករណ៍ហិរញ្ញវត្ថុក៏មានតិច ទីផ្សារអន្តរធនាគារក៏នៅអន់ថយ ទីភ្នាក់ងារផ្ដល់ចំណាត់ថ្នាក់ និងធានារ៉ាប់រងប្រាក់បញ្ញើជាផ្លូវការ ក៏មិនទាន់មាន ហើយការចែកចាយព័ត៌មានឥណទានក៏មានតិចដែរ (Pak *et al*. 2008)។ NBC កំពុងពិចារណាយ៉ាងប្រុងប្រយ័ត្នលើជំរើសនានាសម្រាប់ដោះស្រាយចំណុចខ្វះខាតទាំងនេះ និងគិតគូរថ្លឹងថ្លែងពីផលប្រយោជន៍ និងគុណវិបត្តិនៃមធ្យោបាយសម្រាប់ដោះស្រាយនានា និងសមត្ថភាពនៃប្រព័ន្ធហិរញ្ញវត្ថុក្នុងការអនុវត្តមធ្យោបាយទាំងនេះ ។ ចំពោះការងារផ្ទៃក្នុងវិញ NBC កំពុងព្យាយាមកសាងសមត្ថភាពបុគ្គលិករបស់ខ្លួន ដោយប្រើប្រាស់ធនធានដែលខ្លួនមាន (ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ) ។

ហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុ ក៏នៅខ្វះទីផ្សារហ៊ុនដែលមានសារៈសំខាន់ច្រើនដែរ ។ កង្វះនេះ បានជួយការពារប្រទេសកម្ពុជាឱ្យរួចផុតពីឥទ្ធិពលដោយផ្ទាល់ចំបងៗ និងឥទ្ធិពលឆ្លងរាលដាលនៃវិបត្តិហិរញ្ញវត្ថុក៏ពិតមែន ប៉ុន្តែវាក៏ជាឧបសគ្គផងដែរ ដល់ការបង្កើតមូលនិធិបន្ថែមសម្រាប់ជួយជំរុញស្ថានភាពសេដ្ឋកិច្ចយ៉ាប់យ៉ឺន ក៏ដូចជា តារាងតុល្យការមានខ្វង់ខូចខាតច្រើនរបស់ធនាគារ ។ បញ្ហាខាងលើ ស្ថិតនៅខាងក្រៅដែនកំណត់នៃអត្ថបទនេះ ដូច្នេះ យើងគ្រាន់តែបញ្ជាក់យ៉ាងខ្លីថា ថ្វីបើរដ្ឋាភិបាលមានឯកសារផែនការវិស័យហិរញ្ញវត្ថុឆ្នាំ២០០១-២០១០ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥ ដែលមានកំណត់ពីវិធានការត្រៀមមួយចំនួន (រួមទាំងការដាក់អនុវត្តច្បាប់ និងបទបញ្ញត្តិដ៏ចាំបាច់ និងការបង្កើតគណៈកម្មការមូលបត្រផង) ក៏នៅខ្វះបុព្វលក្ខខណ្ឌជាច្រើនសម្រាប់ឱ្យទីផ្សារហ៊ុនដំណើរការបានដោយជោគជ័យ ។ គោលដៅចំបងនៃការអភិវឌ្ឍទីផ្សារមូលធន គឺដើម្បីធ្វើការប្រមែប្រមូលប្រាក់សន្សំ ប៉ុន្តែអត្រាប្រាក់សន្សំក្នុងស្រុក មានកម្រិតទាប ដែលបណ្តាលមួយចំណែកមកពី កម្រិតយល់ដឹងទាបខាងហិរញ្ញវត្ថុរបស់សាធារណជន និងកង្វះទំនុកចិត្តលើប្រព័ន្ធហិរញ្ញវត្ថុ ។ បញ្ហាដទៃទៀតរួមមាន មូលដ្ឋានវិនិយោគិនតូចចង្អៀត ការអនុវត្តមិនបានល្អតាមស្តង់ដារតម្លាភាព និងអភិបាលកិច្ចរបស់ក្រុមហ៊ុន ដែលប៉ះពាល់ដល់ទំហំនៃអ្នកចេញផ្សាយសន្លឹកហ៊ុនមានសិទ្ធិ និង អវត្តមាននៃអន្តរការីសន្លឹកហ៊ុន ។

## ចក្ខុវិស័យ និងហានិភ័យ

ទោះបីជាសេដ្ឋកិច្ចកម្ពុជា និងសេដ្ឋកិច្ចសាកល បានចាប់ងើបឡើងវិញ ហើយលទ្ធផលក៏សំរេចបានគួរឱ្យពេញចិត្ត យោងតាមសូចនាករភាពរឹងមាំខាងហិរញ្ញវត្ថុក៏ដោយ ក៏នៅតែមានការព្រួយបារម្ភពីភាពរឹងមាំនៃវិស័យធនាគារដដែល ។ ប៉ុន្តែការព្រួយបារម្ភនេះ ប្រែប្រួលខុសៗគ្នា គឺអ្នកដែលមិនសូវទុទិដ្ឋិនិយម បានសំលឹងឃើញការងើបឡើងវិញនៃវិស័យអចលនទ្រព្យ ហើយច្រើនផ្តោតការគិតគូរលើស្ថានភាព ដូចជា ការប្រែប្រួលមិនល្អជាយថាហេតុនៃឥណទានមិនដំណើរការ ដែលជះឥទ្ធិពលតែលើធនាគារខ្លះប៉ុណ្ណោះ ។ រីឯអ្នកទុទិដ្ឋិនិយមខ្លាំងវិញ គេផ្តោតការយកចិត្តទុកដាក់លើបញ្ហាបង្កប់ផ្សេងៗ លើធនាគារកណ្តាល ដែលត្រូវរ៉ាប់រងការងារស្ទើរហួសសមត្ថភាព និងហានិភ័យពីខាងក្រៅ ដូចជា ការធ្លាក់ចុះពីរដងនៃសេដ្ឋកិច្ចសាកល នៅពេលគេដកចេញវិញនូវកម្មវិធីជំរុញវិស័យហិរញ្ញវត្ថុនានា ។ សរុបមក អ្នកមិនសូវទុទិដ្ឋិនិយម គិតថា គ្រោះថ្នាក់បានកន្លងផុតហើយ ប៉ុន្តែអ្នកទុទិដ្ឋិនិយមខ្លាំង បានក្រើនរំលឹកថា នៅពេលខាងមុខ អាចមានស្ថានភាពអាក្រក់ជាងនេះទៀត ។

## ប្រភព:


ការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនៅចន្លោះខែតុលា និងវិច្ឆិកា ២០០៩

ADB (2009), *Asia Economic Outlook Update* (Manila: ADB)

Alvarez-Plata, P. & A. Garcia-Herrero (2008), *To Dollarize or De-dollarize: Consequences for Monetary Policy*, DIW Discussion Paper 842 (Berlin: DIW)

Antinolfi, G. & T. Keisner (2001), "Dollarization as a Monetary Arrangement for Emerging Market Economies", *Review*, November (Federal Reserve Bank of St Louis)

Baliño, T., A. Bennett & E. Borenzstein (1999), *Monetary Policy in Dollarized Economies (Overview)*, IMF Occasional Paper 171 (Washington, DC: IMF)

Cambodia Economic Watch (CEW) (2009), *Economics Today*, Special Issue, July (Vol. 2, No. 42)

CDRI (2009a), *Cambodia Outlook Briefs* (Phnom Penh: CDRI)

CDRI (2009b), *Cambodia Development Review*, April –June (Phnom Penh: CDRI)

CDRI (2009c), "Cambodia Country Report", prepared for the International Conference on East Asian Economy in Beijing, 22–23 October

Chang, R. & A. Velasco (2002), *Dollarization: Analytical Issues*, NBER Working Paper 8838 (Cambridge: NBER)

Chhun, S. (2009), "Can MFIs Survive?", *Economics Today*, Vol. 2, No. 37

Edwards, S. & I.I. Magendzo (2003). *Strict Dollarization and Economic Performance: An Empirical Investigation*, NBER Working Paper 9820 (Cambridge: NBER)

Keat Chhon (2009), "Keynote Address on the Occasion of the Official Inauguration of the Securities and Exchange Commission", 29 April

IMF (2009a), *Country Report No. 09/47*, Cambodia: 2008 Article IV Consultation—Staff Report; Staff Supplement; and Public Information Notice on the Executive Board Discussion (Washington, DC: IMF)

IMF (2009b), "Statement at the Conclusion of an IMF Staff Mission to Cambodia", Press Release No. 09/325

IMF (2009c), *World Economic Outlook: Sustaining the Recovery* (Washington, DC: IMF)

Jalilian, H., S. Chan, G. Reyes, C.H. Saing, D. Pon, & D. Phann (2009), *Cambodia*, Global Financial Crisis Discussion Paper Series, 3 (London: ODI)

Menon, Jayant (2008), *Cambodia's Persistent Dollarization: Causes and Policy Options*, ADB Working Paper Series on Regional Economic Integration, No. 19 (Manila: ADB)

Nguon, S. (2009). Bad Loans Rising, *Phnom Penh Post*, 27 August.

Pak, S., T. Hourn & M. Biallas (2008), *Cambodia Financial Sector Diagnostic* (Washington, DC: IFC)

Prakas on Asset Classification and Provisioning in Banking and Financial Institutions, http://www.nbc.org/read-prakas/asp?id=63.

Schmitt-Grohé, S. & M. Uribe (2000), *Stabilization and the Costs of Dollarization*, Departmental Working Papers 200006 (New Brunswick: Rutgers University)

World Bank (2009a), *East Asia and Pacific Update —Battling the Forces of Global Recession* (Washington, DC: World Bank)

World Bank (2009b), *East Asia and Pacific Update —Transforming the Rebound into Recovery* (Washington, DC: World Bank)

# ផលប៉ះពាល់នៃការធ្លាក់ចុះសេដ្ឋកិច្ចសាកល លើភាពក្រីក្រ និងការអភិវឌ្ឍសង្គមនៅកម្ពុជា[1]

## ប្រវត្តិព្រឹត្តិការណ៍

វិបត្តិហិរញ្ញវត្ថុសាកល បានលេចឡើងកាន់តែច្បាស់ក្នុងអំឡុងខែកញ្ញា ២០០៨ ដោយសារការដួលរលំបណ្តាស្ថាប័នហិរញ្ញវត្ថុធំៗជាច្រើន ដែលមានមូលដ្ឋាននៅសហរដ្ឋអាមេរិក ។ វិបត្តិនេះ បានរីករាលដាលចេញពីសហរដ្ឋអាមេរិក ទៅកាន់ប្រទេសផ្សេងៗទៀតក្នុងទូទាំងសាកលលោក រួមទាំងប្រទេសកំពុងអភិវឌ្ឍន៍ ដូចជា ប្រទេសកម្ពុជាជាដើម ។

ដោយទទួលបានជំនួយទ្រទ្រង់ជាហិរញ្ញវត្ថុ និងបច្ចេកទេសពីវិទ្យាស្ថានអភិវឌ្ឍន៍ក្រៅប្រទេស (Overseas Development Institute) និងធនាគារពិភពលោក វិទ្យាស្ថាន CDRI បានធ្វើការសិក្សា និងវាយតម្លៃលើផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុសាកលនៅកម្រិតម៉ាក្រូ (Jalilian *et al.* 2009) នៅតាមវិស័យនីមួយៗ (កសិកម្ម កាត់ដេរ ទេសចរណ៍ និងសំណង់) (Jalilian *et al.* 2009) នៅកម្រិតគ្រួសារ (Tong *et al.* forthcoming) និងកម្រិតបុគ្គល (Tong *et al.* 2009) ។ អត្ថបទនេះ បង្ហាញពីរបកគំហើញសំខាន់ៗ និងពិនិត្យមើលលើការឆ្លើយតបមួយចំនួនក្នុងពេលកន្លងមករបស់វិស័យសាធារណៈ ។

មានការទទួលស្គាល់ជាទូទៅថា សេដ្ឋកិច្ចកម្ពុជា បានទទួលរងឥទ្ធិពលធ្ងន់ធ្ងរពីវិបត្តិហិរញ្ញវត្ថុសាកល ជាពិសេសដោយសារការរួមចុះក្នុងវិស័យកាត់ដេរ ទេសចរណ៍ និង សំណង់ ។ នៅកម្ពុជា វិបត្តិនេះ ប៉ះពាល់ធ្ងន់ធ្ងរជាងគេដល់ឧស្សាហកម្មកាត់ដេរ ដោយក្នុងចំណោមកម្មករសរុប ៣៥២.០០០នាក់ មាន ១៨% (ភាគច្រើនជានារី) បានបាត់បង់ការងារ នៅចន្លោះខែកញ្ញា ២០០៨ និងខែឧសភា ២០០៩ ដោយសារការនាំចេញធ្លាក់ចុះខ្លាំង ។ យោងតាមវិទ្យាស្ថានជាតិស្ថិតិ វិស័យកាត់ដេរ ផ្តល់ការងារដល់ប្រមាណ ៤% នៃកំលាំងពលកម្មសរុប និងមានចំណែក ៣៨% ក្នុងការងារផ្នែកកម្មន្តសាលសរុបនៅឆ្នាំ២០០៧ ។

នៅឆមាសទី១ ឆ្នាំ២០០៩ ភ្ញៀវទេសចរមកដល់កម្ពុជា មានសរុប ១.០៨៦.៥១៨នាក់ គឺប្រហាក់ប្រហែលនឹងតួលេខនៅឆមាសទី១ ឆ្នាំ២០០៨ និងមានកំណើនប្រមាណ ១២% ពីខែមករា-មិថុនា ២០០៧ ។ ប៉ុន្តែវិស័យទេសចរណ៍ បានរួមចុះជាមធ្យមអស់ ៣,៩%ក្នុងមួយខែក្នុងរយៈពេល ៦ខែជាប់ៗគ្នា ពីខែតុលា ២០០៨ ដល់មីនា ២០០៩ ។ ជាលទ្ធផល អត្រាស្នាក់នៅតាមសណ្ឋាគារជាច្រើន មានកម្រិតទាប ដែលធ្វើឱ្យសណ្ឋាគារប្រណីតមួយចំនួន ត្រូវផ្អាកដំណើរការជាបណ្តោះអាសន្ន ហើយបុគ្គលិកសណ្ឋាគារ ក៏ត្រូវឈប់សំរាកដោយគ្មានប្រាក់បៀវត្សរ៍ ឬក៏បញ្ឈប់ជាបណ្តោះអាសន្នពីការងារ ។

ក្នុងពេលជាមួយគ្នា សកម្មភាពសំណង់ ក៏ត្រូវធ្លាក់ចុះជាខ្លាំងដែរ ដោយសារវិនិយោគិនបរទេសក្នុងវិស័យអចលនទ្រព្យ គេកាត់បន្ថយទំហំគម្រោង ឬពន្យារពេលគម្រោងសាងសង់ធំៗ ដោយសារវិបត្តិឥណទាននៅក្នុងប្រទេសដើមរបស់ពួកគេ ។

> **ភាពក្រីក្រមានភាគច្រើននៅជនបទ ដូច្នេះ គេគួរពិនិត្យជាសំខាន់ពីផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុសាកល ទៅលើសេដ្ឋកិច្ច និងកសិកម្មនៅជនបទ ។**

## ផលប៉ះពាល់នៃវិបត្តិទៅលើភាពក្រីក្រ

អត្រាប៉ាន់ស្មាននៃប្រជាជនក្រីក្រនៅឆ្នាំ២០០៧ គឺ ៣៥% នៅតំបន់ជនបទ ធៀបនឹង ០,៨% នៅរាជធានីភ្នំពេញ និង ២២% នៅក្រុងដទៃទៀត (World Bank 2009) ។ នៅឆ្នាំ២០០៧ ខ្សែបន្ទាត់ភាពក្រីក្រជារួមនៅតំបន់ជនបទកម្ពុជា មានកម្រិតស្មើនឹង ០,៥៨ដុល្លារ (World Bank 2009) ។ ផ្អែកលើខ្សែបន្ទាត់ភាពក្រីក្រអន្តរជាតិ ដែលមានអំណាចទិញស្មើគ្នា ក្នុងចំណោម ប្រជាជនកម្ពុជាសរុប ១៣,៨លាននាក់ មាន ៤០,២% រកចំណូលបានក្រោម ១,២៥ដុល្លារ/ថ្ងៃ ហើយ ៦៨,២% មានចំណូលក្រោម ២ដុល្លារ/ថ្ងៃ នៅឆ្នាំ២០០៤ (Bauer *et al.* 2008) ។ ដោយហេតុថា នៅកម្ពុជា ភាពក្រីក្រមានភាគច្រើននៅតំបន់ជនបទ ដែលមានកសិកម្មជាសកម្មភាពសេដ្ឋកិច្ចចំបង ដូច្នេះ គេគួរពិនិត្យជាសំខាន់ពីផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុសាកលទៅលើសេដ្ឋកិច្ច និងកសិកម្មនៅជនបទ ។

កសិកម្ម រួមចំណែកប្រហែល ២៧% នៃ ផសស នៅឆ្នាំ២០០៧ ហើយប្រជាជន ៥៩% ពឹងផ្អែកលើវិស័យនេះ ដើម្បីដោះស្រាយជីវភាពរស់នៅ ។ ក្នុងមួយទសវត្សរ៍កន្លងមក វិស័យកសិកម្មបានរីកលូតលាស់តាមអត្រាប្រចាំឆ្នាំ ៤,៦% ធៀបនឹង ១៣,១% សម្រាប់វិស័យសណ្ឋាគារ និងភោជនីយដ្ឋាន (សូចនាករតំណាងសម្រាប់វិស័យទេសចរណ៍) ២៥,៤%សម្រាប់ផ្នែកវាយនភ័ណ្ឌ សំលៀកបំពាក់ និងទ្រនាប់ជើង (សូចនាករតំណាងសម្រាប់វិស័យកាត់ដេរ) ១៣,៩% សម្រាប់វិស័យសំណង់ និង ៩,១% សម្រាប់សេដ្ឋកិច្ចទាំងមូល ។ គេរំពឹងថា វិស័យកសិកម្ម នឹងមានកំណើនខ្លាំងនៅឆ្នាំនេះ ហើយជួយប៉ះប៉ូវដល់ការធ្លាក់ចុះក្នុងវិស័យផ្សេងៗទៀត ពីព្រោះកសិកម្ម ទំនងជាមិនសូវប៉ះពាល់ខ្លាំងដោយសារវិបត្តិសេដ្ឋកិច្ចសាកលឡើយ (Jalilian *et al.* 2009) ។

ដើម្បីវាយតម្លៃពីផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុសាកលលើគ្រួសារនៅកម្ពុជា កាលពីខែឧសភា ២០០៩ វិទ្យាស្ថាន CDRI បានសហការជាមួយ

---

[1] អត្ថបទសង្ខេបគោលនយោបាយនេះ លោក តុង គឹមស៊ុន ជាអ្នកសំរបសំរួលកម្មវិធីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់ នៅ CDRI បានរៀបចំឡើងសម្រាប់សន្និសីទតំបន់អាស៊ី ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី ២៨-២៩ កញ្ញា ២០០៩ នៅទីក្រុងហាណូយ ប្រទេសវៀតណាម ។

ក្រាហ្វិក ១ : ខ្សែកោងនៃអត្រាភាពក្រីក្រសម្រាប់ខែមីនា ២០០៨ និង ឧសភា ២០០៩




*ប្រភព: អង្កេតរបស់ CDRI លើក្រុមគ្រួសារចំនួន ៩០ នៅក្នុងភូមិចំនួន ៩ រវាងខែមីនា ២០០៨ និង ឧសភា ២០០៩ ។*

ធនាគារពិភពលោក ដើម្បីធ្វើអង្កេតជាក្រុមលើប្រជាជនចំនួន ៩០គ្រួសារ នៅតំបន់ដែលបានធ្វើការសិក្សាពីឌីណាមិកនៃភាពក្រីក្រ ។ ទិន្នន័យដែលប្រមូលបានពី ៩ភូមិក្នុង ៧ខេត្ត កាលពីខែមីនា ២០០៨ និងខែឧសភា ២០០៩ បង្ហាញថា ចំណូល និងចំណាយក្នុងមនុស្សម្នាក់ បានធ្លាក់ចុះខ្លាំងក្នុងអំឡុងពេលនោះ ពោលគឺចំណូល បានធ្លាក់ចុះ ៣០% និងចំណាយ ធ្លាក់ចុះ ២៣% ។ ទំហំដីកសិកម្ម និងដីលំនៅដ្ឋាន មិនមានការប្រែប្រួលខ្លាំងទេ ប៉ុន្តែតម្លៃនៃទ្រព្យសកម្មក្រៅពីដីធ្លី បានធ្លាក់ចុះអស់ ៣៨% ទ្រព្យប្រើប្រាស់បានយូរ ធ្លាក់ចុះ ៣០% ហើយសត្វចិញ្ចឹម ធ្លាក់ចុះ ៤៥% ។ ជាលទ្ធផល នៅឆ្នាំ២០០៩ អត្រាភាពក្រីក្រ បានកើនឡើង ដោយកំណត់តាមខ្សែបន្ទាត់ភាពក្រីក្រស្មើនឹង ១ដុល្លារ[២] (ក្រាហ្វិក ១)[៣] ។

អង្កេតលើចំណូលប្រចាំថ្ងៃរបស់ពលករងាយរងគ្រោះ នៅរាជធានីភ្នំពេញ និងខេត្តពីរផ្សេងទៀត ដែល CDRI បានធ្វើជាច្រើនឆ្នាំមកហើយ បង្ហាញថា វិបត្តិហិរញ្ញវត្ថុសាកល បានប៉ះពាល់កម្មកររោងចក្រកាត់ដេរធ្ងន់ធ្ងរជាងគេ ព្រោះវិស័យកាត់ដេរពឹងផ្អែកខ្លាំងលើតំរូវការពីសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប[៤] ។ ចំណូលប្រចាំថ្ងៃពិតរបស់កម្មកររោងចក្រកាត់ដេរ បានធ្លាក់ចុះប្រហែល ១៧% បើធៀបកម្រិតកាលពីខែកុម្ភៈ-ឧសភា ២០០៧ និងកម្រិតខែកុម្ភៈ-ឧសភា ២០០៩ ដែលឆ្លុះបញ្ចាំងពីអត្រាប្រាក់កំរៃការងារថេរ ការកាត់បន្ថយចំនួនម៉ោងធ្វើការ និងអត្រាអតិផរណាខ្ពស់ ។ ទោះបីប្រាក់ចំណូលធ្លាក់ចុះក្តី ចំណាយប្រចាំថ្ងៃពិត បានកើនឡើង ១៤% ដែលអាចមកពីកំហុសក្នុងការវាស់វែង ឬការជ្រើសយកគំរូតាង ។ ក្នុងពេលដំណាលគ្នា ប្រាក់សន្សំប្រចាំថ្ងៃពិត បានធ្លាក់ចុះ ២១% ។ ប្រាកដណាស់ ចំណាយប្រចាំថ្ងៃរបស់កម្មកររោងចក្រកាត់ដេរ មិនអាចនៅថេរឡើយ ប្រសិនបើចំណូល និងប្រាក់សន្សំប្រចាំថ្ងៃរបស់ពួកគេ បន្តធ្លាក់ចុះនោះ ។

អង្កេតបានបង្ហាញផងដែរថា ចំនួនចារិកនៃប្រាក់ផ្ញើមកផ្ទះប្រចាំខែជាមធ្យមរបស់កម្មកររោងចក្រកាត់ដេរ បានធ្លាក់ចុះ ៣២% ពី ២៤,៤០ដុល្លារ នៅខែកុម្ភៈ មកត្រឹម ១៨,៤០ដុល្លារនៅខែឧសភា ២០០៩ ។ ការធ្លាក់ចុះគួរឱ្យកត់សំគាល់នៃប្រាក់ផ្ញើមកផ្ទះនេះ បានដាក់សម្ពាធធ្ងន់ធ្ងរលើជីវភាពរស់នៅរបស់សាច់ញាតិពួកគេ ។

វិបត្តិហិរញ្ញវត្ថុសាកល បានប៉ះពាល់លើកម្មករ ៩ក្រុមទៀត តិចជាងកម្មកររោងចក្រកាត់ដេរ ។ គួរកត់សំគាល់ដែរថា អង្កេតនេះ បានជ្រើសយកតែពលករដែលមានការងារធ្វើ ឬប្រកបអាជីវកម្មដោយខ្លួនឯង ដូច្នេះ លទ្ធផលអង្កេត មិនអាចឆ្លុះបញ្ចាំងពីស្ថានភាពរបស់ពលករជាទូទៅបានទេ ។

ការពិភាក្សាតាមក្រុមស្នូល ដែលធ្វើឡើងនៅខេត្តសៀមរាប កាលពីខែឧសភា ២០០៩ បានបង្ហាញថា ពលករក្នុងវិស័យទេសចរណ៍ ជាពិសេសពលករនៅតាមសណ្ឋាគារ និងភោជនីយដ្ឋាន បានរងផលប៉ះពាល់ ដោយសារការថយចុះភ្ញៀវទេសចរ ។ បុគ្គលិកមួយចំនួន ត្រូវជំរុញឱ្យឈប់សំរាកដោយគ្មានបៀវត្សរ៍ ឬបញ្ឈប់ពីការងារជាបណ្តោះអាសន្ន ដូច្នេះ ក៏ត្រូវតែទៅរកការងារក្រៅផ្លូវការផ្សេងៗធ្វើ ដូចជា បើករថយន្តតាក់ស៊ី ឬបង្រៀនភាសាអង់គ្លេសក្រៅម៉ោង ជាដើម ។ ចលនាកំលាំងពលកម្មបែបនេះ បានធ្វើឱ្យអ្នកបើករថយន្តតាក់ស៊ី និងអ្នកលក់ដូរតូចតាច ត្រូវខំប្រឹងធ្វើការកាន់តែខ្លាំងក្នុងពេលតំរូវការកំពុងមានតិចនេះ ។

២ ខ្សែបន្ទាត់ភាពក្រីក្រនៅឆ្នាំ២០០៧ គឺប្រហែល ២០០៦រៀល ស្មើនឹង ០,៤៩ដុល្លារ ដោយប្រើអត្រាប្តូរប្រាក់ ៤០៦៣រៀល/ដុល្លារ (World Bank 2009) ។

៣ ទោះយ៉ាងណាក្តី គំរូតាងដែលជ្រើសរើសយកមកសិក្សាមានទំហំតូច ហើយមិនអាចយកមកតំណាងឱ្យក្រុមគ្រួសារទាំងអស់បានឡើយ ។

៤ តាំងពីឆ្នាំ២០០០ មក CDRI បានធ្វើអង្កេតរៀងរាល់ត្រីមាស លើពលករងាយរងគ្រោះចំនួន ១០ក្រុម ដែលរួមមាន: អ្នកធាក់ស៊ីក្លូ អ្នកលីសែង អ្នកលក់បន្លែតូចតាច អ្នករើសអេតចាយ អ្នករត់ម៉ូតូឌុប កម្មករសំណង់គ្មានជំនាញ កម្មករសំណង់មានជំនាញ អ្នកបំរើតុភោជនីយដ្ឋាន កម្មកររោងចក្រកាត់ដេរ និងអ្នកស៊ីឈ្នួលធ្វើស្រែ ។

តារាង ១: យុទ្ធសាស្ត្រផ្សេងៗរបស់ក្រុមគ្រួសារទទួលរងផលប៉ះពាល់ពីវិបត្តិ

| | ភាគរយនៃគ្រួសារ | |
|---|---|---|
| | ខែមីនា ២០០៨ | ខែឧសភា ២០០៩ |
| យុទ្ធសាស្ត្រសម្របខ្លួន [i] | 3.13 | 5.56 |
| យុទ្ធសាស្ត្រសកម្ម | 81.25 | 94.4 |
| យុទ្ធសាស្ត្របណ្តាញសង្គម [ii] | 2.5 | 13.8 |

i. ការផ្លាស់ប្តូរលំនាំចំណាយ

ii.ជំនួយពី មិត្តភក្តិ គ្រួសារ អង្គការមិនមែនរដ្ឋាភិបាល និង អង្គការរដ្ឋ ។

*ប្រភព: អង្កេតរបស់ CDRI លើ ៩០គ្រួសារ ក្នុង ៩ភូមិនៅជនបទ កាលពីខែមីនា ២០០៨ និងខែឧសភា ២០០៩ ។*

## យន្តការដោះស្រាយរបស់ប្រជាជនក្រីក្រ និងជនងាយរងគ្រោះ

ទិន្នន័យបានពីអង្កេតជាក្រុម បង្ហាញថា ប្រមាណ ៣៥% នៃក្រុមគ្រួសារដែលជ្រើសរើសធ្វើអង្កេតនៅឆ្នាំ២០០៨ និង ៤០% នៅឆ្នាំ២០០៩ បានទទួលរងការប៉ះទង្គិច ជាពិសេសការប៉ះទង្គិចខុសពីធម្មតា ។ ក្រុមគ្រួសារដែលរងផលប៉ះពាល់ រាយការណ៍ថា បានចំណាយជាមធ្យម ១៩៨ដុល្លារក្នុងមួយគ្រួសារ ដើម្បីទប់ទល់នឹងការប៉ះទង្គិចនេះ ក្នុងនេះ មានជាង ៨០% បានសម្របខ្លួនទ្រាំទ្រនឹងស្ថានភាព ដោយអនុវត្តយុទ្ធសាស្ត្រសកម្មរបស់គ្រួសារ តាមរយៈការប្រើប្រាស់ទ្រព្យរូបវ័ន្ត ហិរញ្ញវត្ថុ និងធនធានមនុស្ស ដូចជា ការដាក់បញ្ចូលសមាជិកគ្រួសារថែមទៀតទៅក្នុងកំលាំងពលកម្ម ការធ្វើការច្រើនម៉ោងជាងមុន លក់ទ្រព្យសម្បត្តិ ប្រើប្រាស់ប្រាក់សន្សំ ខ្ចីបុលគេ និងធ្វើចំណាកស្រុករកការងារ (តារាង ១) ។ ប៉ុន្តែមិនមានភស្តុតាងជាក់លាក់ណាមួយបង្ហាញថា យុទ្ធសាស្ត្របែបនេះ (ជាពិសេស ការលក់ដី ទ្រព្យសម្បត្តិក្រៅពីដី និងសត្វចិញ្ចឹម) ត្រូវបានប្រើប្រាស់ ដើម្បីឆ្លើយតបនឹងវិបត្តិឡើយ ។

កំរងទិន្នន័យមួយផ្សេងទៀត ដែលប្រមូលបានពីអង្កេតលើ ១០០៣ គ្រួសារ ក្នុង ៩ភូមិដដែលនេះ នៅខែមីនា និងខែកញ្ញា ២០០៨ បង្ហាញកាន់តែច្បាស់ពីយន្តការដោះស្រាយរបស់គ្រួសារនានា ក្នុងអំឡុងពេលម្ហូបអាហារឡើងថ្លៃ។ ដូចមានបង្ហាញក្នុងតារាង ២ ចំណាយលើទំនិញមិនមែនអាហារបានធ្លាក់ចុះ ២០% ពីខែមីនា ដល់ខែកញ្ញា ២០០៨[៥] ស្របពេលដែលចំណាយលើស្បៀងអាហារ ធ្លាក់ចុះតែ ១១% ។ ទោះបីទឹកប្រាក់ចំណាយលើម្ហូបអាហារ បានធ្លាក់ចុះក៏ពិតមែន ប៉ុន្តែភាគរយនៃចំណាយលើស្បៀងនៅក្នុងចំណាយសរុបប្រចាំគ្រួសារ នៅថេរដដែល ដែលបង្ហាញថា គ្រួសារទាំងនោះបានរឹតត្បិតចំណាយលើទំនិញមិនមែនអាហារ ដើម្បីយកមកទប់ចំណាយលើស្បៀងអាហារ ។

ទោះជាករណីសិក្សាផ្សេងៗគ្នា ផ្តល់ការសន្និដ្ឋានខុសៗគ្នាក៏ដោយ ក៏វាបានផ្តល់ខ្លឹមសាររួមមួយ គឺគ្រួសារនៅតាមតំបន់ជនបទកម្ពុជា ច្រើនតែអាចដោះស្រាយផលប៉ះពាល់នៃវិបត្តិដោយខ្លួនឯងបាន តាមរយៈការកែសំរួលសកម្មភាព និងការចំណាយរបស់ខ្លួន និងការប្រើប្រព័ន្ធសុវត្ថិភាពសហគមន៍មិនមែនផ្លូវការផ្សេងៗ ដែលតែងតែថយចុះខ្លះ ក្នុងគ្រាលំបាកលំបិន ។

## ការឆ្លើយតបជាគោលនយោបាយរបស់រដ្ឋាភិបាល

ដើម្បីឆ្លើយតបនឹងវិបត្តិសេដ្ឋកិច្ចសាកល រដ្ឋាភិបាល បានដាក់ចេញគោលនយោបាយមួយចំនួន រួមមាន:

៥ អតិផរណា ឡើងដល់ ២៦% នៅក្នុងខែឧសភា ២០០៨ ដែលជាអត្រាខ្ពស់បំផុតក្នុង ៣ទសវត្សរ៍កន្លងមកនេះ ។

តារាង ២ : បញ្ចភាគចំណាយប្រើប្រាស់ពិតក្នុងមនុស្សម្នាក់ (ជាដុល្លារ)

| បញ្ចភាគ | ចំណាយសរុប | | អាហារ | | មិនមែនអាហារ | | ចំណាយសរុប | អាហារ | មិនមែនអាហារ |
|---|---|---|---|---|---|---|---|---|---|
| | មីនា-០៨ | កញ្ញា-០៨ | មីនា-០៨ | កញ្ញា-០៨ | មីនា-០៨ | កញ្ញា-០៨ | % ផ្លាស់ប្តូរ មីនា-កញ្ញា ០៨ | % ផ្លាស់ប្តូរ មីនា-កញ្ញា ០៨ | % ផ្លាស់ប្តូរ មីនា-កញ្ញា ០៨ |
| ១ (ទាបបំផុត) | 0.53 | 0.48 | 0.42 | 0.38 | 0.11 | 0.10 | -9.04 | -8.99 | -9.26 |
| ២ | 0.71 | 0.64 | 0.55 | 0.49 | 0.16 | 0.14 | -10.45 | -10.09 | -11.64 |
| ៣ | 0.85 | 0.76 | 0.65 | 0.58 | 0.20 | 0.18 | -10.41 | -10.88 | -8.86 |
| ៤ | 1.07 | 0.92 | 0.76 | 0.68 | 0.31 | 0.24 | -13.68 | -10.79 | -20.86 |
| ៥ (ខ្ពស់បំផុត) | 1.86 | 1.51 | 0.98 | 0.85 | 0.88 | 0.66 | -18.94 | -13.21 | -25.29 |
| សរុប | 0.97 | 0.86 | 0.67 | 0.60 | 0.33 | 0.26 | -11.38 | -11.16 | -20.06 |

*ប្រភព: ទិន្នន័យបានពីអង្កេតរបស់ CDRI ក្នុង ៩ភូមិ នៅខែមីនា និងខែកញ្ញា ២០០៨ និងខែកញ្ញា ២០០៩ ។*

- បង្កើនចំណាយថវិកា ដើម្បីប៉ះប៉ូវការធ្លាក់ចុះវិនិយោគឯកជន (ដើម្បីជំរុញសកម្មភាពសេដ្ឋកិច្ច) ។
- ផ្អាកការយកពន្ធលើផលរបរប្រចាំខែ១% លើការចំណាយរបស់រោងចក្រកាត់ដេរ ។
- កាត់បន្ថយ ១០% លើប្រាក់កំរៃគ្រប់គ្រងការនាំចេញ និងបន្ទុកចំណាយផ្សេងៗ ។
- បង្កើតមូលនិធិអភិវឌ្ឍន៍ និងទ្រទ្រង់កសិកម្ម សម្រាប់វិស័យឯកជនជាពិសេសសម្រាប់សហគ្រាសខ្នាតតូច និងមធ្យម ដោយផ្ដល់ឥណទានរយៈពេលខ្លី និងមានការប្រាក់ទាបទៅឱ្យកសិករ ដើម្បីបង្កើនផលិតភាពកសិកម្ម និងសន្តិសុខស្បៀង ។
- បង្កើតមូលនិធិពិសេសរបស់សម្ដេចនាយករដ្ឋមន្ត្រី ដើម្បីផ្ដល់ការបណ្ដុះបណ្ដាលវិជ្ជាជីវៈរយៈពេលខ្លីដល់កម្មករដែលបាត់បង់ការងារ ។ រហូតមកដល់ខែកក្កដា ២០០៩ មានកម្មករត្រូវបានបញ្ឈប់ពីការងារ និងមិនមានការងារធ្វើ ចំនួន ៤០.១៤០នាក់ ដែលបានទទួលការបណ្ដុះបណ្ដាលបែបនេះផ្ដល់ដោយក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ក្នុងនោះ មាន ៣០.៧២០នាក់ (៧៦,៥%) បានទទួលការបណ្ដុះបណ្ដាលខាងកសិកម្ម និង ៩៤២០នាក់ទៀត (២៣,៥%) ខាងឧស្សាហកម្ម និងគ្រឿងយន្ត ។
- ចរចាជាមួយធនាគារពិភពលោក ទាក់ទងនឹងការផ្ដល់ហិរញ្ញប្បទានប្រមាណ ១៣លានដុល្លារ សម្រាប់កម្មវិធីផ្សេងៗ ពាក់ព័ន្ធនឹងប្រព័ន្ធសុវត្ថិភាពសង្គម ។

ទោះមានចំណាត់ការដូចខាងលើក្ដី ក៏មានការទទួលស្គាល់ជាទូទៅថាវិធានការទាំងនេះ ទំនងមិនអាចជះឥទ្ធិពលទៅដល់ប្រជាជនក្រីក្រ និងជនងាយរងគ្រោះនៅតាមតំបន់ជនបទ ឬទីក្រុងឡើយ ។

## អនុសាសន៍សម្រាប់រយៈពេលខ្លី និងមធ្យម

តួនាទីដែលអ្នកកសាងគោលនយោបាយ ម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាលទទួលអនុវត្ត អាចកំណត់បាននូវផលប៉ះពាល់ពិតប្រាកដនៃវិបត្តិទៅលើកំណើន និងភាពក្រីក្រនៅកម្ពុជា ។ ផលប៉ះពាល់ទំនងមានលក្ខណៈធ្ងន់ធ្ងរលើក្រុមប្រជាជនក្រីក្រ និងជនងាយរងគ្រោះ ។ ដោយសារស្ថានភាពសេដ្ឋកិច្ច និងឋានៈសង្គមរបស់ខ្លួន ពួកគេទំនងត្រូវរងគ្រោះមុនគេពីការប៉ះទង្គិច ដូចជា ត្រូវបាត់បង់ការងារ និងចំណូល ឬថយចុះអំណាចទិញ ដោយសារទំនិញឡើងថ្លៃ (Jalilian *et al*. 2009) ។ ដោយសារជនក្រីក្រ និងជនងាយរងគ្រោះ មានចំនួនច្រើននៅកម្ពុជា ដូច្នេះ ត្រូវផ្ដល់សារៈសំខាន់ដល់គោលនយោបាយសម្រាប់ជួយដល់ពួកគេ ។ នៅក្នុងប្រទេសមួយចំនួន ប្រជាជនក្រីក្រ និងជនងាយរងគ្រោះ តែងទទួលបានជំនួយ (ដោយផ្ទាល់ ឬដោយប្រយោល) ពីរដ្ឋាភិបាល ម្ចាស់ជំនួយ និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងពេលជួបការលំបាកខ្លាំង ។ ជំនួយទាំងនោះ អាចជាសម្ភារៈ ឬឧបត្ថម្ភធនជួយចេញខាតលើថ្លៃទំនិញ របបអាហារ ប័ណ្ណអាហារ ស្បៀងពលកម្ម ការផ្ដល់អាហារតាមសាលារៀន ជាដើម ។

វិបត្តិ មិនគ្រាន់តែនាំឱ្យមានបំរែបំរួលខ្លាំងក្នុងកម្រិតជីវភាពប្រជាជនប៉ុណ្ណោះទេ ប៉ុន្តែកង្វះខាតមធ្យោបាយសម្រាប់ទប់ទល់នឹងហានិភ័យ ធ្វើឱ្យភាពក្រីក្រតោកយ៉ាកនៅអូសបន្លាយយូរអង្វែង ។ ដូច្នេះ យុទ្ធសាស្ត្រសម្រាប់ដោះស្រាយនៅមុនពេល និងក្រោយពេលមានវិបត្តិ ដូចជា ការជំរុញឥណទានប្រាក់សន្សំទុកការពារខ្លួន ព្រមទាំងប្រព័ន្ធសុវត្ថិភាពសង្គម ដែលអាចជឿទុកចិត្តបាន អាចដើរតួនាទីយ៉ាងសំខាន់ក្នុងការការពារប្រជាជនក្រីក្រ និងជនងាយរងគ្រោះ ។ម្យ៉ាងវិញទៀត គួរយកចិត្តទុកដាក់ពង្រឹងប្រព័ន្ធធានារ៉ាប់រងសង្គមក្រៅផ្លូវការ ពីព្រោះក្រុមប្រជាជនក្រីក្រ និងជនងាយរងគ្រោះ អាចប្រើប្រាស់មូលធនសង្គមនៅក្នុងមូលដ្ឋានរបស់ខ្លួន ដើម្បីការពារចំណាយប្រើប្រាស់របស់ខ្លួន នៅពេលប្រាក់ចំណូលមានការឡើងចុះ ។

## សេចក្ដីសន្និដ្ឋាន

វិបត្តិសេដ្ឋកិច្ចសាកល មានផលប៉ះពាល់ធ្ងន់ធ្ងរទៅលើប្រជាជនក្រីក្រ និងជនងាយរងគ្រោះ ទាំងនៅជនបទ និងនៅទីក្រុង ។ វិបត្តិហាក់ដូចបានប៉ះពាល់ជនក្រីក្រភ្លាមៗតាមរយៈស្ថានភាពការងារ និងចំនួនប្រាក់ផ្ញើមកផ្ទះ ហើយការប៉ះពាល់នេះ ទំនងជាកាន់តែធ្ងន់ធ្ងរថែមទៀតក្នុងរយៈពេលមធ្យម ដោយសារតែភាពអន់ខ្សោយនៃយុទ្ធសាស្ត្រសម្រាប់ដោះស្រាយ នៅមុនពេល និងក្រោយពេលមានវិបត្តិ ប្រព័ន្ធធានារ៉ាប់រងសង្គមក្រៅផ្លូវការ ក៏ដូចជា កង្វះការឆ្លើយតបរបស់វិស័យសាធារណៈ ។

រដ្ឋាភិបាល គួរតែអាចលើកកំពស់ប្រព័ន្ធធានារ៉ាប់រងសម្រាប់ជនក្រីក្រ តាមរយៈការបង្កើតក្របខ័ណ្ឌច្បាប់សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងការជួយពង្រឹងប្រព័ន្ធសុវត្ថិភាពសង្គមឱ្យមានលក្ខណៈអាចជឿទុកចិត្តបាន ។

## ប្រភព:

Bauer, Armin, Rana Hasan, Rohoda Magsombol & Guanghua Wan (2008), *The World Bank's New Poverty Data: Implications for the Asian Development Bank*, ADB Sustainable Development Working Paper Series (Manila: ADB)

Jalilian, Hossein, Chan Sophal, Glenda Reyes, Siang Chan Hang, Phann Dalis & Pon Dorina (2009), *The Global Financial Crisis and Developing Countries: Cambodia* (Phnom Penh: CDRI)

Tong Kimsun, Siang Chanhang & Hem Socheth with Phann Dalis, Hem Metta & Pon Dorina (forthcoming), *Trends in Living Standards of 90 Rural Households in Poverty Dynamics Study Villages* (Phnom Penh: CDRI)

Tong Kimsun, Khieng Sothy & Phann Dalis with Hem Metta & Pon Dorina (2009), *Vulnerable Workers Survey in Phnom Penh, Kandal, Kompong Speu, Siem Reap and Battambang*. (Phnom Penh: CDRI)

World Bank (2009), *Poverty Estimates for Cambodia 2007: Report to the EAS Country Units of the World Bank Washington DC*

# ការវិភាគពីរដ្ឋកម្ពុជាក្នុងលក្ខណៈ ជារដ្ឋជំរុញអភិវឌ្ឍន៍[១]

តើប្រទេសកម្ពុជាបច្ចុប្បន្ន គឺជារដ្ឋជំរុញអភិវឌ្ឍន៍មែនឬទេ? នេះជាសំនួរមួយធំធេង ដែលត្រូវទទួលការបំភ្លឺពីកម្មវិធីស្រាវជ្រាវមួយមានរយៈពេល ២ឆ្នាំ ។ ជិតពីរទសវត្សរ៍ក្រោយការបញ្ចប់សង្គ្រាមស៊ីវិល[២] និងក្រោយពេលកសាងបានឡើងវិញនូវស្ថិរភាព សណ្តាប់ធ្នាប់សង្គម និងកំណើនសេដ្ឋកិច្ចខ្ពស់គួរឱ្យកត់សម្គាល់ រដ្ឋាភិបាលកម្ពុជា បានប្រកាសខ្លួនឯងថាជា រដ្ឋជំរុញអភិវឌ្ឍន៍ (ផ្នែកសេដ្ឋកិច្ច) ។ ប៉ុន្តែមានមតិជំទាស់មួយចំនួនថា រដ្ឋនៅទន់ខ្សោយនៅឡើយ មានដំណើរការមិនទាន់រៀបរយ និងមានលក្ខណៈជាប្រព័ន្ធខ្សែខ្នង (Öjendal and Lilja 2009; Hughes and Un, forthcoming; Pak *et la.* 2007; Kim, forthcoming) ។ កន្លងមក មានការសិក្សាជាច្រើនដែលបានបកស្រាយដោយចោះៗពីលក្ខណៈដូចខាងលើ ប៉ុន្តែនៅមិនទាន់មានការសិក្សាណាមួយដែលផ្តោតចំលើប្រទេសកម្ពុជាក្នុងលក្ខណៈជារដ្ឋជំរុញអភិវឌ្ឍន៍នោះទេ ។

**តើរដ្ឋកម្ពុជា នឹងចាប់យកមាគ៌ាអភិវឌ្ឍន៍ពិតប្រាកដ ឬក៏ផ្លូវផ្សេង ជាពិសេសនៅចំពោះមុខប្រាក់ចំណូលដ៏ច្រើនសន្ធឹកសន្ធាប់ពីធនធានរ៉ែ និងប្រេងកាត ដែលទំនងនឹងទទួលបាននាពេលឆាប់ៗ ?**

ចាប់ពីដើមទសវត្សរ៍១៩៨០ ដល់ដើមទសវត្សរ៍១៩៩០ អ្នកនិយមរបបសេរីបែបថ្មី បានជំដែកវែកញែកឱ្យមានការកាត់បន្ថយតួនាទីរបស់រដ្ឋ និងការដើរតាមកំលាំងទីផ្សារ (Thorbecke 2007; Fukuyama 2004) ។ ប៉ុន្តែបរាជ័យ និងកំហិតកំណត់នៃឯកជនភាវូបនីយកម្មក្នុងប្រទេសកំពុងអភិវឌ្ឍន៍ កង្វះសមត្ថភាព និងដែនឥទ្ធិពលតូចរបស់រដ្ឋ (អន្តរាគមន៍ និងលទ្ធភាពលូកដៃចូលទីផ្សារ) ដើម្បីជួយទ្រទ្រង់ទីផ្សារ មិនបានជួយជំរុញឱ្យមាន កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងសមធម៌ឡើយ ។ លំនាំគំនិតថ្មីដែលផ្តល់សារៈសំខាន់ និងភាពចាំបាច់ដល់សមត្ថភាពរបស់រដ្ឋ និងគុណភាពស្ថាប័ន ដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ច បានរីកលូតលាស់កាន់តែខ្លាំង ចាប់ពីដើមទសវត្សរ៍១៩៩០ (Fukuyama 2004) ។ លំនាំគំនិតថ្មីនេះ វាសមស្របល្អ នៅពេលមានកង្វះអន្តរាគមន៍ពីរដ្ឋ (បទបញ្ញត្តិគ្រប់គ្រងទីផ្សារ និងការពង្រឹងអនុវត្ត) ដូចក្នុងករណីសហរដ្ឋអាមេរិកដែលត្រូវគេបន្ទោសថា ជាដើមហេតុនៃការផ្ទុះវិបត្តិសេដ្ឋកិច្ចសាកលលោកនាពេលថ្មីៗ ។ ជាប្រតិកម្មក្នុងរឿងនេះ គេឃើញមានសំណើឱ្យបំផុសឡើងវិញនូវអន្តរាគមន៍របស់រដ្ឋក្នុងសេដ្ឋកិច្ច ទាំងសម្រាប់រដ្ឋាភិបាលដែលប្រកាន់ជំហរបណ្តោយតាមកំលាំងទីផ្សារ ដូចនៅសហរដ្ឋអាមេរិកក្តី ។ ដូចគ្នាដែរ ចម្លើយតបយ៉ាងស័ក្តិសិទ្ធិរបស់រដ្ឋាភិបាលចិនចំពោះវិបត្តិនេះ បានបញ្ជាក់គាំទ្រពីប្រសិទ្ធភាពគំរូអភិវឌ្ឍន៍ដឹកនាំដោយរដ្ឋសម្រាប់ដោះស្រាយការរីករវើផ្នែកហិរញ្ញវត្ថុ ដោយរក្សាបាននូវកំណើនសេដ្ឋកិច្ច ។ ដូច្នេះ ដល់ពេលវេលាដែល ត្រូវរើសយកមកប្រើសាជាថ្មីនូវគោលគំនិត "ឱ្យរដ្ឋចូលមកពាក់ព័ន្ធវិញ" (Skocpol 1985) ។

ដោយទទួលស្គាល់ពីភាពចាំបាច់ និងប្រសិទ្ធភាពនៃការអភិវឌ្ឍដែលដឹកនាំដោយរដ្ឋនោះ អង្គភាពចំនួនបីនៅ CDRI គឺមានផ្នែកអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងកំណែទម្រង់វិស័យសាធារណៈ ផ្នែកសេដ្ឋកិច្ច ពាណិជ្ជកម្ម និងកិច្ចសហប្រតិបត្តិការក្នុងតំបន់ និងផ្នែកភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ បានរួមគ្នាផ្តួចផ្តើមគំនិតបង្កើតកម្មវិធីស្រាវជ្រាវនេះឡើង ដើម្បីស្វែងយល់ពីរដ្ឋកម្ពុជា ។

កម្មវិធីស្រាវជ្រាវនេះ មានគោលដៅចំបងពិនិត្យពីលក្ខណៈនៃរដ្ឋកម្ពុជាទាំងក្នុងទស្សនវិស័យបែបប្រៀបធៀប និងបែបប្រវត្តិសាស្ត្រ ដោយធ្វើការពិចារណាលើគំរូខុសៗគ្នានៃរដ្ឋដូចមានបង្ហាញនៅខាងក្រោម ដើម្បីចូលរួមចំណែកដល់ការសិក្សាបែបទ្រឹស្តីអំពីរដ្ឋកម្ពុជា ។ ដោយឡែក ការសិក្សាព្យាយាមឆ្លើយនឹងសំនួរសំខាន់ៗមួយចំនួនដូចជាៈ តើរដ្ឋកម្ពុជាមានប្រសិទ្ធភាពប៉ុណ្ណាក្នុងក្របខ័ណ្ឌជារដ្ឋជំរុញអភិវឌ្ឍន៍? ទាក់ទិននឹងសមត្ថភាពរដ្ឋ តើរដ្ឋមានចំណុចខ្លាំងអ្វីខ្លះ? តើរដ្ឋកម្ពុជា មានស្វ័យភាពប៉ុណ្ណាពាក់ព័ន្ធនឹងវណ្ណៈផ្សេងៗក្នុងសង្គម (វណ្ណៈគ្រប់គ្រង)? តើរដ្ឋលូកដៃចូលក្នុងសេដ្ឋកិច្ចបានកម្រិតណា?

## ហេតុផលត្រូវធ្វើការស្រាវជ្រាវ

Hughes and Un (បោះពុម្ពផ្សាយក្នុងពេលខាងមុខ) អះអាងថា ប្រទេសកម្ពុជា បានងើបផុតពីសម័យក្រោយជម្លោះ និងឈានចូលទៅក្នុងដំណាក់កាលថ្មីនៃការផ្លាស់ប្តូរសេដ្ឋកិច្ច ។ ការសិក្សានេះ មានគោលដៅពិនិត្យឱ្យបានឆ្ងាយជាងការសិក្សារបស់ Hughes and Un ដោយចង់បង្ហាញយ៉ាងពិស្តារពីចរិតលក្ខណៈជាមូលដ្ឋាននៃរដ្ឋកម្ពុជា និងប្រមើលមើលពីទិសដៅដែលរដ្ឋកំពុងឈានទៅរក គឺថា តើរដ្ឋកម្ពុជា នឹងចាប់យកមាគ៌ាអភិវឌ្ឍន៍

១ ដោយលោក អ៊ូ ស៊ីវហួច លោក លន់ ពិដេ លោក ឃៀង សុធី និងកញ្ញា អ៊ូច ច័ន្ទតារ៉ានី (អ្នកស្រាវជ្រាវ នៃ CDRI) ដោយមានការជួយណែនាំ និងត្រួតពិនិត្យពីលោក គីម សេតារា (អ្នកស្រាវជ្រាវ នៃវិទ្យាស្ថាន CDRI) និងបណ្ឌិត អ៊ុន ឃាង (ជំនួយការសាស្ត្រាចារ្យនៅសាកលវិទ្យាល័យ Northern Illinois) ។ អត្ថបទនេះជាសេចក្តីសង្ខេបនៃឯកសារគោលគំនិតសម្រាប់កម្មវិធីរដ្ឋជំរុញអភិវឌ្ឍន៍ ដែលបានចាប់ផ្តើមឡើងពីត្រីមាសទី៤ ឆ្នាំ២០០៩ និងគ្រោងបញ្ចប់នៅពាក់កណ្តាលឆ្នាំ២០១១ ។ ឯកសារនេះ មានគោលដៅចំបងណែនាំកម្មវិធីនេះដល់បុគ្គលគោលដៅ ដូចជា អ្នកកសាងគោលនយោបាយ សហគមន៍ផ្តល់ជំនួយ អ្នកសិក្សា និងក្រុមសង្គម ស៊ីវិល ព្រមទាំងវិស័យឯកជន ។

២ សង្គ្រាមស៊ីវិល បានបញ្ចប់អស់នៅក្នុងឆ្នាំ១៩៩៨ នៅពេលដែលភាគីខ្មែរក្រហម បានធ្វើសមាហរណកម្មពេញលេញជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា ។

ពិតប្រាកដ ឬក៏ផ្លូវផ្សេង ជាពិសេសនៅចំពោះមុខប្រាក់ចំណូលដ៏ច្រើនសន្ធឹកសន្ធាប់ពីធនធានរ៉ែ និងប្រេងកាត ដែលទំនងនឹងទទួលបាននាពេលឆាប់ៗ ។ តាមការពិនិត្យឃើញជាក់ស្ដែងកន្លងមក អ្នកកសាងគោលនយោបាយរបស់រដ្ឋាភិបាល អ្នកផ្ដល់ជំនួយ ពាណិជ្ជករថ្នាក់ខ្ពស់ តួអង្គសង្គមស៊ីវិល និងសូម្បីតែអ្នកសិក្សាទៀតសោត ក៏ខ្វះខាតការយល់ដឹងពីលទ្ធផលការស្រាវជ្រាវដ៏សំខាន់ៗទាំងនេះដែរ ។ ការសិក្សានេះ នឹងជួយបំពេញចន្លោះខ្វះខាតទាំងនេះ ទាំងផ្នែកទ្រឹស្ដី និងការអនុវត្ត ។ ជាងនេះទៅទៀត ការសិក្សានឹងបង្ហាញថា តើបុគ្គលណាត្រូវធ្វើអ្វីខ្លះ ដើម្បីធានាឱ្យកម្ពុជាអាចចាប់យកមាគ៌ាអភិវឌ្ឍន៍ដ៏ត្រឹមត្រូវ ។ យើងក៏មានបំណងពិនិត្យមើលលើបទពិសោធន៍អភិវឌ្ឍន៍នៃប្រទេសផ្សេងៗ និងជ្រើសរើសមេរៀនល្អៗដែលសមស្របសម្រាប់បរិបទកម្ពុជា ។

## ការធ្វើផែនការស្រាវជ្រាវ

ដើម្បីសម្រេចបានតាមកម្មវត្ថុនៃកម្មវិធីខាងលើ យើងបានរៀបចំការសិក្សានេះជាបីដំណាក់កាលៈ

- ការវិភាគពីរដ្ឋកម្ពុជាៈ តើជារដ្ឋជំរុញអភិវឌ្ឍន៍ មែនឬទេ?
- រដ្ឋ និងការយកពន្ធនៅកម្ពុជា
- រដ្ឋ និងគោលនយោបាយកសិកម្មនៅកម្ពុជា

គម្រោងទី១ នឹងវិភាគពីចរិតលក្ខណៈនៃរដ្ឋកម្ពុជាដោយប្រើប្រភេទផ្សេងៗផ្អែកតាមទ្រឹស្ដីនៃរដ្ឋ ដូចមានបង្ហាញនៅខាងក្រោម ។ គម្រោងនេះ ក៏នឹងពិនិត្យពីសមាសធាតុសំខាន់ៗ ដូចជា សមត្ថភាព ស្វ័យភាព និងដែនឥទ្ធិពលរបស់រដ្ឋ ។ គម្រោងពីរទៀត គឺជាករណីសិក្សាជាក់ស្ដែងពីចំណុចខ្លាំង និងចំណុចខ្សោយរបស់រដ្ឋ ។ គម្រោងនីមួយៗនឹងបញ្ចប់ ដោយមានការបោះពុម្ពផ្សាយជាឯកសារពិភាក្សាដោយវិទ្យាស្ថាន CDRI ។ ដើម្បីជំរុញឥទ្ធិពល និងការផ្សព្វផ្សាយរបកគំហើញនៃការស្រាវជ្រាវ យើងនឹងប្រឹងប្រែងកសាងជាឯកសារខ្លីៗសម្រាប់ចុះផ្សាយនៅក្នុងព្រឹត្តបត្រ និងសៀវភៅថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ ។

ផ្នែកបន្ទាប់ នឹងរៀបរាប់លំអិតថែមទៀតពីប្រវត្តិនៃការសិក្សា និងពិភាក្សាពីប្រភេទខុសៗគ្នានៃគំរូរដ្ឋដែលនឹងត្រូវយកមកប្រើ ដើម្បីអង្កេតលើចរិតលក្ខណៈនៃរដ្ឋកម្ពុជា ។ ការសិក្សានេះ ក៏បង្ហាញនូវការរែកញែកមួយចំនួនអំពីទំនាក់ទំនងជិតស្និទ្ធរវាងសមត្ថភាពរដ្ឋ ហើយនិងចំណូលពន្ធ និងគោលនយោបាយកសិកម្ម ជាពិសេសសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ ដូចជា ប្រទេសកម្ពុជា ។ សេចក្ដីសង្ខេបនេះ នឹងត្រូវប្រើប្រាស់ជាក្របខ័ណ្ឌសម្រាប់ការស្រាវជ្រាវ ។

## ការសិក្សាឯកសារអំពីគំរូរដ្ឋផ្សេងៗ និងភាពជាប់ទាក់ទងល្អសម្រាប់ការសិក្សាពីរដ្ឋកម្ពុជា

ដោយផ្ដោតការពិភាក្សាទៅលើរដ្ឋ ឯកសារផ្សេងៗជាច្រើន បានបង្ហាញពីគំរូរដ្ឋខុសៗគ្នា ដែលគេប្រើប្រាស់សម្រាប់ធ្វើវិភាគ ។ ឯកសារ Evans (1989), Evans (1995) និង Hutchcroft (1998) បានបង្កើតជាខ្សែបន្ទាត់មួយ ដែលនៅលើនោះ គាត់បានដាក់តំរៀបគ្នានូវគំរូរដ្ឋផ្សេងៗ ចាប់ពីរដ្ឋមានឥទ្ធិពលខ្លាំងបំផុត ហៅថារដ្ឋជំរុញអភិវឌ្ឍន៍ (developmental state) រហូតដល់រដ្ឋមានប្រសិទ្ធភាពតិចបំផុត ហៅថារដ្ឋជិះជាន់ (predatory state) ហើយនៅចន្លោះរដ្ឋទាំងពីរនេះ មានរដ្ឋច្រើនបែបទៀត ដូចជា រដ្ឋមូលធនបក្សពួកនិយម (crony capitalist state) រដ្ឋមូលធនការិយាធិបតេយ្យ (bureaucratic capitalist state) និងរដ្ឋជ័យភ័ណ្ឌ (booty state) ជាដើម ។ លោក Evans (Evans 1989; Evans 1995: 44) បានលើកឡើងថា រដ្ឋជិះជាន់ សំដៅដល់រដ្ឋដែលដកហូតយកយ៉ាងច្រើននូវប្រាក់នៅសល់ដែលអាចធ្វើវិនិយោគបាន និងផ្ដល់តិចតួចណាស់នូវទំនិញសម្ភារភាព ។ Evans (1995: 44) អះអាងថា រដ្ឋ Zaire (បានប្ដូរឈ្មោះទៅជាសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ) ស្ទើរតែក្លាយជារដ្ឋជិះជាន់សុទ្ធសាធ (អាចយកជាគំរូនៃរដ្ឋប្រភេទនេះបាន) ដោយក្នុងនេះ មានអ្នកនយោបាយវណ្ណៈខ្ពស់មួយក្រុមតូចដែលគ្រប់គ្រងលើក្បាលម៉ាស៊ីនរដ្ឋ និងដែលប្រឹងគិតគូរតែពីរឿងស្វែងរកប្រាក់កំរៃក្រៅផ្លូវការ និងមានប្រព័ន្ធការិយាធិបតេយ្យគុណភាពអន់មួយដែលបណ្ដោយឱ្យមានការលក់ដូរមុខងាររដ្ឋ និងការឃុបឃិតរវាងអ្នកការិយាធិបតេយ្យ អ្នកនយោបាយ និងពួកអាជីវករ ក្នុងការលួចប្លន់ធនធានរដ្ឋ ជាដើម ។ រដ្ឋប្រភេទនេះ ជាឧបសគ្គមួយដល់ការលូតលាស់សេដ្ឋកិច្ច ។

ផ្ទុយទៅវិញ រដ្ឋជំរុញអភិវឌ្ឍន៍ដែលស្ថិតនៅចុងម្ខាងទៀតនៃខ្សែបន្ទាត់ គឺរដ្ឋដែលមានសមត្ថភាពជួយលើកស្ទួយ ជំនាញសហគ្រិនក្នុងរយៈពេលវែង និងសកម្មភាពផ្សេងៗក្នុងវិស័យអាជីវកម្មឯកជន តាមរយៈការផ្ដល់គ្រឿងលើកទឹកចិត្តផ្សេងៗ និងជួយការពារវិនិយោគសម្រាប់ការលូតលាស់ ដូចជា នៅកូរ៉េខាងត្បូង តៃវ៉ាន់ និងជប៉ុន ជាដើម (Evans 1989; Donald 1998) ។ រដ្ឋជំរុញអភិវឌ្ឍន៍ ក៏មាន "ស្វ័យភាពបង្កប់" ដែលអាចសំគាល់បាន តាមកិច្ចសហការរវាងវិស័យឯកជន ស្ថាប័នរដ្ឋ និងអ្នកការិយាធិបតេយ្យ ។ ទោះរដ្ឋប្រភេទនេះ មានបង្កប់នូវវិស័យអាជីវកម្មឈានមុខក្ដី ក៏ Leftwich (2000: 160–167) បានស្នើឡើងនូវលក្ខណៈសំគាល់មួយចំនួនថែមទៀតសម្រាប់រដ្ឋជំរុញអភិវឌ្ឍន៍ ។ លក្ខណៈទីមួយ ឥស្សរជនអង់អាច ជំរុញអភិវឌ្ឍន៍ដែលស្អាតស្អំគ្រាន់បើ ដូចជា លោក Lee Kuan Yew នៅសិង្ហបុរី និងឧត្តមសេនីយ៍ Park Chung Hee នៅកូរ៉េខាងត្បូង ។ ទីពីរ រដ្ឋដែលមានស្វ័យភាព និងមិនចំណុះឱ្យក្រុមអ្នកមានផលប្រយោជន៍ធំៗ គឺការពារផលប្រយោជន៍ជាតិ ។ ទីបី ក្បាលម៉ាស៊ីនការិយាធិបតេយ្យរឹងមាំដំណើរការដោយមន្ត្រីដែលមានសមត្ថភាពរបស់រដ្ឋ និងដែលដាក់ចេញនូវគោលនយោបាយ ដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ច ។ លក្ខណៈសំគាល់ផ្សេងៗទៀតមានដូចជា សង្គមស៊ីវិលទន់ខ្សោយដែលនាំឱ្យរដ្ឋមានអំណាចគ្រប់គ្រងបាន

ដើម្បីធានាដល់ការពង្រឹងរបបនយោបាយ, សមត្ថភាពរដ្ឋក្នុងការលើកស្ទួយផលប្រយោជន៍សេដ្ឋកិច្ច (ការប្រមូលផ្ដុំមូលធន), ការអនុវត្តសិទ្ធិមនុស្សនៅខ្សោយ ដូចឃើញមាននៅសិង្ហបុរី និង តៃវ៉ាន់ ក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍន៍, ភាពពេញច្បាប់ និងលទ្ធផលល្អ (របបគ្រប់គ្រងនៃរដ្ឋជំរុញអភិវឌ្ឍន៍ មានលក្ខណៈពេញច្បាប់ និងសំរេចបានកំណើនលឿន) ។

Haber (2002: p.12) បានពន្យល់ពីមូលធនបក្សពួកនិយម ថាជាប្រព័ន្ធមួយដែលក្នុងនោះ អ្នកដែលមានចំណងទាក់ទងរឹងមាំជាមួយអ្នកមានវណ្ណៈខ្ពស់ក្នុងរដ្ឋអំណាច តែងទទួលបានអត្ថប្រយោជន៍សេដ្ឋកិច្ចធំធេង ដូចជាសិទ្ធិពិសេសទទួលបានឥណទានថោកជាងធម្មតាពីធនាគាររដ្ឋ ឬការអនុញ្ញាតឱ្យគិតថ្លៃផលិតផលខ្ពស់ជាងថ្លៃលំនឹងទីផ្សារ ។ ក្រុមបក្សពួកនិយមទាំងនោះបែងចែកកំរៃសេដ្ឋកិច្ចដែលខ្លួនទទួលបានទៅឱ្យគ្រួកនខ្លួនដែលជាអ្នកមានសិទ្ធិអំណាចក្នុងការបង្កើតគោលនយោបាយសេដ្ឋកិច្ច ។ ដូច្នេះ អ្នកមានបុណ្យស័ក្តិក្នុងរដ្ឋអំណាចគ្មានហេតុផលអ្វីនឹងបង្កើតគោលនយោបាយដែលរារាំងដល់ផលប្រយោជនរបស់បក្សពួកខ្លួនទេ ។ Sharafutdinova (2007) លើកថែមទៀតថា មូលធនបក្សពួកនិយមនៅរុស្ស៊ីបានកាត់បន្ថយភាពត្រឹមត្រូវពេញច្បាប់របស់រដ្ឋ ។

Hutchcroft ក៏បានបង្កើតប្រព័ន្ធបែងចែកប្រភេទរដ្ឋមួយ ដែលមានអនុប្រភេទចំនួនពីរ គឺមូលធននិយមការិយាធិបតេយ្យ និងមូលធននិយមជ័យភ័ណ្ឌ ។ ក្នុងអនុប្រភេទទីមួយ "អ្នកមានវណ្ណៈខ្ពស់ក្នុងការិយាធិបតេយ្យដកហូតយកបុព្វសិទ្ធិពីវណ្ណៈអាជីវករទន់ខ្សោយ" រីឯក្នុងអនុប្រភេទទីពីរវិញ "វណ្ណៈអាជីវករដែលមានអំណាចខ្លាំងដកហូតយកបុព្វសិទ្ធិពីប្រព័ន្ធការិយាធិបតេយ្យដែលដំណើរការមិនស៊ីចង្វាក់គ្នា" (Hutchcroft 1998:20) ។ Hutchcroft លើកឡើងថា ប្រទេសថៃ តំណាងឱ្យមូលធននិយមការិយាធិបតេយ្យ ហើយហ្វីលីពីន តំណាងឱ្យមូលធននិយមជ័យភ័ណ្ឌ ។

តាមការសង្កេតរបស់ Moore (2004) នៅក្នុងប្រវត្តិសាស្ត្រ ការផ្លាស់ប្ដូរក្លាយជារដ្ឋទំនើបនៃបណ្ដាប្រទេសនៅអឺរ៉ុប មិនមែនជំរុញដោយការិយាធិបតេយ្យសមហេតុផល ដូចក្នុងទ្រឹស្ដីរបស់ Weber ឬដូចក្នុងគំរូមូលធននិយមរបស់ពួក Marxist នោះទេ ។ ផ្ទុយទៅវិញ បំលាស់ប្ដូររដ្ឋដូចរៀបរាប់ខាងលើ សម្រេចបានតាមរយៈការធ្វើអន្តរកាលក្លាយជារដ្ឋពន្ធដារ ដែលក្នុងនោះ ចំណូលរដ្ឋបានមកពីការយកពន្ធ ។ រដ្ឋប្រភេទនេះ មានស្ថាប័នរឹងមាំ មានសមត្ថភាពអនុវត្តគោលនយោបាយអភិវឌ្ឍន៍ និងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ ។ រដ្ឋជំរុញអភិវឌ្ឍន៍ទំនើបៗនៅតំបន់អាស៊ីខាងកើត ដូចជា ជប៉ុន តៃវ៉ាន់ និងកូរ៉េខាងត្បូង សុទ្ធតែមានមូលដ្ឋានយកពន្ធរឹងមាំ ។ ផ្ទុយទៅវិញ រដ្ឋមួយចំនួនទៀត ទទួលធនធានហិរញ្ញវត្ថុតាមរយៈការទាញយកធនធានធម្មជាតិក្នុងប្រទេសរបស់ខ្លួន ដូចជា ប្រេងកាត ឬឈើ និង/ឬតាមរយៈជំនួយពីបរទេស ហើយគេហៅរដ្ឋទាំងនេះថា "រដ្ឋចាយទ្រព្យធន (rentier state)" ។ បណ្ដាប្រទេសនៅមជ្ឈិមបូព៌ា និងអាហ្វ្រិកខាងជើង ដែលទទួលបានប្រាក់ចំណូលភាគច្រើនមកពីការលក់ធនធានធម្មជាតិ គឺស្ថិតក្នុងប្រភេទនេះ ។ តាមការពិនិត្យឃើញជាក់ស្ដែង រដ្ឋទាំងនេះ មិនសូវមានការទាមទារគណនេយ្យភាពច្រើនពីសំណាក់ប្រជាពលរដ្ឋទេ (Moore 2004; Ross 2004) ។

អ្នកកសាងគោលនយោបាយ និងអ្នកស្រាវជ្រាវភាគច្រើននៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ គេចាត់ទុកកំណើនសេដ្ឋកិច្ច ជំរុញដោយការនាំចេញ និងផ្ដេកលើកម្មន្តសាល ថាជាសមាសធាតុចាំបាច់នៃកំណើនសេដ្ឋកិច្ចឆាប់រហ័ស និងមានចីរភាព ។ តាមបទពិសោធន៍របស់ប្រទេសមួយចំនួននៅអាស៊ី គោលគំនិតបែបនេះ អាចនាំឱ្យមានការមើលរំលងកសិកម្មដែលជាមូលដ្ឋានដ៏សំខាន់នៃការស្ទុះឡើងសេដ្ឋកិច្ច ។ ឧទាហរណ៍ ប្រទេសតៃវ៉ាន់ នៅដំណាក់កាលដំបូងនៃការអភិវឌ្ឍ បានពង្រឹងវិស័យកសិកម្ម តាមរយៈកំណែទម្រង់បំរើគោលដៅនេះ និងអន្តរាគមន៍ផ្សេងៗទៀតរបស់រដ្ឋ ។ ផលចំណេញដែលហូរហៀរចេញពីវិស័យកសិកម្ម មានច្រើនគួរកត់សំគាល់សម្រាប់ការរីកលូតលាស់ឧស្សាហកម្មដែលបន្ទាប់មកត្រូវក្លាយជាកត្តាចំបងនៃកំណើនសេដ្ឋកិច្ច (Amsden 1985: 87–88) ។ ដូចគ្នាដែរ ប្រទេសជប៉ុនក្នុងសម័យ Meiji (1868-1912) បានរីកលូតលាស់គួរឱ្យកត់សំគាល់ ដោយសារមានវិស័យកសិកម្មរឹងមាំ ។ កំណើនខាងកសិកម្ម បានជួយពង្រីកការអភិវឌ្ឍក្នុងវិស័យមិនមែនកសិកម្ម តាមរយៈការផ្ដល់ធាតុចូល ដូចជា វត្ថុធាតុដើមជាដើម ព្រមទាំងការផ្ទេរកំលាំងពលកម្ម និងមូលធន (Akino and Hayami 1974) ។ ដូច្នេះ សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ ជាពិសេសប្រទេសសំបូរធនធាន ដូចជា កម្ពុជាជាដើម ដែលមានប្រជាពលរដ្ឋ ប្រមាណ ៨០% រស់នៅទីជនបទ ដោយប្រកបរបរកសិកម្ម ក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍ គេត្រូវពឹងផ្អែកជាសំខាន់លើការពង្រឹងវិស័យកសិកម្ម ។

**ផលចំណេញដែលហូរហៀរចេញពីវិស័យកសិកម្ម មានច្រើនគួរកត់សំគាល់សម្រាប់ការរីកលូតលាស់ ឧស្សាហកម្មដែលបន្ទាប់មក ត្រូវក្លាយជាកត្តាចំបងនៃកំណើនសេដ្ឋកិច្ច ។**

**កំណើនខាងកសិកម្ម បានជួយពង្រីកការអភិវឌ្ឍក្នុង វិស័យមិនមែនកសិកម្ម តាមរយៈការផ្ដល់ធាតុចូល ដូចជា វត្ថុធាតុដើមជាដើម ព្រមទាំងការផ្ទេរ កំលាំងពលកម្ម និងមូលធន ។**

ក្រោយពីបានយល់ដឹងពីគំរូរដ្ឋខុសៗគ្នា គេអាចសង្ស័យថា ប្រទេសនីមួយៗ មិនអាចចាត់ចូលយ៉ាងដាច់ណាត់ទៅក្នុងគំរូណាមួយបានទេ ។ ជាក់ស្ដែង សូម្បីតែការអះអាងថា បណ្ដាប្រទេស ដូចជា សិង្ហបុរី និងតៃវ៉ាន់ ជាដើម ត្រូវចាត់ចូលក្នុងប្រភេទប្រទេសជំរុញអភិវឌ្ឍន៍ ក៏នៅតែអាចជជែកតវ៉ា

បាននៅឡើយ ។ បើក្រឡេកមើលមកកម្ពុជាវិញ គឺមានឯកសារកាន់តែច្រើន ដែលផ្ដល់ការសន្និដ្ឋានខុសៗគ្នាស្ដីពី លំនាំអភិវឌ្ឍន៍នៅក្នុងប្រទេស ។ សម្រាប់សេដ្ឋកិច្ច កំណើនប្រាក់ចំណូលវិជ្ជមានក្នុងមួយទសវត្សរ៍ចុងក្រោយ ដោយមានអត្រាកំណើនលេខពីរខ្ទង់ក្នុង ៤ឆ្នាំជាប់ៗគ្នាផង (២០០៤-២០០៧) បានឆ្លុះបញ្ចាំងពីប្រសិទ្ធភាពនៃគោលនយោបាយរបស់រដ្ឋ ក្នុងការជំរុញការអភិវឌ្ឍសេដ្ឋកិច្ច ។ កំណើនគួបផ្សំគ្នានៃវិស័យកសិកម្ម ឧស្សាហកម្ម (ជាពិសេសផ្នែកកាត់ដេរ) និងទេសចរណ៍ គឺជាកំលាំងដ៏សំខាន់ជំរុញកំណើនសេដ្ឋកិច្ច ។ នៅចំពោះមុខសមិទ្ធផលដ៏គួរកោតសរសើរនេះ គេមិនគួរមើលរំលងនូវសមត្ថភាពរបស់រដ្ឋាភិបាលក្នុងការរក្សាសន្តិភាព និងសណ្ដាប់ធ្នាប់សង្គម ដែលជាលក្ខខណ្ឌត្រូវមានជាមុនសម្រាប់ការលូតលាស់សេដ្ឋកិច្ច ។ ទាក់ទិននឹងការពង្រឹងកំលាំងនយោបាយវិញ មានការអះអាងថា សង្គមស៊ីវិលកម្ពុជាដែលទន់ខ្សោយ ត្រូវបានគ្រប់គ្រងដោយរដ្ឋ (Ou *et al*. 2009) គឺហាក់ដូចគ្នានឹងចរិតលក្ខណៈមួយរបស់រដ្ឋជំរុញអភិវឌ្ឍន៍ដទៃទៀត ដូចជា សិង្ហបុរី និងតៃវ៉ាន់ ជាដើម ។

អ្នកស្រាវជ្រាវមួយចំនួនបានជំទាស់នឹងការអះអាងខាងលើនេះ ។Un (2004) and Hughes (2003) បានសន្និដ្ឋានថា កម្ពុជានៅតែត្រូវគេចាត់ទុកជារដ្ឋទន់ខ្សោយ ដែលមានអំពើពុករលួយច្រើនពាសពេញ និងមានរបបនីតិរដ្ឋទន់ខ្សោយ ។Cock (បោះពុម្ពផ្សាយក្នុងពេលខាងមុខ) បានគូសបញ្ជាក់ពីការកើតមានប្រព័ន្ធគ្រប់គ្រងរដ្ឋដោយជនមួយក្រុមតូច ដែលឆ្លៀតយកចំណេញពីការទទួលបានបុព្វសិទ្ធិផ្សេងៗក្នុងការប្រើប្រាស់ដីសម្បទាន និងទ្រព្យសម្បត្តិរដ្ឋផ្សេងៗទៀត ។ គាត់យល់ថា បាតុភូតនេះ ជាឧបសគ្គរាំងស្ទះដល់ការបង្កើតរដ្ឋដែលត្រឹមត្រូវតាមច្បាប់ ។ ស្រដៀងគ្នានេះដែរ Pak and Craig (2008) បានបង្ហាញថា គណនេយ្យភាពរបស់រដ្ឋ វាយរលើបណ្ដាញខ្សែខ្នងភក្ដីភាព និងការស្វែងរកប្រាក់កំរៃក្រៅផ្លូវការ ។ ការសិក្សានេះ ក៏នឹងពិនិត្យពីទស្សនៈរបស់អ្នកស្រាវជ្រាវខុសៗគ្នា ហើយប្រៀបធៀបទស្សនៈទាំងនោះទៅនឹងការពិនិត្យឃើញជាក់ស្ដែង ដើម្បីធ្វើវិភាគពីចរិតលក្ខណៈនៃរដ្ឋកម្ពុជា ។ ចំណុចសំខាន់សម្រាប់ការវិភាគ គឺការយកពន្ធ និង គោលនយោបាយកសិកម្ម ។

សរុបមក ការយល់ដឹងពីគោលគំនិតស្ដីពីរដ្ឋដែលអ្នកស្រាវជ្រាវខុសៗគ្នាបានលើកឡើង មានសារៈសំខាន់បំផុត ដើម្បីក្ដាប់បានពីចរិតលក្ខណៈនៃរដ្ឋកម្ពុជា ដែលជាគោលដៅចំបងនៃកម្មវិធីស្រាវជ្រាវនេះ ។ ក្របខ័ណ្ឌនៃការវិភាគក្នុងការសិក្សា គឺការស្វែងយល់ពីចរិតលក្ខណៈសំខាន់ៗរបស់រដ្ឋជំរុញអភិវឌ្ឍន៍ ដើម្បីយកមកពិចារណាលើព័ត៌មានជាក់ស្ដែងដែលទទួលបានលើរដ្ឋកម្ពុជា ។

**កំណើនគួបផ្សំគ្នានៃវិស័យកសិកម្ម ឧស្សាហកម្ម (ជាពិសេសផ្នែកកាត់ដេរ) និងទេសចរណ៍ គឺជាកំលាំងដ៏សំខាន់ជំរុញកំណើនសេដ្ឋកិច្ច ។**

**ការរក្សាសន្តិភាព និងសណ្ដាប់ធ្នាប់សង្គម គឺជាលក្ខខណ្ឌត្រូវមានជាមុនសម្រាប់ការលូតលាស់សេដ្ឋកិច្ច ។**

## វិធីសាស្ត្រស្រាវជ្រាវ

ស្របតាមក្របខ័ណ្ឌនៃការស្រាវជ្រាវ ជាដំបូង ក្រុមស្រាវជ្រាវនឹងចំណាយពេលយ៉ាងច្រើន ពិនិត្យឡើងវិញលើការសិក្សាប្រៀបធៀបថ្នាក់តំបន់ និងអន្តរជាតិ ស្ដីពីរដ្ឋ និងមុខងាររដ្ឋ ការបង្កើតនិងកសាងរដ្ឋ ប្រភេទផ្សេងៗនៃរដ្ឋ ចរិតលក្ខណៈនៃរដ្ឋភាគខាងជើងនិងរដ្ឋភាគខាងត្បូង រចនាសម្ព័ន្ធរដ្ឋ ស្វ័យភាពនិងដែនឥទ្ធិពលការិយាធិបតេយ្យរបស់រដ្ឋនិងស្ថាប័នក្រៅផ្លូវការ (បណ្ដាញខ្សែខ្នងបែបថ្មី) អាណានិគមនិយម ការយកពន្ធ ការបង្កើតនិងអនុវត្តគោលនយោបាយរដ្ឋ ចំណុចខ្សោយនិងចំណុចខ្លាំងរបស់រដ្ឋ ទំនាក់ទំនងរវាងជនឋានៈខ្ពស់ក្នុងរដ្ឋនិងវណ្ណៈគ្រប់គ្រង ទំនាក់ទំនងរវាងរដ្ឋនឹងអ្នកផ្ដល់ជំនួយ/តួអង្គអន្តរជាតិ ជាពិសេសប្រទេសចិនដែលជាមហាអំណាចក្នុងតំបន់ ។ ការពិនិត្យឡើងវិញនេះ មានសារៈសំខាន់ខ្លាំងណាស់សម្រាប់ការស្វែងយល់និងវិភាគពីរដ្ឋកម្ពុជា ។ ក្នុងគោលដៅដូចគ្នា ក៏នឹងមានការពិនិត្យមើលនូវការសិក្សាជាប់ពាក់ព័ន្ធ ព្រមទាំងគោលនយោបាយ ច្បាប់ និងបទបញ្ញត្តិនានារបស់កម្ពុជា ។

នៅដំណាក់កាលបន្ទាប់ ការសិក្សា នឹងផ្ដោតទៅលើបទសម្ភាសន៍ស៊ីជំរៅជាមួយអ្នកផ្ដល់ព័ត៌មានគន្លឹះ ជាអាទិ៍ អ្នកកសាងគោលនយោបាយ ពាណិជ្ជករធំៗ អ្នកដឹកនាំក្រុមសង្គមស៊ីវិល និងអ្នកតំណាងនៃសហគមន៍អ្នកផ្ដល់ជំនួយ ។

សរុបមក ការស្រាវជ្រាវនេះធ្វើឡើងចំពេលដ៏សំខាន់ដែលរដ្ឋកំពុងធ្វើការផ្លាស់ប្ដូរសេដ្ឋកិច្ច[៣] ។របកគំហើញនៃការស្រាវជ្រាវ នឹងជួយពន្យល់ថា តើរដ្ឋកម្ពុជាកំពុងធ្វើដំណើរចំលើមាគ៌ាអភិវឌ្ឍន៍ដ៏ត្រឹមត្រូវឬទេ ហើយបើសិនមិនត្រឹមត្រូវទេ តើតួអង្គពាក់ព័ន្ធនានាគួរមានប្រតិកម្មបែបណា ដើម្បីរុញច្រានរដ្ឋឱ្យចូលទៅក្នុងមាគ៌ាដែលគួរដើរតាមនោះវិញ ។

(*សូមមើលឯកសារយោងនៅក្នុងអត្ថបទជាភាសាអង់គ្លេស*)

៣ Hughes and Un (បោះពុម្ពផ្សាយក្នុងពេលខាងមុខ) បានលើកឡើងថា កម្ពុជាបានងើបផុតពីសម័យក្រោយជម្លោះ និងឈានចូលទៅក្នុងដំណាក់កាលថ្មីនៃការផ្លាស់ប្ដូរសេដ្ឋកិច្ច ។ ម្យ៉ាងទៀត កម្ពុជាបានធ្វើសមាហរណកម្មចូលទៅក្នុងតំបន់ និងសាកលលោក ។ នៅមុនពេលមានការធ្លាក់ចុះសេដ្ឋកិច្ចសាកល កម្ពុជាមានកំណើនសេដ្ឋកិច្ចជាមធ្យម ៨,៧%ក្នុងមួយឆ្នាំនៅអំឡុងឆ្នាំ១៩៩៦ ដល់ ២០០៦ ហើយមានសេដ្ឋកិច្ចធ្លាក់ចុះ ដោយសារវិបត្តិហិរញ្ញវត្ថុ ។ ទោះជាយ៉ាងនេះក្ដី វិបត្តិហិរញ្ញវត្ថុក្នុងឆ្នាំ១៩៩៧ សឹងមិនមានផលប៉ះពាល់ដល់កម្ពុជាឡើយ ។

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្រៅប្រទេស

អត្ថបទនេះ បង្ហាញពីនិន្នាការសេដ្ឋកិច្ចនៃប្រទេសមានសេដ្ឋកិច្ចជឿនលឿនមួយចំនួនក្នុងពិភពលោក និងប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួននៅអាស៊ី នៅត្រីមាសទី៣ ឆ្នាំ២០០៩ ។

## កំណើនសេដ្ឋកិច្ចពិភពលោក

នៅត្រីមាសទី៣ កំណើន ផសស ពិតពីមួយឆ្នាំទៅមួយឆ្នាំនៅសហរដ្ឋអាមេរិក បន្តរួមចុះអស់ ២,៥% ដែលធូរស្រាលជាងត្រីមាសទី២ មកពីការរួមចំណែកជាវិជ្ជមាននៃចំណាយប្រើប្រាស់ផ្ទាល់ខ្លួន ការនាំចេញវិនិយោគលើស្តុកទំនិញឯកជន ចំណាយរបស់រដ្ឋាភិបាលសហព័ន្ធ និងវិនិយោគជាប់លាប់លើសំណង់សម្រាប់ស្នាក់នៅប៉ុន្តែត្រូវកាត់កងមួយផ្នែកដោយការរួមចំណែកជាអវិជ្ជមាននៃវិនិយោគជាប់លាប់មិនមែនសំណង់សម្រាប់ស្នាក់នៅ ។ ក្នុងពេលតែមួយ ផលិតផលប្រចាំឆ្នាំនៅតំបន់អឺរ៉ូ នៅតែរួមចុះធ្ងន់ធ្ងរអស់ដល់ ៤,៧% ដែលបណ្តាលជាសំខាន់មកពីការធ្លាក់ចុះនៃចំណាយប្រើប្រាស់ចុងក្រោយរបស់គ្រួសារ និងការបង្កើតទ្រព្យមូលធនជាប់លាប់ដុល ដែលត្រូវបានប៉ះប៉ូវខ្លះៗវិញ ដោយកំណើនបន្តិចនៃចំណាយប្រើប្រាស់ចុងក្រោយរបស់រដ្ឋាភិបាល ។ ផលិតផលពិតនៅជប៉ុនបន្តរួមចុះ ប៉ុន្តែមិនសូវធ្ងន់ធ្ងរដូចត្រីមាសមុនទេ ដោយសារការប្រសើរឡើងនៃពាណិជ្ជកម្ម និងចំណាយប្រើប្រាស់របស់ឯកជន ។

នៅត្រីមាសទី៣ ឆ្នាំ២០០៩ កំណើន ផសស ពិតពីមួយឆ្នាំទៅមួយឆ្នាំនៅចិន បន្តកើនឡើងដល់ ៨,៩% ដែលជាកម្រិតមួយខ្ពស់ ធៀបនឹងអត្រា ៧,៩% នៅត្រីមាសទី២ ដោយសារការរើបឡើងនៃវិនិយោគលើទ្រព្យជាប់លាប់និងការនាំចេញ ។សញ្ញាណនៃការរើបសេដ្ឋកិច្ច អាចឃើញច្បាស់នៅហុងកុង ដោយកំណើនផលិតផល មានអត្រា -២,៤% ធៀបនឹង -៣,៦% នៅត្រីមាសទី២ ដែលបណ្តាលមកពីកំណើនជាវិជ្ជមាននៃចំណាយប្រើប្រាស់របស់ឯកជន និងការបង្កើតទ្រព្យមូលធនក្នុងស្រុក ថ្វីបើនៅតែបន្តមានកំណើនជាអវិជ្ជមាននៃការនាំចេញក្តី ។នៅកូរ៉េខាងត្បូង ក៏មានសញ្ញាណរើបសេដ្ឋកិច្ចដែរ ដោយកំណើនផលិតផលពីមួយឆ្នាំទៅមួយឆ្នាំ ប្រែជាវិជ្ជមានវិញបានដល់០,៧% នៅត្រីមាសទី៣ដែលជាអត្រាមួយខ្ពស់ធៀបនឹងកំណើន -២,២% នៅត្រីមាសមុន ដែលបណ្តាលជាចំបងមកពីកំណើនជាវិជ្ជមាននៃការនាំចេញសរុប ចំណាយប្រើប្រាស់របស់រដ្ឋាភិបាល និងរបស់ឯកជន ប៉ុន្តែវាត្រូវកាត់កងមួយផ្នែកដោយការរួមចុះនៃការបង្កើតទ្រព្យមូលធនដុល ។ នៅតៃវ៉ាន់ កំណើនផលិតផល នៅតែមានដំណើរយឺត ដោយមានអត្រា -១,៣% ប៉ុន្តែប្រសើរជាងនៅត្រីមាសទី២ ដែលមានអត្រា -៧,៥% ដែលបណ្តាលមកពីកំណើនជាវិជ្ជមាននៃចំណាយប្រើប្រាស់ចុងក្រោយរបស់ឯកជន (២,២%) និងចំណាយប្រើប្រាស់ចុងក្រោយរបស់រដ្ឋាភិបាល (៣,៦%) ប៉ុន្តែវាត្រូវកាត់កងដោយកំណើនជាអវិជ្ជមាននៃការបង្កើត ទ្រព្យមូលធនជាប់លាប់ដុល (-៦,១%) និងការនាំចេញ (-៨,៥%) ។

នៅត្រីមាសទី៣ នៅម៉ាឡេស៊ី សិង្ហបុរី និងថៃ ក៏មានសញ្ញាណនៃការរើបសេដ្ឋកិច្ចដែរ ។ កំណើនផលិតផលពិត ពីមួយឆ្នាំទៅមួយឆ្នាំ នៅម៉ាឡេស៊ី មានអត្រា -១,២% ធៀបនឹង -៣,៩%នៅត្រីមាសទី២ ។ការរួមចុះបានធូរស្រាលខ្លះវិញ ដោយសារកំណើនជាវិជ្ជមាននៃចំណាយប្រើប្រាស់ចុងក្រោយរបស់រដ្ឋាភិបាល (១០,៩%) និងចំណាយប្រើប្រាស់របស់ឯកជន (១,៥%) ខណៈដែលកំណើននៃការបង្កើតទ្រព្យមូលធនជាប់លាប់ដុល និងការនាំចេញទំនិញនិងសេវាកម្ម នៅតែមានអត្រាអវិជ្ជមានត្រឹម -៧,៩% និង -១៣,៤% ។ សិង្ហបុរី ទំនងជារើបឡើងសេដ្ឋកិច្ចលឿនជាងប្រទេសពីរទៀត ដោយមានអត្រាកំណើនជាវិជ្ជមានដល់ ០,៦% ដែលបណ្តាលជាសំខាន់មកពីកំណើនជាវិជ្ជមាននៃចំណាយប្រើប្រាស់របស់រដ្ឋាភិបាល (១០,២%) និងការបង្កើតទ្រព្យមូលធនជាប់លាប់ដុល (០,៣%) ប៉ុន្តែត្រូវកាត់កងអស់មួយផ្នែកដោយកំណើនជាអវិជ្ជមាននៃចំណាយប្រើប្រាស់របស់ឯកជន (-០,៩%) និងការនាំចេញទំនិញនិងសេវាកម្ម (-១០,៩%) ។ កំណើន ផសស ពិតនៅថៃ គឺ -២,៨% ដែលជាការរួមចុះមួយតូចជាងកាលពីត្រីមាសមុន ហើយមូលហេតុសំខាន់ គឺកំណើន ៤,៧% នៃចំណាយរបស់រដ្ឋាភិបាល និងការនាំចេញសុទ្ធ ។

## អតិផរណាក្នុងពិភពលោក និងអត្រាប្តូរប្រាក់

នៅត្រីមាសទី៣ ឆ្នាំ២០០៩ នៅប្រទេសមានសេដ្ឋកិច្ចជឿនលឿន និងប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន នៅតែមានការបារម្ភពីសំពាធបរិត្តផរណា ។ នៅត្រីមាសទី៣ ឆ្នាំ២០០៩ អតិផរណាថ្លៃទំនិញប្រើប្រាស់ពីមួយឆ្នាំទៅមួយឆ្នាំនៅសហរដ្ឋអាមេរិក បន្តធ្លាក់ចុះ (-១,៦%) ។នៅត្រីមាសដដែល ថ្លៃទំនិញប្រើប្រាស់ជាទូទៅនៅតំបន់អឺរ៉ូ ធ្លាក់ចុះ -០,៣% ។នៅជប៉ុន អតិផរណាថ្លៃទំនិញប្រើប្រាស់ ក៏ធ្លាក់ចុះ ស្រដៀងគ្នានឹងសហរដ្ឋអាមេរិក និងតំបន់អឺរ៉ូដែរ ។

នៅត្រីមាសទី៣ ឆ្នាំ២០០៩ ប្រាក់ដុល្លារអាមេរិក ធ្លាក់ថ្លៃទល់នឹងប្រាក់វ៉ុនកូរ៉េខាងត្បូង និងប្រាក់យ៉េនជប៉ុន ដោយប្តូរបាន ១២៣៩,០៤វ៉ុន/ដុល្លារអាមេរិក និង ៩៣,៥៨យ៉េន/ដុល្លារអាមេរិក ។ ប្រាក់ដុល្លារអាមេរិក ក៏ធ្លាក់ថ្លៃទល់នឹងដុល្លារតៃវ៉ាន់ដែរ ដោយប្តូរបាន ៣២,៧៧ដុល្លារតៃវ៉ាន់/ដុល្លារអាមេរិក ។នៅត្រីមាសដដែល ប្រាក់ដុល្លារអាមេរិកនៅថ្លៃថេរ ធៀបនឹងប្រាក់យ៉ុនចិន ដុល្លារហុងកុង និងប្រាក់អឺរ៉ូ ។

## ថ្លៃទំនិញប្រើប្រាស់នៅទីផ្សារពិភពលោក

នៅត្រីមាសទី៣ ឆ្នាំ២០០៩ មានការធ្លាក់ថ្លៃទំនិញកសិកម្មសំខាន់ៗមួយចំនួន ។ ធៀបនឹងត្រីមាសមុន មានការធ្លាក់ថ្លៃគួរឱ្យកត់សម្គាល់ចំពោះពោត (១៤,២%) និងអង្ករ (៣៨,៤%) ប៉ុន្តែមានការធ្លាក់ថ្លៃតិចតួចចំពោះប្រេងឆា (៨,៣%) និងសណ្តែកសៀង (២,១%) ។ នៅត្រីមាសដដែល ទំនិញថាមពល បន្តឡើងថ្លៃ ធៀបនឹងត្រីមាសមុន ។ ប្រេងឆៅ និងម៉ាស៊ូត ឡើងថ្លៃ ១៨,៩% និង ១៤,៧% រីឯសាំងឡើងថ្លៃ ៨,៨% ។

*រៀបរៀងដោយ សាំង ច័ន្ទហង្ស*

តារាង១. កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៤-០៩ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2004 | 2005 | 2006 | 2007 | 2008 | 2008 Q2 | Q3 | Q4 | 2009 Q1 | Q2 | Q3 |
|---|---|---|---|---|---|---|---|---|---|---|---|
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | |
| កម្ពុជា | 7.7 | 13.4 | 10.6 | 10.2 | 6.8 | - | - | - | - | - | - |
| ឥណ្ឌូនេស៊ី | 5.1 | 5.6 | 5.4 | 6.3 | 6.1 | 6.4 | 6.1 | 5.2 | 4.4 | 3.9 | 4.2 |
| ម៉ាឡេស៊ី | 7 | 5.2 | 5.9 | 6.3 | 4.6 | 6.3 | 4.7 | 0.1 | -6.2 | -3.9 | -1.2 |
| សិង្ហបុរី | 8.5 | 5.7 | 7.7 | 7.7 | 1.1 | 1.9 | -0.6 | -4.2 | -10.1 | -3.5 | 0.6 |
| ថៃ | 6 | 4.5 | 4.8 | 4.9 | 2.6 | 5.3 | 3.9 | -4.3 | -7.1 | -4.9 | -2.8 |
| វៀតណាម | 7.5 | 8.4 | 8.1 | 8.5 | 6.2 | - | - | - | - | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | |
| ចិន | 9.5 | 9.6 | 10.5 | 11.9 | 9.0 | 10.1 | 9.0 | 6.8 | 6.1 | 7.9 | 8.9 |
| ហុងកុង | 8.3 | 6.5 | 6.6 | 6.4 | 2.4 | 4.2 | 1.7 | -2.5 | -7.8 | -3.8 | -2.4 |
| កូរ៉េខាងត្បូង | 4.7 | 4.7 | 5.0 | 4.9 | 2.2 | 4.8 | 3.8 | -3.6 | -4.4 | -2.2 | 0.7 |
| តៃវ៉ាន់ | 5.7 | 4.1 | 4.6 | 5.2 | 0.1 | 4.3 | -1.0 | -8.4 | -10.2 | -7.5 | -1.3 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | |
| អឺរ៉ូ-១២ | 1.8 | 1.5 | 2.7 | 2.9 | 0.9 | 1.4 | 0.6 | -1.3 | -2.5 | -4.8 | -4.7 |
| ជប៉ុន | 3.4 | 2.5 | 2.1 | 2.0 | -0.7 | 1.0 | -0.5 | -4.6 | -9.1 | -0.6 | -4.7 |
| សហរដ្ឋអាមេរិក | 4.4 | 3.7 | 3.3 | 2.2 | 1.1 | 2.8 | -0.5 | -6.3 | -2.6 | -3.9 | -2.5 |

*Sources: International Monetary Fund, Economist and countries' statistic offices*

តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៤-២០០៩ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2004 | 2005 | 2006 | 2007 | 2008 | 2008 Q2 | Q3 | Q4 | 2009 Q1 | Q2 | Q3 |
|---|---|---|---|---|---|---|---|---|---|---|---|
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | |
| កម្ពុជា | 4.0 | 5.8 | 4.7 | 10.5 | 19.7 | 24.9 | 21.7 | 15.7 | 4.3 | -4.8 | -3.0 |
| ឥណ្ឌូនេស៊ី | 8.3 | 10.5 | 13.4 | 6.4 | 10.1 | 10.1 | 11.9 | 11.4 | 8.5 | 5.6 | 2.7 |
| ម៉ាឡេស៊ី | 1.6 | 3.1 | 3.7 | 2.0 | 5.3 | 4.8 | 8.4 | 5.9 | 3.7 | 1.3 | -2.2 |
| សិង្ហបុរី | 1.7 | 0.5 | 1.0 | 2.1 | 6.5 | 7.5 | 6.5 | 5.5 | 2.1 | -0.5 | -0.4 |
| ថៃ | 2.7 | 4.5 | 4.7 | 2.2 | 5.5 | 7.7 | 7.2 | 2.2 | -0.2 | -2.8 | -2.1 |
| វៀតណាម | 7.8 | 8.2 | 7.7 | 8.3 | 23.3 | 24.4 | 29.0 | 23.6 | - | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | |
| ចិន | 3.9 | 1.8 | 1.5 | 4.8 | 5.9 | 7.8 | 5.3 | 2.5 | -0.6 | 1.5 | -1.2 |
| ហុងកុង | -0.4 | 1.1 | 2.2 | 2.0 | 4.3 | 5.7 | 4.6 | 2.3 | 1.7 | -0.1 | -0.8 |
| កូរ៉េខាងត្បូង | 3.5 | 2.8 | 2.4 | 2.5 | 4.6 | 4.8 | 5.5 | 4.5 | 3.9 | 2.8 | 2.0 |
| តៃវ៉ាន់ | 1.6 | 2.3 | 0.6 | 1.8 | 3.2 | 4.2 | 4.5 | 1.9 | 0.0 | -0.8 | -1.3 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | |
| អឺរ៉ូ-១២ | 2.2 | 2.2 | 2.1 | 2.1 | 3.3 | 3.8 | 3.8 | 2.3 | 1.0 | 0.9 | -0.3 |
| ជប៉ុន | Nil | -0.3 | 0.5 | 0.1 | 1.4 | 1.4 | 2.2 | 1.0 | -0.1 | -1.0 | -2.2 |
| សហរដ្ឋអាមេរិក | 2.7 | 3.4 | 3.2 | 2.9 | 3.8 | 4.4 | 5.3 | 1.5 | -0.2 | -0.9 | -1.6 |

*Sources: International Monetary Fund, Economist and National Institute of Statistics*

តារាង៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៤-២០០៩ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2004 | 2005 | 2006 | 2007 | 2008 | 2008 Q2 | Q3 | Q4 | 2009 Q1 | Q2 | Q3 |
|---|---|---|---|---|---|---|---|---|---|---|---|
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | |
| កម្ពុជា (រៀល) | 4016.3 | 4092.5 | 4103.2 | 4062.7 | 4054.2 | 4030.3 | 4117.4 | 4089.8 | 4108.0 | 4128.55 | 4164.44 |
| ឥណ្ឌូនេស៊ី (រូពីយ៉ា) | 8938 | 9705 | 9134 | 9419 | 9699.0 | 9265.3 | 9216.3 | 11,060 | 11,630.8 | 10,225.0 | 9887 |
| ម៉ាឡេស៊ី (រីងហ្គិត) | 3.80 | 3.79 | 3.67 | 3.31 | 3.34 | 3.21 | 3.37 | 3.56 | 3.63 | 3.52 | 3.50 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.69 | 1.66 | 1.59 | 1.51 | 4.58 | 1.37 | 1.43 | 1.49 | 1.51 | 1.45 | 1.44 |
| ថៃ (បាត) | 40.2 | 40.2 | 37.9 | 32.22 | 33.36 | 32.25 | 34.0 | 34.83 | 35.29 | 33.98 | 33.96 |
| វៀតណាម (ដុង) | 15,777 | 15,859 | 15,994 | 16,030 | 16,382 | 16,881 | 16,517 | 16,537 | 16,954 | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | |
| ចិន (យ៉ុន) | 8.28 | 8.19 | 7.97 | 8.03 | 6.94 | 6.96 | 6.82 | 6.83 | 6.84 | 6.83 | 6.83 |
| ហុងកុង (ដុល្លារហុងកុង) | 7.79 | 7.78 | 7.77 | 7.8 | 7.78 | 7.80 | 7.77 | 7.75 | 7.75 | 7.75 | 7.75 |
| កូរ៉េខាងត្បូង (វ៉ុន) | 1145 | 1024 | 955 | 929.04 | 1137.23 | 1018.84 | 1207.0 | 1367.2 | 1412.5 | 1273.9 | 1239.04 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 33.6 | 32.1 | 32.5 | 32.85 | 31.54 | 30.45 | 31.20 | 33.0 | 34.0 | 33.1 | 32.77 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 0.80 | 0.80 | 0.80 | 0.7 | 0.84 | 0.64 | 0.71 | 1.32 | 0.76 | 0.71 | 0.70 |
| ជប៉ុន (យ៉េន) | 108.2 | 110.2 | 116.4 | 117.8 | 102.46 | 104.53 | 104.03 | 96.1 | 93.72 | 95.95 | 93.58 |

*Sources: International Monetary Fund, Economist and National Bank of Cambodia*

តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០៤-២០០៩ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2004 | 2005 | 2006 | 2007 | 2008 | 2008 Q2 | Q3 | Q4 | 2009 Q1 | Q2 | Q3 |
|---|---|---|---|---|---|---|---|---|---|---|---|
| ពោត (US No. 2) - US ($/តោន) | 110.65 | 89.19 | 111.04 | 149.08 | 218.15 | 238.03 | 254.99 | 181.22 | 183.12 | 171.16 | 146.85 |
| ប្រេងឆា- អឺរ៉ុបពាយព្យ ($/តោន) | 427.47 | 381.32 | 433.85 | 707.68 | 912.23 | 1086.89 | 949.03 | 564.50 | 636.53 | 719.35 | 659.16 |
| អង្ករ (Thai 100%B) - បាងកក ($/តោន) | 221.67 | 262.88 | 282.00 | 305.36 | 615.32 | 839.58 | 657.88 | 519.41 | 522.13 | 499.45 | 307.31 |
| សណ្តែកសៀង (US No. 1) - US ($/តោន) | 262.03 | 224.25 | 213.88 | 294.59 | 460.41 | 479.97 | 529.30 | 382.72 | 434.40 | 420.10 | 411.18 |
| ប្រេងឆៅ-ឌូបៃ ($/ធុង) | 33.5 | 50.14 | 61.58 | 69.25 | 95.44 | 117.48 | 115.30 | 55.23 | 42.34 | 57.46 | 68.32 |
| សាំង - US Gulf Coast (សេន/លីត្រ) | 30.9 | 42.19 | 47.70 | 53.58 | 62.22 | 80.90 | 81.27 | 34.52 | 31.97 | 43.11 | 46.92 |
| ម៉ាស៊ូត (ស្តាន់ដ័រតិច លេខ២) - US Gulf Coast (សេន/លីត្រ) | 29.48 | 44.35 | 51.35 | 55.51 | 76.2 | 95.37 | 88.46 | 46.98 | 34.17 | 40.51 | 46.46 |

*Sources: Food and Agriculture Organisation and US Energy Information Administration*

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

នៅត្រីមាសទី៣ ឆ្នាំ២០០៩ អនុមតិគម្រោងវិនិយោគសរុប កើនឡើងគួរឱ្យកត់សម្គាល់ ប្រមាណ ៨,៨ដង ធៀបនឹងត្រីមាសមុន ដោយសារអនុមតិក្នុងវិស័យកសិកម្ម និងសេវាកម្ម កើនខ្លាំង ។ អនុមតិក្នុងវិស័យកសិកម្ម កើនឡើងពីសូន្យ ដល់ ១៧៦,១លានដុល្លារ រីឯអនុមតិក្នុងវិស័យសេវាកម្ម ស្ទុះឡើងពីសូន្យ ដល់ ១៥០,២លានដុល្លារ ។ អនុមតិសណ្ឋាគារ កើនដល់ ៧,២លានដុល្លារ វិស័យទេសចរណ៍ កើនដល់ ១៣៣,៣លានដុល្លារ និងអនុមតិវិស័យសេវាកម្មផ្សេងៗទៀត កើនដល់ ៦១,៦លានដុល្លារ ។ កំណើនវិនិយោគក្នុងវិស័យសេវាកម្មដែលជាប្រភពចំបងមួយនៃកំណើនសេដ្ឋកិច្ចកម្ពុជា អាចជាប់ទាក់ទងនឹងកំណើនភ្ញៀវមកដល់កម្ពុជា ធៀបនឹងត្រីមាសមុនដែលជារយៈពេលថយចុះ ។ អនុមតិវិស័យឧស្សាហកម្ម កើនឡើង ៥៤% ពី ៣៩,៤លានដុល្លារនៅត្រីមាសមុន ដល់ ៦០,៦លានដុល្លារ ។ អនុវិស័យកាត់ដេរ ធ្លាក់ចុះ ៣៧% មកត្រឹម ២១,៩លានដុល្លារ ហើយអនុវិស័យនេះ បន្តទទួលរងការប៉ះពាល់ពីការធ្លាក់ចុះសេដ្ឋកិច្ចនៅសហរដ្ឋអាមេរិកដែលជាទីផ្សារនាំចេញចំបងរបស់កម្ពុជា និងរួមចំណែកជាង ៥០% នៃចំណូលនាំចេញទូទាំងប្រទេស ។ ម្យ៉ាងទៀត អនុមតិខាងអនុវិស័យថាមពល ធ្លាក់ចុះពី ២,៧លានដុល្លារ មកត្រឹម ២,៥លានដុល្លារ ប៉ុន្តែខាងអនុវិស័យផលិតស្បែកជើង កើនពីសូន្យ ដល់ ១៣,៨លានដុល្លារ ហើយខាងសកម្មភាពរុករករ៉ែ កើនពីសូន្យ ដល់ ៥,៩លានដុល្លារ ។ អនុវិស័យឱសថ កើនដល់ ៣,៩លានដុល្លារ និងឧស្សាហកម្មផ្សេងៗទៀត កើនដល់ ១២,៨លានដុល្លារ ។

តម្លៃអនុមតិវិស័យសំណង់នៅរាជធានីភ្នំពេញ ធ្លាក់ចុះ ៨៨% ធៀបនឹងត្រីមាសមុន និង ៨៥% ធៀបនឹងត្រីមាសដូចគ្នាក្នុងឆ្នាំ២០០៨ ។ អនុមតិគម្រោងសាងសង់ផ្ទះ និងភូមិគ្រឹះ ធ្លាក់ចុះ ៦៧% មកត្រឹម ២,២លានដុល្លារ ហើយសម្រាប់ផ្ទះល្វែង និងសំណង់ផ្សេងៗទៀត ធ្លាក់ចុះ ៦៦% មកត្រឹម ៦,៣លានដុល្លារ និង ១២,២លានដុល្លារ ។ សកម្មភាពសាងសង់ បានថយល្បឿនដោយសារអ្នកអភិវឌ្ឍន៍ផ្នែកអចលនទ្រព្យកូរ៉េខាងត្បូង នៅជួបការលំបាកនៅឡើយ ដោយសារវិបត្តិសេដ្ឋកិច្ចសាកល ។

នៅត្រីមាសទី៣ ចំនួនភ្ញៀវបរទេសមកដល់កម្ពុជាសរុប កើនឡើង ៥,០% ធៀបនឹងត្រីមាសមុន ។ភ្ញៀវមកដល់តាមផ្លូវអាកាសកើនឡើង ១២% រហូតដល់ ២៤៧.១៧៣នាក់ ក្នុងនោះ មាន ៥១% ចូលមកតាមអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និង ៤៩% ចូលមកតាមអាកាសយានដ្ឋានខេត្តសៀមរាប ។ ភ្ញៀវចូលមកតាមផ្លូវគោក កើនដល់ ២៥.៦៧៧នាក់ និងតាមផ្លូវទឹក កើនដល់ ១៣.៥៥៦នាក់ ។ ក្នុងចំណោមភ្ញៀវមកពីប្រទេសអាស៊ាន ភ្ញៀវវៀតណាមមានច្រើនជាងគេ (៨០.៩៧៣នាក់) បន្ទាប់មកគឺភ្ញៀវឡាវ (២៥.២២០នាក់) ឯភ្ញៀវប្រ៊ុយណេ មានតិចជាងគេ (១០៥នាក់) ។ទោះបីជាមានទេសចរច្រើនមកពីប្រទេសជិតខាងក្ដី ប៉ុន្តែពួកគេច្រើនតែចំណាយតិចលើការស្នាក់នៅ ចំណីអាហារ ការដឹកជញ្ជូន និងចំណាយផ្សេងៗទៀត ។

ឱនភាពពាណិជ្ជកម្ម បានប្រែប្រួលប្រសើរឡើងពីកម្រិត ៦២៧,៣លានដុល្លារនៅត្រីមាសទី២ ដល់ ៩១,២លានដុល្លារ នៅត្រីមាសទី៣ ដោយសារការនាំចូលធ្លាក់ចុះច្រើន ទន្ទឹមនឹងការនាំចេញធ្លាក់ចុះតិច ។ ការនាំចូលធ្លាក់ចុះ ៦៨% ធៀបនឹងត្រីមាសមុន មកត្រឹម ៣៣៦,៥លានដុល្លារ ដោយសារការនាំចូលសម្ភារៈសំណង់ធ្លាក់ចុះ ៦៨% ក្នុងនេះ ការនាំចូលស៊ីម៉ង់ត៍ កើនឡើង ១៥% ដល់ ១០,៥លានដុល្លារ ប៉ុន្តែការនាំចូលដែកថែប ធ្លាក់ចុះ ២២% មកត្រឹម ៩,៨លានដុល្លារ ។ ការនាំចូលផ្សេងៗទៀត ធ្លាក់ចុះ ៧៥% ប៉ុន្តែការនាំចូលផលិតផលប្រេងកាត កើនឡើង ២៣% ។

នៅត្រីមាសទី៣ នេះដែរ ការនាំចេញ ធ្លាក់ចុះ ៤៣% មកត្រឹម ២៤៥,៣លានដុល្លារ ដោយសារការនាំចេញផលិតផលសំលៀកបំពាក់ ធ្លាក់ចុះ ៣៦% មកត្រឹម ២៤០,០លានដុល្លារ ។ ការនាំចេញកៅស៊ូ ធ្លាក់ចុះ ៤០% មកត្រឹម ៤,៩លានដុល្លារ និងការនាំចេញត្រី ធ្លាក់ចុះ ៤៧% មកត្រឹម ០,៤លានដុល្លារ ប៉ុន្តែគ្មានការនាំចេញឈើទេ ។

## ហិរញ្ញវត្ថុសាធារណៈ

នៅត្រីមាសទី៣ ឱនភាពថវិកាកើនឡើង ៧៦% ធៀបនឹងត្រីមាសមុន ដល់ ៩០៤,៨ពាន់លានរៀល ។ ការប្រមូលចំណូលចរន្ត រួមចុះ ៥,០% មកត្រឹម ១១៧៤,៩ពាន់លានរៀល ។ចំណូលពន្ធ ធ្លាក់ចុះ ៩,០% មកត្រឹម ៩៩៩,៥ពាន់លានរៀល ខណៈដែលចំណូលមិនមែនពន្ធ កើនឡើង ១៨% ដល់ ១៧៦,០ពាន់លានរៀល ។ ចំណាយសរុប កើនឡើង ១៨% ដោយសារចំណាយមូលធនកើនឡើង ២៥% និងចំណាយចរន្ត កើនឡើង ២១% ។ ក្នុងចំណាយចរន្តចំណាយលើបៀវត្សរ៍ កើនឡើង ២,០% មកដល់ ៥២៦,៦ពាន់លានរៀល ហើយចំណាយលើប្រាក់បំពេញខាត និងប្រាក់ឧបត្ថម្ភខាងសង្គមកិច្ច កើនឡើង ៤៧% មកដល់ ២៧២,៦ពាន់លានរៀល ។

## អតិផរណា និងអត្រាប្តូរប្រាក់

សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ទូទៅនៅរាជធានីភ្នំពេញ ធ្លាក់ចុះ ៣,០% តាំងពីដើមឆ្នាំដល់ត្រីមាសទី៣ នេះ ដោយវាមានបរិត្តផរណាក្នុងពីរត្រីមាសចុងក្រោយនេះ ។ កម្រិតថ្លៃលើចំណីអាហារ និងភេសជ្ជៈគ្មានជាតិស្រា ធ្លាក់ចុះ ២,៧% ថ្លៃស្នាក់នៅ និងទឹកភ្លើង ធ្លាក់ចុះ ៩,៦% ថ្លៃដឹកជញ្ជូន ធ្លាក់ចុះ ១៣,៨% ហើយថ្លៃទូរគមនាគមន៍ ធ្លាក់ចុះ ៨,៦% ។ ប៉ុន្តែកម្រិតថ្លៃ កើនឡើងសម្រាប់ការអប់រំ (១៤%) ភោជនីយដ្ឋាន និងសណ្ឋាគារ (៨,៤%) ការថែទាំសុខភាព (៨,០%) សំលៀកបំពាក់និងគ្រឿងសម្រាប់ពាក់នៅជើង (៥,៣%) ភេសជ្ជៈមានជាតិស្រា ថ្នាំជក់ និងថ្នាំងងុយដេក narcotics (៨,០%) ។

នៅត្រីមាសទី៣ ប្រាក់រៀលធ្លាក់ថ្លៃ ០,៩% ទល់នឹងប្រាក់ដុល្លារអាមេរិក ធៀបនឹងត្រីមាសមុន ប៉ុន្តែឡើងថ្លៃ ១,០% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ

២០០៨ ។ នៅត្រីមាសនេះ ប្រាក់រៀល ប្ដូរបាន ៤១៦៤,៤រៀល/ដុល្លារអាមេរិក ។ ប្រាក់រៀលធ្លាក់ថ្លៃ ៣,០% និង ០,៩% ទល់នឹងប្រាក់បាតថៃ និងប្រាក់ដុងវៀតណាម ដោយប្ដូរបាន ១២២,៩រៀល/បាត និង ២៣,៥រៀល/១០០ដុង ។

## ការវិវត្តរូបិយវត្ថុ

នៅខែកញ្ញា ២០០៩ រូបិយវត្ថុទូទៅ (M2) កើនឡើង ៣,០% ធៀបនឹងត្រីមាសមុន ដល់ ២៧៧៣,០ពាន់លានរៀល ដោយសាររូបិយវត្ថុនៅក្រៅធនាគារ កើនឡើង ២,០% ដល់ ២៦៥៧,៦ពាន់លានរៀល ប្រាក់បញ្ញើបើកបានភ្លាម កើន ២៥% ដល់ ១១៥,០ពាន់លានរៀល និងរូបិយវត្ថុផ្សេងៗ កើន ៩,០% ដល់ ១២.១៣៩,០ពាន់លានរៀល ។

នៅអំឡុងពេលដដែល ឥណទានក្នុងស្រុក កើនឡើង ៦,០% ដល់ ៧៦៦៣,០ពាន់លានរៀល ។ ឥណទេយ្យលើរដ្ឋាភិបាលសុទ្ធ គឺ -២៤៦៣,០ពាន់លានរៀល ក្នុងនេះ ឥណទេយ្យលើរដ្ឋាភិបាល មាន ២៧០,៥ពាន់លានរៀល និងប្រាក់បញ្ញើរដ្ឋាភិបាល មាន -២៧៣៤,០ពាន់លានរៀល ។ នៅពេលជាមួយគ្នាឥណទានដល់វិស័យឯកជនធ្លាក់ចុះ០,០២% មកត្រឹម១០.១២៧,០ពាន់លានរៀល ។ បំណុលផ្សេងៗ កើនឡើង ១០% ដល់ ៦៦២១,០ពាន់លានរៀល ដោយសារទ្រព្យសកម្មក្នុងស្រុកសុទ្ធ ធ្លាក់ចុះ ១៧% មកត្រឹម ១០៤២,០ពាន់លានរៀល ។

## ស្ថានភាពភាពក្រីក្រ

នៅខែវិច្ឆិកា ២០០៩ ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់ពលករងាយរងគ្រោះធ្លាក់ចុះ១៥,៦% ធៀបនឹងខែវិច្ឆិកា២០០៨ ។ទោះជាយ៉ាងនេះក្ដី ក្នុងចំណោម ១០ក្រុម មាន ៥ក្រុម បានរាយការណ៍ថា ប្រាក់ចំណូលរបស់ពួកគេ កើនឡើងបានបន្តិច (សូមមើលតារាង ៨) ។

នៅខែវិច្ឆិកា ប្រាក់ចំណូលពិតរបស់អ្នកធាក់ស៊ីក្លូ ធ្លាក់ចុះ ៤១% មកត្រឹម ៧៤៤៦រៀល ធៀបនឹង ១២.៦២៨រៀលកាលពីខែវិច្ឆិកា ២០០៨ ។ អ្នកធាក់ស៊ីក្លូ មានចំណូលឡើងចុះ តាំងពីដើមឆ្នាំ២០០៩ មកម្ល៉េះ យោងតាម ៨២,៥% នៃអ្នកឆ្លើយសម្ភាសន៍ ។ អ្នកធាក់ស៊ីក្លូ ៦០% រាយការណ៍ថា តាមធម្មតា ពួកគេចំណាយប្រហែល ៤៣០០រៀលលើចំណីអាហារ ដូច្នេះ មិនអាចសន្សំលុយបានច្រើនសម្រាប់ផ្ញើទៅផ្ទះឡើយ ។ ក្នុងចំណោមអ្នកឆ្លើយសម្ភាសន៍ មាន ៣២,៥% រាយការណ៍ថា ជីវភាពគ្រួសារបានប្រសើរឡើង ចាប់តាំងពីមកធ្វើការនៅភ្នំពេញ ចំណែកឯ ៤០% ទៀត រាយការណ៍ថា ជីវភាពគ្រួសារគ្មានការផ្លាស់ប្ដូរអ្វីទេ ហើយ ២៧,៥% ទៀត និយាយថា ស្ថានភាពគ្រួសាររឹតតែលំបាក ។ អ្នកធាក់ស៊ីក្លូ ៦០% បាននិយាយថា គ្រួសាររបស់ពួកគេត្រូវធ្លាក់ខ្លួនជំពាក់បំណុល ដោយសារប្រាក់ចំណូលធ្លាក់ចុះ ។

អ្នកលក់បន្លែតូចតាច ធ្លាក់ចុះប្រាក់ចំណូល ២៣% ធៀបនឹងខែវិច្ឆិកា ២០០៨ គឺចុះពី ៩៩២៦រៀលកាលពីឆ្នាំមុន មកត្រឹម ៧៦៤៧រៀល ។ កង្វះទុនគឺជាកត្តាមួយធ្វើឱ្យប្រាក់ចំណូលថយចុះ យោងតាម ៧២,៥% នៃអ្នកឆ្លើយសម្ភាសន៍ ។ អ្នកលក់បន្លែប្រហែល ៨០% មានទុនវិនិយោគតិចជាង ៥០.០០០រៀល ។ ចំណាយលើចំណីអាហាររបស់អ្នកលក់បន្លែ កើនឡើង ២០% ធៀបនឹងឆ្នាំមុន ដល់ ៤៣០០រៀលក្នុងមួយថ្ងៃ ។ អ្នកឆ្លើយសម្ភាសន៍ ៦០% បាននិយាយថា ការខ្ចីលុយគេ គឺជាដំណោះស្រាយតែមួយគត់ ដើម្បីចិញ្ចឹមជីវិតនៅពេលប្រាក់ចំណូលធ្លាក់ចុះ ។

នៅខែវិច្ឆិកា ២០០៩ ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់អ្នករត់ម៉ូតូឌុប ធ្លាក់ចុះ ៣៨,២% ធៀបនឹងកាលពីមួយឆ្នាំមុន ដល់ត្រឹម ៩៦៩៦រៀល ។ អ្នករត់ម៉ូតូឌុបប្រហែល ៩៥% និយាយថា ប្រាក់ចំណូលរកបាន វាមិនគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់គ្រួសារទាំងមូលឡើយ គឺគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់តែខ្លួនឯងម្នាក់តែប៉ុណ្ណោះ ។ អ្នករត់ម៉ូតូឌុប ៩៣% មកពីតាមខេត្ត ។ តាមធម្មតា ពួកគេចំណាយអស់ប្រហែល ៤៧០០រៀលទៅលើចំណីអាហារប្រចាំថ្ងៃ ។

ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់កម្មករសំណង់មានជំនាញ កើន ២,៤% ធៀបនឹងឆ្នាំមុន ដល់ ១៣.០១១រៀលក្នុងមួយថ្ងៃ ប៉ុន្ដែកំណើននេះ មិនគ្រប់គ្រាន់សម្រាប់ដោះស្រាយចំណាយក្នុងគ្រួសារឡើយ យោងតាម ៨៥,៧% នៃអ្នកឆ្លើយសម្ភាសន៍ ។ ស្ថានភាពនេះបានបណ្ដាលឱ្យគ្រួសារអ្នកឆ្លើយសម្ភាសន៍ ៣៥% ត្រូវធ្លាក់ខ្លួនជំពាក់បំណុលគេ ។ កម្មករសំណង់មានជំនាញភាគច្រើនមកពីទីជនបទ ដូច្នេះ ពួកគេត្រូវចំណាយលើចំណីអាហារផង និងលើការជួលផ្ទះផង ។

ប្រាក់ចំណូលរបស់កម្មករគ្មានជំនាញ ធ្លាក់ចុះ ៧,៤% ធៀបនឹងខែវិច្ឆិកា ២០០៨ ។ ការធ្លាក់ចុះនេះ បណ្ដាលជាសំខាន់មកពីចំនួនកម្មករកើនឡើង បើយោងតាមសេចក្ដីរាយការណ៍របស់អ្នកឆ្លើយសម្ភាសន៍ ៧៥% ។

ចំណូលរបស់អ្នករើសអេតចាយ កើនឡើង ០,៩% ធៀបនឹងខែវិច្ឆិកា ២០០៨ ប៉ុន្ដែធ្លាក់ចុះ បើធៀបនឹងអង្កេតនានា ក្នុងឆ្នាំ២០០៩ (តារាង ៨) ។ អ្នករើសអេតចាយ បានប្រាប់ពីក្ដីបារម្ភថា មិនអាចសន្សំប្រាក់បានគ្រប់គ្រាន់សម្រាប់ផ្ញើទៅផ្ទះទេ ពីព្រោះពួកគេរកបានមួយថ្ងៃហូបមួយថ្ងៃប៉ុណ្ណោះ ។

នៅខែវិច្ឆិកា ប្រាក់ចំណូលពិតរបស់កម្មកររោងចក្រកាត់ដេរ កើនឡើង ១៨,២% ធៀបនឹងខែវិច្ឆិកា ២០០៨ ដល់ ៧៧៤៥រៀល ។ អ្នកឆ្លើយសម្ភាសន៍ ៣៥,៨% គ្មានការងារបន្ថែមម៉ោងទេ ប៉ុន្ដែ ២៦,៧% មានការងារបន្ថែមម៉ោងជាទៀងទាត់ និង ៣៧,៥% មានការងារបន្ថែមម៉ោងដោយពេល ។

*រៀបចំដោយ*

*ស្រ៊ី បុប្ផារ័ត្ន និង ប៊ុន ដូរីណា*

តារាង១. គម្រោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០០៣-០៩

| | 2003 | 2004 | 2005 | 2006 | 2007 | 2008 | | | | 2009 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | | | | | | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | |
| កសិកម្ម | 3.7 | 12.3 | 26.8 | 498.0 | 102.4 | 52.3 | 16.7 | 18.6 | 4.4 | 175.3 | 0.0 | 176.1 |
| ឧស្សាហកម្ម | 137.2 | 187.9 | 914.6 | 365.3 | 328.0 | 52.9 | 95.0 | 91.6 | 485.4 | 257.7 | 39.4 | 60.6 |
| *កាត់ដេរ* | *68.1* | *132.6* | *174.4* | *89.4* | *69.1* | *42.3* | *47.8* | *31.3* | *21.4* | *16.4* | *35.0* | 21.9 |
| សេវាកម្ម | 168.4 | 91.8 | 155.5 | 2939.1 | 311.1 | 148.2 | 4064.9 | 4450.5 | 1339.6 | 495.6 | 0.0 | 150.2 |
| *សណ្ឋាគារ និងទេសចរណ៍* | *124.1* | *55.9* | *102.6* | *345.0* | *199.2* | *93.7* | *4015.0* | *3481.3* | *1168.1* | *254.1* | *0.0* | 150.2 |
| សរុប | 309.3 | 292.0 | 1096.9 | 3802.4 | 741.5 | 253.4 | 4176.5 | 4560.7 | 1580.3 | 928.6 | 39.4 | 386.3 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | |
| សរុប | - | - | - | - | -35.9 | -78.1 | 1548.2 | 9.2 | -65.3 | -41.2 | -95.7 | 882.0 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | |
| សរុប | 22.1 | -5.6 | 275.6 | 246.6 | -23.7 | -49.1 | 2083.2 | 294.2 | 113.1 | 266.5 | -99.0 | -91.5 |

*Including expansion project approvals. Source: Cambodian Investment Board*

តារាង២. តម្លៃគម្រោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០៣-០៩

| | 2003 | 2004 | 2005 | 2006 | 2007 | 2008 | | | | 2009 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | | | | | | លានដុល្លារ | | | | | | |
| ភូមិគ្រឹះ និង ផ្ទះ | 20.0 | 30.3 | 45.5 | 33.1 | 20.2 | 45.3 | 17.6 | 52.1 | 39.7 | 32.1 | 6.7 | 2.2 |
| ផ្ទះល្វែង | 91.6 | 167.6 | 204.2 | 213.3 | 57.6 | 40.9 | 55.1 | 65.6 | 60.0 | 95.2 | 18.9 | 6.3 |
| ផ្សេងៗ | 87.3 | 65.6 | 109.1 | 76.8 | 94.3 | 51.2 | 68.2 | 369.3 | 252.2 | 53.7 | 36.7 | 12.2 |
| សរុប | 198.9 | 263.5 | 358.8 | 323.3 | 172.2 | 137.3 | 140.9 | 486.9 | 351.9 | 181.1 | 62.3 | 20.7 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | |
| សរុប | - | - | - | - | -4.2 | -1.4 | 2.6 | 245.6 | -27.7 | -48.5 | -65.6 | -66.8 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | |
| សរុប | -9.5 | 32.5 | 36.2 | -9.9 | 120.2 | -1.4 | -2.6 | 170.9 | 104.4 | 31.9 | -55.8 | -95.7 |

*Source: Department of Cadastre and Geography of Phnom Penh municipality*

តារាង៣. ចំនួនអ្នកដំណើរមកដល់ក្នុងប្រទេសកម្ពុជា ឆ្នាំ២០០៣-០៩

| | 2003 | 2004 | 2005 | 2006 | 2007 | 2008 | | | | 2009 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | | | | | | ចំនួនអ្នកដំណើរ (ពាន់នាក់) | | | | | | |
| តាមផ្លូវអាកាស | 456.0 | 626.1 | 856.5 | 1029.0 | 368.8 | 402.0 | 262.0 | 259.2 | 316.2 | 335.2 | 221.2 | 247.2 |
| តាមផ្លូវគោក និងទឹក | 245.0 | 428.9 | 565.1 | 672.9 | 239.2 | 242.2 | 192.0 | 186.3 | 261.4 | 287.1 | 243.0 | 240.2 |
| សរុប | 701.1 | 1055.0 | 1421.6 | 1701.9 | 608.0 | 644.2 | 454.0 | 445.5 | 577.6 | 622.3 | 464.2 | 487.4 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | |
| សរុប | - | - | - | - | 40.8 | 6.0 | -29.5 | -1.9 | 29.6 | 7.7 | -25.4 | 5.0 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | |
| សរុប | -10.9 | 50.5 | 34.7 | 19.7 | 17.8 | 17.0 | 6.9 | 3.2 | -5.0 | -3.4 | 2.2 | 9.4 |

*Source: Ministry of Tourism*

តារាង៤. ការនាំចេញ និងនាំចូល ឆ្នាំ២០០៣-០៩

| | 2003 | 2004 | 2005 | 2006 | 2007 | 2008 | | | | 2009 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 |
| | | | | | | លានដុល្លារ | | | | | | |
| ការនាំចេញសរុប | 1708.1 | 2108.1 | 2352.8 | 2799.9 | 793.4 | 803.1 | 539.6 | 928.7 | 728.6 | 721.4 | 433.5 | 245.3 |
| ក្នុងនេះ: សំលៀកបំពាក់ | 1628.4 | 2027 | 2253.3 | 2698.9 | 727.1 | 773.4 | 463.8 | 868.8 | 678.8 | 606.9 | 377.3 | 240.0 |
| កៅស៊ូ | 35.1 | 38.3 | 36.7 | 41.4 | 14.6 | 7.0 | 11.0 | 12.9 | 5.2 | 11.8 | 8.2 | 4.9 |
| ឈើ | 10.2 | 11.1 | 10.3 | 8.6 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.1 | 0.1 | 0 |
| ត្រី | 2.8 | 10.6 | 10.1 | 5.9 | 0.9 | 0.7 | 0.3 | 0.6 | 0.6 | 0.9 | 0.7 | 0.4 |
| ការនាំចូលសរុប | 1824.9 | 2149.0 | 2513.0 | 3057.0 | 982.7 | 983.8 | 1178.5 | 1027.1 | 916.3 | 987.7 | 1060.8 | 366.5 |
| ក្នុងនេះ: ផលិតផលប្រេងកាត | 191.6 | 187.0 | 184.8 | 238.5 | 58.9 | 60.0 | 64.6 | 68.3 | 62.9 | 67.3 | 72.2 | 89.0 |
| សំភារ:សំណង់ | 80.8 | 95.3 | 134.7 | 154.4 | 32.5 | 39.7 | 40.7 | 35.6 | 29.9 | 41.4 | 30.9 | 9.9 |
| ផ្សេងៗ | 1601.3 | 1914.0 | 2245.0 | 2731.0 | 891.3 | 884.1 | 1073.2 | 923.2 | 823.5 | 879.0 | 957.7 | 237.5 |
| ជញ្ជីងពាណិជ្ជកម្ម | -116.8 | -40.9 | -160.1 | -257.1 | -189.3 | -180.7 | -638.9 | -98.4 | -187.7 | -157.6 | -627.3 | -91.2 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | - | - | - | - | -14.1 | 6.4 | -40.0 | 87.3 | -21.9 | -10.5 | -37.8 | -36.3 |
| ការនាំចេញសរុប | - | - | - | - | -10.9 | 1.2 | -32.8 | 72.1 | -21.5 | -0.9 | -39.9 | -43.4 |
| ការនាំចូលសរុប | - | - | - | - | 6.3 | 0.1 | 19.8 | -12.8 | -10.8 | 7.8 | 7.4 | -68.3 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | -54.1 | -64.9 | 291.4 | 19.8 | 1.6 | 14.2 | -32.6 | 2.7 | -6.6 | -21.5 | -18.6 | -72.4 |
| ការនាំចេញសរុប | 17.5 | 23.4 | 11.6 | 19.0 | 7.7 | 13.5 | -23.5 | 4.3 | -8.2 | -10.2 | -19.7 | -73.6 |
| ការនាំចូលសរុប | 6.9 | 17.8 | 16.9 | 21.6 | 21.7 | 24.4 | 29.3 | 11.1 | -6.8 | 0.4 | -9.9 | -67.2 |

*Import data include tax-exempt imports. Sources: Customs and Excise Department, cited by National Bank of Cambodia*

តារាង៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានជាសាច់ប្រាក់ ឆ្នាំ២០០៣-០៩ (ពាន់លានរៀល)

| | 2003 | 2004 | 2005 | 2006 | 2007 Q4 | 2008 Q1 | Q2 | Q3 | Q4 | 2009 Q1 | Q2 | Q3 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ចំណូលសរុប | 1764 | 2126 | 2625 | 3259.2 | 1146.1 | 1194.1 | 1463.6 | 1297.0 | 1335.3 | 1101.7 | 1252.7 | 1184.7 |
| ចំណូលចរន្ត | 1733 | 2107 | 2474 | 2881.8 | 1141.6 | 1189.4 | 1447.0 | 1288.3 | 1286.0 | 1097.7 | 1245.7 | 1174.9 |
| ចំណូលពន្ធ | 1220 | 1577 | 1911 | 2270.9 | 965.2 | 978.0 | 1255.0 | 1071.2 | 1105.7 | 947.4 | 1096.5 | 999.5 |
| ពន្ធក្នុងស្រុក | - | - | - | - | 661.8 | 719.9 | 955.5 | 776.7 | 796.3 | 712.0 | 838.7 | 731.8 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | - | - | - | - | 303.5 | 258.1 | 299.5 | 294.5 | 309.4 | 235.4 | 257.8 | 268.0 |
| ចំណូលមិនមែនពន្ធ | 513 | 530 | 563 | 610.9 | 176.4 | 211.4 | 192.1 | 217.1 | 180.2 | 150.3 | 149.2 | 176.1 |
| ចំណូលលើទ្រព្យសម្បត្តិ | - | - | - | - | 13.6 | 2.9 | 53.9 | 11.0 | 10.2 | 13.1 | 9.7 | 27.5 |
| លក់ទំនិញ និងសេវា | - | - | - | - | 124.3 | 118.9 | 96.3 | 99.7 | 109.8 | 93.5 | 100.9 | 91.7 |
| ចំណូលមិនមែនពន្ធផ្សេងទៀត | - | - | - | - | 38.5 | 89.6 | 41.9 | 106.4 | 60.3 | 43.7 | 38.6 | 56.5 |
| ចំណូលជាមូលធន | 31 | 19 | 152 | 377.4 | 4.5 | 4.8 | 16.5 | 8.7 | 49.3 | 4.0 | 7.0 | 9.8 |
| ចំណាយសរុប | 2757 | 2932 | 3295 | 4174.7 | 1689.7 | 1059.1 | 1744.7 | 1662.8 | 1831.2 | 1650.6 | 1766.1 | 2089.5 |
| ចំណាយជាមូលធន | 1171 | 1163 | 1328 | 1638.1 | 807.4 | 411.0 | 648.2 | 641.2 | 874.0 | 693.6 | 607.1 | 759.2 |
| ចំណាយចរន្ត | 1586 | 1769 | 1967 | 2536.8 | 882.3 | 648.1 | 1096.5 | 918.0 | 1146.4 | 752.4 | 1064.7 | 1290.4 |
| បៀវត្សរ៍ | 615 | 640 | 711 | 822.0 | 362.6 | 250.7 | 367.0 | 363.6 | 415.7 | 327.4 | 515.5 | 526.6 |
| ឧបត្ថមធន និងជំនួយសង្គមកិច្ច | - | - | - | - | 194.2 | 104.3 | 325.7 | 111.9 | 385.2 | 217.3 | 185.9 | 272.6 |
| ចំណាយចរន្តផ្សេងទៀត | - | - | - | - | 325.5 | 193.1 | 403.8 | 442.6 | 345.4 | 207.7 | 363.2 | 491.2 |
| សមតុល្យជាទូទៅ | -993 | -806 | -706 | -915.6 | -543.6 | 135.0 | -281.1 | -365.8 | -495.9 | -548.9 | -513.4 | -904.8 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 886 | 864 | 1127 | 1360.7 | 741.5 | 299.2 | 615.8 | 435.0 | 705.1 | 507.8 | 326.7 | 484.5 |
| ហិរញ្ញប្បទានក្នុងស្រុក | 106 | 148 | -396 | -445.1 | -185.8 | -294.1 | -236.5 | 234.7 | 168.9 | -310.3 | 236.5 | 316.4 |

*Source: MEF web site*

តារាង៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្តូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ឆ្នាំ២០០៣-០៩

| | 2003 | 2004 | 2005 | 2006 | 2007 Q4 | 2008 Q1 | Q2 | Q3 | Q4 | 2009 Q1 | Q2 | Q3 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| (ខែតុលា-ធ្នូ ២០០៦:១០០) | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ភ្នំពេញ - ទំនិញគ្រប់ប្រភេទ | - | - | - | - | 12.3 | 20.6 | 33.3 | 28.7 | 17.8 | 4.3 | -4.8 | -3.0 |
| - ម្ហូបអាហារ និងភេសជ្ជៈគ្មានជាតិស្រា | - | - | - | - | 18.9 | 29.5 | 47.6 | 37.4 | 24.1 | 6.1 | -5.2 | -2.7 |
| - ដឹកជញ្ជូន | - | - | - | - | 9.6 | 21.7 | 28.9 | 27.8 | 4.1 | -13.0 | -16.5 | -13.8 |
| | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 3973.3 | 4016.3 | 4119.7 | 4119.0 | 4030.1 | 3995.3 | 4030.2 | 4117.5 | 4089.8 | 4111.6 | 4128.6 | 4146.4 |
| រៀលក្នុង ១ បាតថៃ | 95.8 | 99.9 | 102.6 | 108.7 | 129.3 | 129.1 | 125.4 | 121.9 | 117.7 | 116.6 | 119.2 | 122.9 |
| រៀលក្នុង ១០០ ដុងវៀតណាម | 25.6 | 25.5 | 25.8 | 25.1 | 25.2 | 25.2 | 24.9 | 24.8 | 24.3 | 23.6 | 23.3 | 23.5 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 41.4 | 46.3 | 54.0 | 70.6 | 94.4 | 111.6 | 107.7 | 106.0 | 98.2 | 105.6 | 110.7 | 123.2 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 1508 | 2088 | 2633 | 3140 | 3679 | 3982 | 4975 | 5495 | 3768.9 | 2873.7 | 3056.9 | 3867.0 |
| ថ្លៃសាំង (រៀល/លីត្រ) | 2150 | 2833 | 3442 | 4004 | 4368 | 4580 | 5171 | 5391 | 3861.3 | 3112.6 | 3452.4 | 3371.1 |

*Sources: NIS, NBC & CDRI*

តារាង៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០០៣-០៩ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 2003 | 2004 | 2005 | 2006 | 2007 Q4 | 2008 Q1 | Q2 | Q3 | Q4 | 2009 Q1 | Q2 | Q3 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ពាន់លានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 4027 | 4797 | 5475 | 7224 | 10,735 | 10,911 | 11,353 | 10,809 | 10,345 | 11,222 | 12,611 | 13,869 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | -698 | -467 | -450 | -282 | 576 | 1136 | 1345 | 1748 | 15,13.3 | 1266 | 1249 | 1042 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -128 | -209 | -421 | -953 | -1,816 | -2400 | -2678 | -2653 | -2987 | -3048 | -2889 | -2462 |
| ឥណទានដល់ផ្នែកឯកជន | 1337 | 1817 | 2394 | 3630 | 6386 | 8050 | 9206 | 9781 | 9894 | 9814 | 10,129 | 10,127 |
| រូបិយវត្ថុទូទៅ M2 | 3329 | 4330 | 5025 | 6942 | 11,311 | 12,047 | 12,698 | 12,557 | 11,858 | 12,488 | 13,859 | 14,912 |
| រូបិយវត្ថុ M1 | 937 | 1153 | 1323 | 1658 | 2052 | 2389 | 2467 | 2335 | 2399 | 2545 | 2695 | 2773 |
| រូបិយវត្ថុផ្សេងៗ | 2392 | 3177 | 3702 | 5285 | 9259 | 9658 | 10,231 | 10,223 | 9459 | 9942 | 11,164 | 12,139 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ M2 | 15.2 | 30.0 | 16.1 | 38.1 | 62.9 | 54.5 | 43.1 | 26.7 | 4.8 | 3.7 | 9.1 | 18.7 |
| រូបិយវត្ថុ M1 | 15.3 | 23.0 | 14.7 | 25.3 | 23.8 | 33.2 | 41.1 | 33.4 | 16.9 | 6.5 | 9.2 | 18.7 |
| រូបិយវត្ថុផ្សេងៗ | 15.2 | 32.8 | 16.6 | 42.8 | 75.2 | 61.0 | 43.5 | 25.3 | 2.2 | 2.9 | 9.1 | 18.7 |

*Source: National Bank of Cambodia*

តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បំរែបំរួលជាភាគរយ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2005 | 2006 | 2007 | 2007 វិច្ឆិកា | 2008 វិច្ឆិកា | 2009 កុម្ភៈ | ឧសភា | សីហា | វិច្ឆិកា | កុម្ភៈ ០៩ -ឧសភា ០៩ | ឧសភា ០៩ -សីហា ០៩ | វិច្ឆិកា ០៨ -វិច្ឆិកា ០៩ |
| អ្នកធាក់ស៊ីក្លូ | 8085 | 7469 | 8075 | 9675 | 12,628 | 8534 | 8896 | 7738 | 7446 | 4.2 | -13.0 | -41.0 |
| អ្នកលីសែង | 6734 | 6545 | 8588 | 9119 | 9005 | 10,476 | 10,319 | 8159 | 9566 | -1.5 | -20.9 | 6.2 |
| អ្នកលក់បន្លែតូចតាច | 7739 | 6390 | 8220 | 8552 | 9926 | 7614 | 9764 | 8323 | 7647 | 28.2 | -14.8 | -23.0 |
| អ្នករើសអេតចាយ | 5167 | 4416 | 5422 | 5727 | 4652 | 5170 | 6637 | 7087 | 4693 | 28.4 | 6.8 | 0.9 |
| អ្នកបំរើតុភោជនីយដ្ឋាន* | 4344 | 4412 | 4482 | 4643 | 4327 | 4283 | 4346 | 4574 | 5568 | 1.5 | 5.3 | 28.7 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 4370 | 5306 | 5516 | 6426 | 8697 | 7044 | 7126 | 5785 | 5003 | 1.2 | -18.8 | -42.5 |
| កម្មកររោងចក្រកាត់ដេរ | 7359 | 7649 | 7568 | 7240 | 6554 | 6754 | 6691 | 7410 | 7745 | -0.9 | 10.8 | 18.2 |
| អ្នករត់ម៉ូតូឌុប | 10,595 | 8201 | 10,634 | 11,872 | 15,691 | 11,655 | 12,148 | 9569 | 9696 | 4.2 | -21.2 | -38.2 |
| កម្មករសំណង់គ្មានជំនាញ | 6712 | 5918 | 6155 | 7777 | 8779 | 6115 | 9956 | 9444 | 8132 | 62.8 | -5.1 | -7.4 |
| កម្មករសំណង់មានជំនាញ | 12,049 | 10,316 | 11,154 | 11,286 | 12,710 | 11,771 | 13,688 | 11,918 | 13,011 | 16.3 | -12.9 | 2.4 |

** Waitresses' earnings do not include meals and accommodation provided by shop owners. Surveys on the revenue of waitresses, rice -field workers, garment workers, unskilled workers, motorcycle taxi drivers and construction workers began in February 2000. Source: CDRI*

តពីទំព័រ ២៤ **ព័ត៌មានថ្មីៗ ...**

ប៉ះពាល់ដល់ការអភិវឌ្ឍប្រទេសកម្ពុជា ដល់ទំនាក់ទំនងចិន-កម្ពុជា-ឡាវ-ថៃ-វៀតណាម និងដល់សមាហរណកម្មក្នុងតំបន់ និងអនុតំបន់ ។

ថ្នាក់គ្រប់គ្រងវិទ្យាស្ថាន CDRI ក៏រាយការណ៍ជូនក្រុមប្រឹក្សាភិបាលអំពីលទ្ធផលហិរញ្ញវត្ថុដ៏ប្រសើរសំរាប់ឆ្នាំ២០០៩ និងការបន្តពង្រីកមូលដ្ឋានធនធានហិរញ្ញវត្ថុ និងធនធានមនុស្ស និងមានអតិរេកថវិកាបន្តិចផងសម្រាប់ដាក់បញ្ចូលក្នុងទុនបំរុង ព្រមទាំងការរំពឹងថា នឹងមានលទ្ធផលល្អប្រហាក់ប្រហែលគ្នាទៀតនៅឆ្នាំ២០១០ ។ ទោះជាយ៉ាងនេះក្ដី ចីរភាពរយៈពេលវែងនៅតែជាបញ្ហាប្រឈម ហើយវិទ្យាស្ថាន CDRI នឹងស្វែងរកដៃគូផ្ដល់ធនធានរយៈពេលវែង ក្នុងចំណោមដៃគូអភិវឌ្ឍន៍អន្ដរជាតិ និងទីភ្នាក់ងារឯទៀត ហើយសំរេចបានតុល្យភាពកាន់តែប្រសើររវាងការផ្ដល់ធនធានផ្អែកលើកម្មវិធី និងការផ្ដល់ធនធានផ្អែកលើគម្រោងក្នុងផែនការយុទ្ធសាស្ដ្រឆ្នាំ២០១១-១៥ ។

វិទ្យាស្ថាន CDRI និងវិទ្យាស្ថានដៃគូនានាក្នុងបណ្ដាញវិភាគអភិវឌ្ឍន៍ (DAN) ដែលមកពីប្រទេសឡាវ ថៃ វៀតណាម និងខេត្តយុនណាន់ ប្រទេសចិន បានចូលរួមប្រជុំចំនួនពីរលើកស្ដីពីការធ្វើផែនការ គឺមួយលើកនៅក្រុងលួងប្រាបាង ក្នុងខែសីហា ២០០៩ និងមួយលើកទៀត នៅក្រុងគុនមិញក្នុងខែមករា ២០១០ ដើម្បីពិនិត្យឡើងវិញពីតួនាទី តម្លៃ លទ្ធផល ចំណុចខ្លាំង និងចំណុចខ្សោយនៃ DAN និងបង្កើតជាយុទ្ធសាស្ដ្រសម្រាប់ពង្រឹង និងទ្រទ្រង់បណ្ដាញឱ្យក្លាយទៅជាបណ្ដាញស្រាវជ្រាវដែលមានការរួមសហការគ្នាយ៉ាងស័ក្ដិសិទ្ធិនៅក្នុងមហាអនុតំបន់មេគង្គ (GMS) ។គម្រោងចុងក្រោយរបស់ DAN ក្រោមកម្មវិធីជំនួយគាំទ្របច្ចុប្បន្នរបស់មូលនិធិ Rockefeller គឺការវាយតម្លៃពីផលប៉ះពាល់នៃប្រទេសចិនទៅលើការកាត់បន្ថយភាពក្រីក្រក្នុង GMS គ្រោងចប់សព្វគ្រប់នៅពាក់កណ្ដាលឆ្នាំ២០១០ ។ វិទ្យាស្ថាន CDRI និងដៃគូនានានៅក្នុង DAN នឹងព្យាយាមទាក់ទងរកដៃគូផ្ដល់ធនធានដល់ភាពជាដៃគូ GMS-DANថ្មីសម្រាប់ឆ្នាំ២០១១-២០១៥ ។

ក្នុងខែកុម្ភៈ ឆ្នាំ២០១០ នាយកប្រតិបត្តិនៃវិទ្យាស្ថាន CDRI បានចូលរួមក្នុងពិធីផ្សព្វផ្សាយរបាយការណ៍ឆ្នាំ២០០៩ ស្ដីពីការអនុវត្តគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ក្នុងតំបន់ របស់ធនាគារអភិវឌ្ឍន៍អាស៊ី-គណៈកម្មការសេដ្ឋកិច្ចសង្គមសហប្រជាជាតិសម្រាប់អាស៊ីនិងប៉ាស៊ីហ្វិក-កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (2009 ADB-ESCAP-UNDP Regional MDG Report) និងចូលរួមក្នុងសិក្ខាសាលាស្ដីពីគោលដៅអភិវឌ្ឍន៍សហសវត្សរ៍បន្ទាប់ពីឆ្នាំ២០១៥ នៅទីស្នាក់ការកណ្ដាលនៃ ADB នៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន ។

## ផ្នែកស្រាវជ្រាវ

ការស្រាវជ្រាវ និងសកម្មភាពពាក់ព័ន្ធនឹងការស្រាវជ្រាវខាងក្រោមនេះ បានធ្វើឡើងក្នុងអំឡុងខែមករា-មីនា ២០១០:

### កម្មវិធីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់

ការសិក្សាស្ដីពីវិនិយោគរបស់ចិននៅកម្ពុជា និងអង្កេតលើប្រាក់កំរៃនៅជនបទ បានចប់សព្វគ្រប់ហើយ ។របាយការណ៍ព្រាងទី២ ស្ដីពីការទាញផលប្រយោជន៍ឱ្យបានច្រើនជាអតិបរមាពីវិនិយោគរបស់ចិនលើធនធានធម្មជាតិនៅកម្ពុជា ត្រូវបានពិនិត្យឡើងវិញ និងគ្រោងហើយស្រេចបាច់នៅពាក់កណ្ដាលខែមីនា ២០១០ ។ របាយការណ៍លើជុំទី៣ នៃការវាយតម្លៃល្បឿនពីផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចទៅលើគ្រួសារនៅកម្ពុជា ដែលជាគម្រោងស្រាវជ្រាវរួមគ្នាជាមួយកម្មវិធីភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ បានបញ្ជូនទៅឱ្យធនាគារពិភពលោកហើយ ។ អង្កេតលើ ៧៥០គ្រួសារ និងការចាត់ចែងទិន្នន័យសម្រាប់ការវាយតម្លៃផលប៉ះពាល់សេដ្ឋកិច្ច-សង្គមកិច្ចនៃគម្រោងរបស់មហាអនុតំបន់មេគង្គ (GMS) បានចប់សព្វគ្រប់ ហើយក្រុមស្រាវជ្រាវ ក៏បានចាប់ផ្ដើមការងារវិភាគដែរ ។របាយការណ៍ព្រាងទី១ នៃការសិក្សាជុំទី ២ ស្ដីពីផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុសាកល បានបញ្ជូនទៅវិទ្យាស្ថានអភិវឌ្ឍន៍ក្រៅប្រទេស (ODI) រួចហើយ ដើម្បីសុំយោបល់ ។ សំណើគម្រោងសិក្សាបានកែសំរួលឡើងវិញស្ដីពីចរន្តពលករខុសៗគ្នា តម្រូវការ ខុសៗគ្នា និងផលប៉ះពាល់ខុសៗគ្នា: ការគ្រប់គ្រងចំណាកស្រុកកំលាំងពលកម្មអន្ដរជាតិនៅអាស៊ាន បានបញ្ជូនទៅឱ្យ និងទទួលយកដោយ វិទ្យាស្ថានហ្វីលីពីនសម្រាប់ការសិក្សាពីការអភិវឌ្ឍ (PIDS) រួចហើយ ។ គម្រោងស្រាវជ្រាវរួមគ្នាមួយគឺ DAN ៨ ស្ដីពីការវាយតម្លៃពីផលប៉ះពាល់របស់ចិនលើការកាត់បន្ថយភាពក្រីក្រនៅ GMS បានជឿនលឿនទៅមុខច្រើនហើយ ។ សមាជិកនៃបណ្ដាញវិភាគអភិវឌ្ឍន៍ (DAN) បានដកឃ្លាទៅសំរាកពិចារណា និងបង្កើតសិក្ខាសាលាស្រាវជ្រាវមួយនៅថ្ងៃទី១២-១៤ មករា ២០១០ នៅក្រុងគុនមិញ ប្រទេសចិន ដោយមានបង្ហាញ និងពិភាក្សាអំពីលទ្ធផលដំបូងៗនៃការសិក្សា ។

### កម្មវិធីអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យនិងកំណែទម្រង់វិស័យសាធារណៈ

កម្មវិធីនេះបានអនុវត្តគម្រោងស្រាវជ្រាវចំនួន៥ ។គម្រោងទី១ "អភិបាលកិច្ចនៅមូលដ្ឋានលើធនធានទ្រព្យរួមៈ ករណីទឹកស្រោចស្រពនៅកម្ពុជា" បានបញ្ចប់ និងកំពុងកែសម្រួលអត្ថបទរបាយការណ៍ ។ គម្រោងទី២ "ការវាយតម្លៃបែបគុណភាពពីផលប៉ះពាល់នៃគម្រោងសេវាច្រកចេញចូលតែមួយ" ក្រុមសិក្សាស្រាវជ្រាវ បានបញ្ចប់ការចុះប្រមូលព័ត៌មានក្នុង ៣ខេត្ត ហើយបច្ចុប្បន្ន កំពុងធ្វើរបាយការណ៍សម្រាប់ផ្ញើជូនធនាគារពិភពលោក ។ ក្រុមការងារ បានធ្វើសន្និសីទមួយតាមការបញ្ជូនរូបភាពវីដេអូភ្លាមៗ (video conference) ដើម្បីបង្ហាញលទ្ធផលបឋមដល់ធនាគារពិភពលោកនៅដើមខែកុម្ភៈ និងបានបញ្ជូនរបាយការណ៍ទី១ ទៅឱ្យគេនៅចុងខែកុម្ភៈនេះ ។ គម្រោងទី៣ " ការស្វែងយល់ពីការចូលពាក់ព័ន្ធគ្នារវាងសង្គមស៊ីវិល និងសមាជិកសភានៅកម្ពុជា": របាយការណ៍ព្រាងលើកទី២ បានបញ្ជូនទៅODI ដើម្បីសុំយោបល់ ហើយ ODI បានយល់ព្រម និងបានស្នើឱ្យក្រុមស្រាវជ្រាវដោះស្រាយសំនួរខ្លះបើសិនជាមាន នៅពេលដែល ODI ធ្វើការបូកសរុបជាមួយរបាយការណ៍ដូចគ្នាមកពី ៣ប្រទេសទៀត គឺថៃ វៀតណាម និងឥណ្ឌូនេស៊ី ។ គម្រោងទី៤

"ការវិភាគពីរដ្ឋកម្ពុជា: តើកម្ពុជាជារដ្ឋជំរុញអភិវឌ្ឍន៍?" កំពុងមានដំណើរការទៅមុខ ដោយក្រុមស្រាវជ្រាវ បាននិងកំពុងពិភាក្សាជាមួយទីប្រឹក្សានៅខាងក្រៅ (អ៊ុន យៀង) និងធ្វើគ្រោងឯកសារបឋម ។ ការសិក្សាឯកសារបន្ថែមទៀត ជាពិសេសស្តីពីកម្ពុជា និងបទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗខ្លះ គ្រោងធ្វើឡើងពីខែកុម្ភៈ ដល់ខែមីនា ដើម្បីពង្រឹងរបាយការណ៍ ។ គម្រោងទី៥ "យេនឌ័រក្នុងរដ្ឋបាលមូលដ្ឋាន: កិច្ចសហការជាមួយអង្គការអភិបាលកិច្ចមូលដ្ឋាន" បានចាប់ដំណើរការ ដោយបានរៀបចំនូវឯកសារគោលគំនិតមួយ ដែលមានស្នើឡើងនូវប្រធានបទបីពាក់ព័ន្ធនឹងបញ្ហាយេនឌ័រក្នុងរដ្ឋបាលមូលដ្ឋាន ។ នៅពេលមានការអនុម័តយកប្រធានបទមួយណាហើយ នឹងចាប់ផ្តើមការងារសិក្សាឯកសារ ។

**កម្មវិធីធនធានធម្មជាតិ និងបរិស្ថាន**

**កម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្រាវជ្រាវលើការគ្រប់គ្រងធនធានទឹក** (WRMRCDP): បានប្រមូល និងបញ្ចូលទិន្នន័យលើ ៣០០គ្រួសារ ក្នុងខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ និងកំពង់ធំ សម្រាប់ម៉ូឌុលស្នូលនៃសមាសភាគសេដ្ឋកិច្ច និងបានធ្វើការពិភាក្សាតាមក្រុម សម្រាប់សមាសភាគអភិបាលកិច្ច ។ ក្រុមស្រាវជ្រាវទឹក កំពុងធ្វើសិក្ខាសាលាថ្នាក់ខេត្តក្នុងខេត្តទាំងបី ដើម្បីផ្សព្វផ្សាយ និងផ្ទៀងផ្ទាត់លទ្ធផលស្រាវជ្រាវនៃសមាសភាគទាំងបី (អភិបាលកិច្ច រូបវន្ត និងសេដ្ឋកិច្ច) ។ កម្មវិធីនេះ កំពុងស្រាវជ្រាវជ្រើសជួលទីប្រឹក្សាម្នាក់ខាងកសាងគំរូវិភាគលើអភិបាលកិច្ចទឹក និងធារាសាស្ត្រ ។ កម្មវិធីនេះ បានកំពុងធ្វើការជាមួយមន្ទីរធនធានទឹក និងឧតុនិយមខេត្ត ដើម្បីកសាងផែនទីប្រព័ន្ធធារាសាស្ត្រទាំង១០ ដែលត្រូវសិក្សា ។ អ្នកបច្ចេកទេសម្នាក់មកពីវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា បានមកចូលរួមក្នុងសមាសភាគរូបវន្ត ដើម្បីជួយធ្វើគំរូវិភាគធារាសាស្ត្រ ។

**កម្មវិធីព្រៃតំបន់ត្រូពិកសម្រាប់ការកាត់បន្ថយភាពក្រីក្រ**-ការវិភាគទិន្នន័យតាំងពីកម្រិតគ្រួសារដល់កម្រិតសាកល កំពុងបន្តសំអាត និងវិភាគទិន្នន័យ ដោយសហការជាមួយអ្នកគ្រប់គ្រងទិន្នន័យរបស់មជ្ឈមណ្ឌលសម្រាប់ការស្រាវជ្រាវព្រៃឈើអន្តរជាតិ (CIFOR) ។ សម្រាប់គម្រោងការកសាងសមត្ថភាពសហគមន៍សម្រាប់ការផ្តួចផ្តើមគំនិតកាត់បន្ថយភាពក្រីក្រនៅតំបន់អាងទន្លេសាប បានធ្វើសិក្ខាសាលាថ្នាក់ឃុំជាច្រើន ។ ចំពោះគម្រោងការកសាងភាពធន់ទ្រាំនៃសហគមន៍នេសាទនៅបឹងទន្លេសាប: សកម្មភាពរួមគ្នា និងសមត្ថភាពគ្រប់គ្រងការប្រកួតប្រជែងខាងធនធាន ក្រុមស្រាវជ្រាវកំពុងសរសេរឯកសារពិភាក្សាស្តីពីទំនាស់ធនធានបរិស្ថាននៅកម្ពុជា ដើម្បីបោះពុម្ពផ្សាយនាពេលឆាប់ៗ ដោយក្នុងនេះ ជំពូកស្តីពីទំនាស់ជលផល បានចប់សព្វគ្រប់ ហើយជំពូក ៤ ទៀត កំពុងសរសេរទៅមុខ ។ សម្រាប់គម្រោងមាគ៌ាមានចីរភាពដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ ដែលមានរយៈពេលមួយឆ្នាំ និងឧបត្ថម្ភដោយវិទ្យាស្ថានបរិស្ថានក្រុង Stockholm (SEI) ក្រុមស្រាវជ្រាវ បានបញ្ជូនរបាយការណព្រាងទៅឱ្យការិយាល័យប្រចាំតំបន់របស់ SEI ហើយកំពុងកែសំរួលឡើងវិញខ្លះតាមការជួយមតិពីម្ចាស់ជំនួយ ។

**កម្មវិធីភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ**

សម្រាប់ការសិក្សាពីឌីណាមិកភាពក្រីក្រ (PDS) ការវិភាគទិន្នន័យបែបបរិមាណ ជិតបញ្ចប់ស្រេចបាច់ហើយ ដោយមានការជួយជ្រោមជ្រែងពីជំនាញការមកពីខាងក្រៅ ។ ផ្នែកនេះ នឹងពិគ្រោះពីលទ្ធផលជាមួយខាងធនាគារពិភពលោក ដើម្បីបញ្ចប់ឯកសារព្រាងនៃរបាយការណ៍បច្ចេកទេស ។ គម្រោងការវាយតម្លៃល្បឿនពីផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចលើគ្រួសារនៅកម្ពុជា មានរៀបរាប់ក្នុងកម្មវិធីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់នៅខាងលើ ។ អត្ថបទស្រាវជ្រាវស្តីពីការគ្រប់គ្រងហានិភ័យក្រៅផ្លូវការ និងរបៀបរបបអនុវត្តប្រព័ន្ធសុវត្ថិភាព: បទពិសោធន៍នៃពលករ និងគ្រួសារក្រីក្រ និងងាយរងគ្រោះ បានតាក់តែងឡើងសម្រាប់ចុះក្នុងរបាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ ២០០៩-១០ ។ គម្រោងមួយចំនួនសម្រាប់វាយតម្លៃផលប៉ះពាល់ខាងសេដ្ឋកិច្ច-សង្គមកិច្ចនៃច្រករបៀងនៅតំបន់ឆ្នេរភាគខាងត្បូងនៃមហាអនុតំបន់មេគង្គ (GMS-SCC) និងការប្រយុទ្ធប្រឆាំងជម្ងឺឆ្លងក្នុងមហាអនុតំបន់មេគង្គ (GMS-CDC) ដែលផ្តល់មូលនិធិដោយធនាគារអភិវឌ្ឍន៍អាស៊ី បានបញ្ចប់ការងារចុះអង្កេតដល់កន្លែង ការសំអាត និងការបញ្ចូលទិន្នន័យក្នុងកុំព្យូទ័រ ។ សព្វថ្ងៃ ក្រុមស្រាវជ្រាវ កំពុងវិភាគទិន្នន័យ និងតាក់តែងរបាយការណ៍ប្រចាំប្រទេស ។ គម្រោងការកសាងភាពធន់ទ្រាំនៃសហគមន៍នេសាទនៅបឹងទន្លេសាប: សកម្មភាពរួមគ្នា និងសមត្ថភាពគ្រប់គ្រងការប្រកួតប្រជែងខាងធនធាន ត្រូវបានចុះកិច្ចសន្យាជាមួយអង្គការ WorldFish និងផ្តល់មូលនិធិដោយ ក្រុមពិគ្រោះយោបល់លើការស្រាវជ្រាវកសិកម្មអន្តរជាតិ (CGIAR) ។ ករណីសិក្សាចំនួន៥ ដែលប្រើវិធីស្រាវជ្រាវសកម្មភាពដោយមានការចូលរួម បានបញ្ចប់រួចរាល់ និងសរសេរជារបាយការណ៍ដែលបានផ្ញើទៅ WorldFish ដើម្បីសុំព័ត៌មានត្រឡប់រួចហើយ ។

**កម្មវិធីអភិវឌ្ឍន៍សង្គម**

គម្រោងការសិក្សាមូលដ្ឋានពីអ្នកគ្រប់គ្រងគន្លឹះសម្រាប់កម្មវិធីទ្រទ្រង់វិស័យសុខាភិបាល កំពុងស្ថិតក្នុងដំណាក់កាលចុងក្រោយនៃការវិភាគ និងធ្វើរបាយការណ៍ ។ គម្រោងនេះ បានយឺតយ៉ាវបន្តិច ដោយសារបញ្ហាសុខភាពរបស់បុគ្គលិកនៃដៃគូដ៏សំខាន់មួយ ។ គម្រោងគ្រឿងលើកទឹកចិត្ត និងការរក្សាបុគ្គលិកសុខាភិបាលនៅតំបន់ជនបទ និងតំបន់អន់ថយនៃប្រទេសកម្ពុជា កំពុងដំណើរការយ៉ាងល្អ ។ ក្រុមស្រាវជ្រាវ ទើបបញ្ចប់ការងារចុះដល់កន្លែង និងការបញ្ចូលទិន្នន័យ ហើយបច្ចុប្បន្នកំពុងវិភាគទិន្នន័យ និងសរសេររបាយការណ៍ ។ គម្រោងនេះ រំពឹងថាអាចចប់សព្វគ្រប់តាមកាលបរិច្ឆេទកំណត់នៅចុងខែមីនា ២០១០ ។ គម្រោងការវិភាគសុវត្ថិភាពទាក់ទងនឹងបទល្មើស និងអំពើហិង្សា នៅក្នុងសហគមន៍ក្រីក្រនៅទីក្រុងចំនួន ៥ នៅរាជធានីភ្នំពេញ បានឈានដល់ដំណាក់កាលបញ្ចប់ ហើយបច្ចុប្បន្នកំពុងសរសេររបាយការណ៍សំរេច បន្ទាប់ពីទទួលបានមតិត្រលប់ពីក្រុមជំនាញការផ្នែកសុខភាពរបស់អង្គការសហប្រជាជាតិ និងសិក្ខាសាលាពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ ដើម្បីបញ្ជាក់លើលទ្ធផលរកឃើញ ។ ការងារត្រៀមរៀបចំសន្និសីទ

អន្តរជាតិនៅថ្ងៃ ២៦-២៨ មេសា ២០១០ ស្តីពីស្ថាប័ន គ្រឿងលើកទឹកចិត្ត និងសន្ទុះចិត្តក្នុងវិស័យសុខាភិបាល កំពុងលូតលាស់ទៅមុខយ៉ាងរលូន ។ វាគ្មិនទាំងអស់ បានបញ្ជាក់ការទទួលចូលរួម ហើយគណៈកម្មាធិការ កំពុងពិនិត្យឯកសារដែលបានរៀបចំសម្រាប់សន្និសីទ ។ វិទ្យាស្ថាន CDRI បានចុះកិច្ចសន្យាជាមួយក្រុមហ៊ុន University Research Co., LLC លើការគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់ការបោះពុម្ពផ្សាយឯកសារសន្និសីទ ។

**ផ្នែកបណ្តុះបណ្តាលជំនាញកសាងសន្តិភាព** បានបញ្ចប់ស្រេចបាច់នូវគម្រោងរយៈពេល ៣ឆ្នាំ ហើយបច្ចុប្បន្នកំពុងអនុវត្តគម្រោងរយៈពេលមួយឆ្នាំ ក្រោមការឧបត្ថម្ភពីអង្គការ Oxfam Novib ប្រទេសហូឡង់ ។ ក្រុមនេះកំពុងរៀបចំធ្វើការបណ្តុះបណ្តាលដោយផ្អែកលើការស្រាវជ្រាវវិញ ។ ការពិនិត្យឡើងវិញលើកម្មវិធីបណ្តុះបណ្តាលរបស់ផ្នែកនេះ ដែលធ្វើឡើងដោយទីប្រឹក្សាម្នាក់នៅ CDRI បន្ទាប់មកដោយក្រុមបណ្តុះបណ្តាលខ្លួនឯង និងមានអ្នកស្រាវជ្រាវចូលរួមផង បានរចនារៀបចំគម្រោងសាកល្បងពីរ គឺវគ្គបណ្តុះបណ្តាលស្តីពីជម្លោះទឹកក្នុងខេត្តកំពង់ឆ្នាំង និងវគ្គបណ្តុះបណ្តាលពាក់ព័ន្ធនឹងវិមជ្ឈការ និងវិសហមជ្ឈការ ។ បន្ទាប់ពីគម្រោងសាកល្បងទាំងពីរ នឹងមានវគ្គពិភាក្សាពីចំណុចខ្លាំង និងចំណុចខ្សោយផ្សេងៗ ។ ក្នុងអំឡុងពេលនេះ លោក នេត នាថ ត្រូវបានតំឡើងជាអ្នកស្រាវជ្រាវ ហើយអ្នកស្រី សុខ សិទ្ធា ត្រូវបានតំឡើងជាអ្នកស្រាវជ្រាវរង ។ មានអ្នកស្រាវជ្រាវរងមានជំនាញខាងអប់រំ និងសន្តិភាពម្នាក់ និងជំនួយការស្រាវជ្រាវម្នាក់ បានចូលបម្រើការក្នុងផ្នែកអភិវឌ្ឍន៍សង្គម ។

ចាប់តាំងពីឆ្នាំ២០០៧ មក វិទ្យាស្ថាន CDRI បាននឹងកំពុងរៀបចំសិក្ខាសាលារៀងរាល់ពីរខែម្តង ទាក់ទងនឹងការអភិវឌ្ឍ ដើម្បីចែករំលែកលទ្ធផលស្រាវជ្រាវ និងពង្រឹងគុណភាពស្រាវជ្រាវតាមរយៈការពិភាក្សា ការកែលំអវិធីសាស្រ្តស្រាវជ្រាវ ការបំផុសនិងវិភាគគោលគំនិតនៃការស្រាវជ្រាវ ។ អ្នកធ្វើបទបង្ហាញក្នុងសន្និសីទទាំងនេះ ជាអ្នកស្រាវជ្រាវនៅ CDRI និងអ្នកស្រាវជ្រាវ និងអ្នកអនុវត្តផ្ទាល់ មកពីស្ថាប័នផ្សេងៗ និង NGOs នៅរាជធានីភ្នំពេញ ។ ក្នុងអំឡុងពេលនេះ អ្នកធ្វើបទបង្ហាញមកពី CDRI គឺមាន បណ្ឌិត តុង គឹមស៊ុន អ្នកសម្របសំរួលកម្មវិធីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់ ។ អ្នកធ្វើបទបង្ហាញមកពីក្រៅ រួមមាន សាស្រ្តាចារ្យ Bent Jorsensen មកពីសាលាសិក្សាជាសាកល នៃសកលវិទ្យាល័យ Goteborg University ប្រទេសស៊ុយអ៊ែត ។ ប្រធានបទ មានដូចជា ការអភិវឌ្ឍម៉ាក្រូសេដ្ឋកិច្ច ភាពក្រីក្រ អភិបាលកិច្ច ពាណិជ្ជកម្មនិងធនធានធម្មជាតិ និងកសិកម្ម ។

## Cambodia Development Review—2010 Subscription Rates

**Domestic Subscription (Individual)**

❒ English edition ($14) ❒ Khmer edition (5,000 riels) Payment by ❒ cash or ❒ local cheque (please add $2 to cover bank charges for processing local cheques). Total payment enclosed..............................................................................

**Domestic Subscription (Discount Price for Bulk Orders—Five Copies)**

❒ English edition ($60 for five copies) ❒ Khmer edition (20,000 riels for five copies) Payment by ❒ cash or ❒ local cheque (please add $2 to cover bank charges). Total payment enclosed..............................................................................

**International Subscription (Individual)**

| | | |
|---|---|---|
| ❒ Thailand, Laos, Vietnam | ❒ English edition ($25)* | ❒ Khmer edition ($15)* |
| ❒ Asia and Europe | ❒ English edition ($30)* | ❒ Khmer edition ($20)* |
| ❒ Americas and Africa | ❒ English edition ($35)* | ❒ Khmer edition ($25)* |

* Subscription includes postage. **Payment options:**

**1.** By Telegraphic Transfer – Please add $10 for bank charges to the above Total Cost.
Transfer to:
Account Name: CDRI
Account Number: 133451
Bank Name: ANZ Royal Bank
Bank Address: Phnom Penh, Cambodia
Swift Code: ANZBKHPP
Receiver Correspondent Bank: JP Morgan Chase Manhattan Bank, New York
Swift Code: CHASUS33
CHIP UID 004966

**2.** By Cheque - Please add (overseas) $50 for bank charges to the above Total Cost. Please make Cheque payable to CDRI, attach it to this invoice and send in to Publications.

Title: ❒Mr ❒Ms ❒Dr ❒ Other ..............................................................................

First name: .................................... Family name: .................................... Position: ....................................

Organisation / Company: ..............................................................................

Address (CCC Box if applicable): ..............................................................................

City / Province: .................................................. Country: ..................................................

Telephone: .................................................. Fax: ..................................................

e-mail: .................................................. ❒ Tick to receive regular information about CDRI publications via e-mail

To subscribe simply fill in this form and return it to CDRI with your payment. Do not send cash through the post.
Please inform the Publishing Department at CDRI if your contact details change.

# ព័ត៌មានថ្មីៗពី វិទ្យាស្ថាន CDRI

## ផ្នែកគ្រប់គ្រង

ឆ្នាំ២០១០ ជាឆ្នាំគំរប់ខួបលើកទី២០ នៃការបង្កើតវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ-CDRI) ។ ដើម្បីអបអរសាទរខួបឆ្នាំនេះ មានការរៀបចំសកម្មភាពបីសំខាន់ៗ គឺមានការរៀបចំ និងតាំងបង្ហាញរូបភាពលើព្រឹត្តិការណ៍ និងជោគជ័យសំខាន់ៗ ចាប់តាំងពីការកកើតវិទ្យាស្ថាន CDRI នៅពេលធ្វើសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១០ នាខែមីនា ពិធីជប់លៀងអបអរសាទរនៅពាក់កណ្តាលឆ្នាំ២០១០ សម្រាប់បុគ្គលិកចាស់-ថ្មី ក្រុមប្រឹក្សាភិបាល និងអ្នកពាក់ព័ន្ធទាំងអស់របស់វិទ្យាស្ថាន CDRI និងការសំរាកការងារឱ្យបុគ្គលិកដកឃ្លាទៅពិចារណាពីតួនាទី និងអាទិភាពរបស់វិទ្យាស្ថាន CDRI នាពេលអនាគត ។ វិទ្យាស្ថាន CDRI នឹងចាប់ដំណើរការគេហទំព័រដែលរចនារៀបចំ និងប្រើបច្ចេកវិទ្យាថ្មី នាឱកាសធ្វើសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ជាមួយគ្នានឹងការផ្សព្វផ្សាយរបាយការណ៍ប្រចាំឆ្នាំ២០០៩-១០ ដែរ ។

សន្និសីទចក្ខុវិស័យប្រទេសកម្ពុជាប្រចាំឆ្នាំលើកទី៤ ក្រោមកិច្ចសហការជាដៃគូរវាងវិទ្យាស្ថាន CDRI និងធនាគារ ANZ Royal និងមានប្រធានបទ "ការសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ឡើងវិញ: អាទិភាពខាងគោលនយោបាយ និងសកម្មភាពដើម្បីកំណើន និងការអភិវឌ្ឍមានចីរភាព" ត្រូវប្រារព្ធធ្វើឡើងនាថ្ងៃទី១៧ មីនា ២០១០ ដោយមានសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចូលរួមជាអធិបតីដ៏ខ្ពស់ខ្ពស់ជាថ្មីម្តងទៀត និងថ្លែងសុន្ទរកថាគន្លឹះបើកសន្និសីទដល់អ្នកចូលរួមជាង ៣០០នាក់ ។ កម្មវិធី បទបង្ហាញ និងឯកសារផ្សេងៗពាក់ព័ន្ធនឹងសន្និសីទ មានចុះក្នុងគេហទំព័ររបស់វិទ្យាស្ថាន CDRI ។ ឯកសារសង្ខេបមួយចំនួនស្តីពីចក្ខុវិស័យប្រទេសកម្ពុជា ដែលបង្ហាញពីបញ្ហាសំខាន់ៗ ព្រមទាំងអនុសាសន៍ខាងគោលនយោបាយ និងសកម្មភាព កំពុងរៀបចំឡើងសម្រាប់ចែកជូនអ្នកចូលរួមក្នុងសន្និសីទ និងសហគមន៍អភិវឌ្ឍន៍កម្ពុជា ។ ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា ក្នុងលេខចេញផ្សាយខែមេសា-មិថុនា ២០១០ នឹងមានចុះផ្សាយពីអត្ថបទស្តីពីខ្លឹមសារសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា និងប្រធានបទតាមវគ្គពិភាក្សានានា ។

បន្ទាប់ពីសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា វិទ្យាស្ថាន CDRI ក៏រៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលសម្រាប់ឆ្នាំ២០១០ នៅថ្ងៃទី១៨ មីនា ។ ក្រុមប្រឹក្សាភិបាល ត្រូវអនុម័តលើក្របខ័ណ្ឌដំបូងសម្រាប់យុទ្ធសាស្ត្រស្រាវជ្រាវប្រទេសកម្ពុជាឆ្នាំ២០២០ ដើម្បីណែនាំពីរបៀបវារៈខាងគោលនយោបាយ និងការស្រាវជ្រាវ នាពេលអនាគតរបស់ CDRI ផែនការយុទ្ធសាស្ត្រឆ្នាំ២០១១-១៥ និងធ្វើជាមូលដ្ឋានសម្រាប់ការកេណ្ឌប្រមូលធនធាន រួមទាំងទិសដៅអភិវឌ្ឍន៍ធំទូលាយមានរយៈពេលវែងផង ។ យុទ្ធសាស្ត្រនេះ ត្រូវកសាងបន្តទៀតក្នុងពេញមួយឆ្នាំ២០១០ ដោយមានការពិគ្រោះយោបល់ជាមួយរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធសំខាន់ៗ បន្ទាប់មកត្រូវផ្សព្វផ្សាយទៅដល់ដៃគូអភិវឌ្ឍន៍ សម្រាប់ធ្វើជាមូលដ្ឋានផ្តល់ជំនួយមានការសំរបសំរួលល្អដល់ CDRI ។ យុទ្ធសាស្ត្រនេះ ក៏មានផ្តោតលើតួនាទីរបស់ប្រទេសចិន និងអ្នកដើរតួនាទីសំខាន់ៗដទៃទៀតនៅក្នុងមហាអនុតំបន់មេគង្គ ការផ្លាស់ប្តូរនានាដែលទំនងនឹងកើតមាន និងផល

(តទៅទំព័រ ២១)

ទស្សនាវដ្តី អភិវឌ្ឍន៍កម្ពុជា
ឯកសារបោះពុម្ពផ្សាយរបស់ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
ឆ្នាំទី១៤ លេខ១ ខែមករា-មីនា ឆ្នាំ២០១០

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* បោះពុម្ពផ្សាយដោយ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នៅភ្នំពេញចំនួន ៤ដង ក្នុងមួយឆ្នាំជាភាសាខ្មែរ និងភាសាអង់គ្លេសនៅក្នុងពេលដំណាលគ្នា ។

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ផ្តល់ជាវេទិកាមួយ ដើម្បីពិភាក្សាពីបញ្ហានៃការអភិវឌ្ឍន៍ដែលកំពុងតែជះឥទ្ធិពលដល់ប្រទេសកម្ពុជា ។ អត្ថបទតាមដានសេដ្ឋកិច្ច ផ្តល់ជូននូវមូលវិចារឯករាជ្យស្តីពីដំណើរប្រព្រឹត្តទៅនៃសេដ្ឋកិច្ចប្រទេសកម្ពុជា ។

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ស្វាគមន៍អត្ថបទទាំងឡាយពីប្រិយមិត្តអ្នកអាន ។ លិខិត ត្រូវចុះហត្ថលេខាប្រត្យក្សភាព ទូរស័ព្ទ និងមានអាសយដ្ឋានផង ។ អ្នកនិពន្ធទាំងអស់ត្រូវទាក់ទង វបសអ មុននឹងជូនអត្ថបទរបស់ខ្លួន ទោះជាឯកសារនោះមិនទាន់រៀបរយក៏ដោយ ។ ឯកសារទាំងអស់នឹងត្រូវកែសម្រួលសម្រាប់ការបោះពុម្ព ។ វបសអ សូមរក្សាសិទ្ធិបដិសេធការបោះពុម្ព ដោយមិនចាំបាច់បញ្ជាក់ពីហេតុផល ។

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
☞ អាសយដ្ឋាន ៥៦ ផ្លូវ ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា
✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
☎ (៨៥៥-២៣) ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣ 🖷 (៨៥៥-២៣) ៨៨០-៧៣៤
e-mail: cdri@wicam.com.kh
website: http://www.cdri.org.kh

9 789995 052065

គ្រឹះស្ថានផ្សាយ: វបសអ
គ្រប់គ្រងកែសំរួល: យូ សិទ្ធិរិទ្ធ
កែសំរួលផលិតកម្ម: អ៊ុំ ចាន់ថា និង អ៊ឹង សុជាតិ
ជំនួយការកែសំរួល: វ៉ា វណ្ណៈ និង ខេង សេង
រោងពុម្ពជប៉ុន ភ្នំពេញ រូបភាពទំព័រមុខ: រូបភាព វបសអ

© រក្សាសិទ្ធិ ២០១០ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
រក្សាសិទ្ធិគ្រប់យ៉ាង-គ្មានផ្នែកណាមួយនៃការបោះពុម្ពផ្សាយនេះត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗដូចជា: អេឡិចត្រូនិក យន្តកម្មថតចម្លង... ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពី វបសអ ឡើយ ។

ISSN 1560-7615 / ISBN 978-99950-52-06-5

គំនិត ការលើកពីហេតុការណ៍ និងការបញ្ចេញយោបល់ទាំងឡាយនៅក្នុង *ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ស្ថិតក្រោមការទទួលខុសត្រូវទាំងស្រុងរបស់អ្នកនិពន្ធ ។ ការបញ្ចេញយោបល់ និងការបកស្រាយទាំងនោះ មិនមែនជាទស្សនៈរបស់ *វបសអ* ទេ ។